អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Oct-2013, 15:05
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# លើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៥នាទី**

**សវនាការលើកទី២១៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger Phillips)*

លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន
*(Mr.Nicolas KoumJian)*

លោក យ៉េត ចរិយា

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ត់

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak )*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*
លោក លោក ឃីត រេយ៍ន័រ
*(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*
កញ្ញា អង់តា ហ្គីសសេ*(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

លោក វ៉េន ពៅ

លោក ហុង គីមសួន

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ជេត វណ្ណលី

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine JAQUIN)*
កញ្ញា លីម៉ាង្វៀន *(Ms.Lyma NGUYEN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*
លោកស្រី អេឡូឌី ឌុយឡាក់
*(Ms.Elodie DULAC)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:៤៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា និងលោក នួន ជា លើកធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន លោក ដាវ អានសាន ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពជម្រាបរាយការណ៍ជូនលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីមានវត្តមាន។ សូមកត់សម្គាល់ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុសុខភាព។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក អានសាន។ បាទ ជាបន្តនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា និងលោក នួន ជា ឡើងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅលើសំណុំរឿង ០០២/០១ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដល់លោក នួន ជា និងមេធាវីការពារក្ដីរបស់លោក នួន ជា ផងដែរថា ពេលវេលាដែលអង្គជំនុំជម្រះផ្ដល់សម្រាប់ការធ្វើសេចក្ដីសន្និដ្ឋាននេះសរុបទាំងជនជាប់ចោទ ទាំងមេធាវីការពារក្ដីផងមានរយៈពេលពីរថ្ងៃ ហើយអង្គជំនុំជម្រះក៏ចង់ដឹងផងដែរថា ជាការចាប់ផ្ដើមនេះ តើមេធាវីការពារក្ដីធ្វើសន្និដ្ឋានកិច្ចពិភាក្សាដេញដោលមុន ឬក៏ជូនវេទិកាជូនទៅជនជាប់ចោទ ដើម្បីឡើងធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួនមុន?

[០៩:០៧:១៥]

**លោក វិ៊ចទ័រ កូប៉េះ**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្ដីនឹងចាប់ផ្ដើមធ្វើសេចក្ដីសន្និដ្ឋានពីរថ្ងៃមុន ហើយបន្ទាប់មកកូនក្ដីរបស់ខ្ញុំនឹងប្រើកន្លះថ្ងៃខាងក្រោយដើម្បីធ្វើសេចក្ដីសន្និដ្ឋានរបស់គាត់បាទ។

សូមជម្រាបសួរភាគីទាំងអស់ មេធាវីការពារក្ដី ហើយនិងភាគីទាំងអស់ ហើយនិងសាធារណជនជាទីគោរព! លោកប្រធាន លោក លោកស្រីចៅក្រម សូមអនុញ្ញាតឲ្យខ្ញុំចាប់ផ្ដើមនៅផែនទីវិថីនៃការវិភាគដែលយើងខ្ញុំនឹងបង្ហាញជូនអង្គជំនុំជម្រះក្នុងរយៈពេលពីរថ្ងៃខាងមុខនេះ។ ខ្ញុំនឹងចាប់ផ្ដើមព្រឹកនេះដោយការពិភាក្សាបញ្ហាមួយចំនួនដែលមានសារៈសំខាន់ទាក់ទងទៅនឹងភាពយុត្តិធម៌ និងភាពស្របច្បាប់នៃការជំនុំជម្រះនេះ។

[០៩:០៨:០០]

ខ្ញុំក៏នឹងពន្យល់ជូនអង្គជំនុំជម្រះអំពីនីតិវិធីដែលបានប្រើប្រាស់ដោយសាលាក្ដីនេះ ដែលរាប់បញ្ចូលទាំងវិធីដែលពិនិត្យមើលរឿងក្ដីនេះ ក្នុងការស៊ើបអង្កេត ហើយនិងការជំនុំជម្រះបានបរាជ័យមិនគោរពតាមស្តង់ដារ ការជំនុំជម្រះដោយយុត្តិធម៌ ដែលសាលាក្ដីនេះត្រូវបានបង្កើតឡើង និងត្រូវគោរពតាម។ ខ្ញុំនឹងជម្រាបជូនថា អ្វីដែលអនុវត្តនៅក្នុងសាលសវនាការនេះ គឺមិនមែនជាការជំនុំជម្រះទាល់តែសោះតាមអត្ថន័យដែលយើង -- ក្នុងឋានៈជាមេធាវីយល់ដឹងនោះ។ ប៉ុន្តែផ្ទុយទៅវិញ គឺមិនបានបង្កើតជារឿងក្ដីគំរូនៃការសេចក្ដីសន្និដ្ឋានថា ម្នាក់ដែលចូលរួមដែលចង់បាន ហើយនិងរំពឹងជារៀងរាល់ថ្ងៃឲ្យទទួលបានពីសាលាក្ដីនេះនោះទេ។

សហសេវិករបស់ខ្ញុំ សុន អរុណ នឹងចំណាយពេលពាក់កណ្ដាលព្រឹកនេះ ហើយនិងពេលល្ងាចដើម្បីពិភាក្សាអំពីប្រវត្តិ ហើយនិងតួនាទីរបស់គាត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ លោក សុន អរុណ នឹងពន្យល់អំពីអង្គហេតុសំខាន់ៗអំពីប្រវត្តិរបស់លោក នួន ជា ហើយនិងមូលហេតុរបស់គាត់នៃការចូលហើយនិងការដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ គាត់នឹងបង្ហាញជូនអង្គជំនុំជម្រះថាតួនាទីរបស់ នួន ជា ក្នុងឋានៈជាមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា គឺមិនមានលក្ខណៈទូលំទូលាយដូចដែលសហព្រះរាជអាជ្ញាលើកឡើងនោះទេ។ សំខាន់បំផុតលោក នួន ជា មិនមានតួនាទីនៅក្នុងយោធា ហើយមានតួនាទីយ៉ាងមានកម្រិតនៅក្នុងសន្តិសុខផ្ទៃក្នុង។ កូនក្ដីរបស់យើងក៏មិនបានធ្វើការត្រួតពិនិត្យកម្មាភិបាលថ្នាក់ក្រោមរបស់បក្សកុម្មុយនីស្តកម្ពុជានៅមូលដ្ឋាននោះដែរ។ ផ្ទុយទៅវិញ គាត់បានទាក់ទងជាមូលដ្ឋានជាមួយ

លេខាភូមិភាគ ដែលជាអ្នកអនុវត្តនូវការងារដោយឆន្ទានុសិទ្ធិរបស់គេ នៅក្នុងភូមិភាគរបស់គេនីមួយៗ។ នៅផ្នែកចុងក្រោយនៃវគ្គថ្ងៃនេះ ខ្ញុំនឹងត្រឡប់មកពិភាក្សាអំពីគោលនយោបាយពីររបស់បក្សកុម្មុយនីស្ត កម្ពុជាពីរនៅក្នុងការជំនុំជម្រះនេះ។ ការដែលចោទប្រកាន់ថា ការមានការសម្លាប់ទាហាន លន់ នល់ និងអ្នករដ្ឋការលន់នល់ ហើយខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះថា គោលនយោបាយនេះមិនធ្លាប់មានទេ។ ហើយខ្ញុំនឹងជម្រាបជូនជាលម្អិតថា សហព្រះរាជអាជ្ញាចាត់ទុកភស្តុតាងទាំងឡាយថា មានការពាក់ព័ន្ធទៅនឹងគោលនយោបាយដែលគេចោទប្រកាន់នេះថា គាត់បានជ្រើសរើសដោយចោះៗ ហើយជាការធ្វើឲ្យភ័ន្តច្រឡំ។

[០៩:១១:១៧]

នៅថ្ងៃទី២នៃការសន្និដ្ឋានរបស់យើងខ្ញុំ នៅថ្ងៃព្រហស្បតិ៍ ខ្ញុំនឹងផ្តោតទៅលើទីតាំងបទល្មើសចំនួនបីដែលចោទជាបញ្ហានៅក្នុងការជំនុំជម្រះនេះ៖ ទួលពោធិ៍ជ្រៃ ការជម្លៀសទីក្រុងភ្នំពេញ ហើយនិងការចោទប្រកាន់អំពីការបំលាស់ទីប្រជាជនលើកទី២ ដំណាក់កាលទី២។ ខ្ញុំនឹងចាប់ផ្តើមនៅព្រឹកថ្ងៃព្រហស្បតិ៍ ដោយពិភាក្សាអំពីទួលពោធិ៍ជ្រៃ។ ហើយខ្ញុំនឹងជម្រាបអង្គជំនុំជម្រះអំពីភស្តុតាងនៅជុំវិញហេតុការណ៍ដែលចោទឡើងនៅទួលពោធិ៍ជ្រៃនោះ គឺវាមានកម្រិត ហើយមិនស៊ីសង្វាក់គ្នា ហើយធ្វើឲ្យមានការភ័ន្តច្រឡំ។ ហើយខ្ញុំនឹងជម្រាបថា សហព្រះរាជអាជ្ញាបានខកខានមិនបានបង្ហាញភស្តុតាងឲ្យច្បាស់លាស់អំពីអ្វីដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ ក្នុងខែមេសា ឆ្នាំ១៩៧៥។

បន្ទាប់មកខ្ញុំនឹងជម្រាបជូនថា សហព្រះរាជអាជ្ញាមិនបានបង្ហាញភស្តុតាងថា មានអ្វីកើតឡើងនៅទួលពោធិ៍ជ្រៃទេ ហើយក៏មិនមានអ្វីពាក់ព័ន្ធទៅនឹងកូនក្តីរបស់ខ្ញុំដែរ។ ផ្ទុយទៅវិញភស្តុតាងបានបង្ហាញយ៉ាងច្បាស់ថា ហេតុការណ៍នៅទួលពោធិ៍ជ្រៃអាចបានដឹកនាំ ប្រព្រឹត្តដោយកម្មាភិបាលមូលដ្ឋានមកពីថ្នាក់ស្រុក និងតំបន់ ហើយអាចថាជាលេខាភូមិភាគពាយ័ព្យ រស់ ញឹម។

[០៩:១២:៤៤]

ក្នុងករណីណាក្តីតួនាទីរបស់ នួន ជា ហើយនិងការទទួលខុសត្រូវរបស់ នួន ជា មិនត្រូវបានបង្ហាញភស្តុតាងទេ។ នៅក្នុងផ្នែកទី២ នៃព្រឹកថ្ងៃព្រហស្បតិ៍នោះលោក សុន អរុណ នឹងជម្រាបជូនអង្គជំនុំជម្រះនូវកាលវិភាគអំពីជីវភាពរស់នៅក្នុងកម្ពុជាក្នុងឆ្នាំ១៩៧៥ ខែមេសា។ លោក សុន អរុណ នឹងជម្រាបថា ការផ្គត់ផ្គង់ស្បៀងអាហារ និងថ្នាំសង្កូវនៅភ្នំពេញគឺស្ថិតនៅក្នុងវិបត្តិ ហើយជិតនឹងដល់មហន្តរាយទាំងស្រុងហើយ។ គាត់នឹងពន្យល់ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាថា វិបត្តិនេះ

ចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩៧២ គឺមុនយូរពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានត្រួតត្រាលើបណ្តាញផ្គត់ផ្គង់មកភ្នំពេញនោះ។ គាត់នឹងពន្យល់ជូនថា នៅខែមេសា ឆ្នាំ១៩៧៥ សេដ្ឋកិច្ចកម្ពុជាត្រូវបានបំផ្លាញដោយសង្គ្រាម ជាពិសេសការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ គាត់ក៏ពន្យល់ដែរ មុនពេលជោគជ័យរបស់បក្សកុម្មុយនីស្តកម្ពុជានៅខែមេសា ឆ្នាំ១៩៧៥ រដ្ឋាភិបាលសហរដ្ឋអាមេរិកក៏បានធ្វើការទស្សន៍ទាយអំពីការទុរ្ភិក្សទូទាំងប្រទេសកម្ពុជា ហើយជាពិសេសនៅក្នុងទីក្រុងភ្នំពេញក្នុងរយៈពេលប៉ុន្មានឆ្នាំដែលនឹងចូលមកនោះ។

[០៩:១៤:១៣]

លោកប្រធាន នៅល្ងាចថ្ងៃព្រហស្បតិ៍ ខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះជាចុងក្រោយដើម្បីពិភាក្សាអំពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ហើយនិងដំណាក់កាលបំលាស់ទីប្រជាជនវគ្គទី២នោះ។ ហើយខ្ញុំនឹងជម្រាបអំពីគោលនយោបាយដែលមជ្ឈិមបក្សបានកំណត់នោះ ត្រូវបានកំណត់ជាពាក្យទូទៅខ្លាំងណាស់។ ហើយមិនបានពាក់ព័ន្ធទៅក្នុងការបង្កើតឲ្យមានការប្រព្រឹត្តនូវអំពើឧក្រិដ្ឋនោះទេ។

បន្ទាប់មកខ្ញុំនឹងពន្យល់ថា ការកម្រិតនូវគោលនយោបាយនេះ គឺជាការទទួលខុសត្រូវនៃកម្មាភិបាលថ្នាក់ក្រោម ដែលធ្វើការដោយមានការត្រួតពិនិត្យពីលេខាភូមិភាគរបស់គេ។ បទឧក្រិដ្ឋនានាដែលត្រូវបាន អាចត្រូវបានអនុញ្ញាតគឺជាផលវិបាកនៃការអនុវត្ត។ វាមិនមែនជាចេតនា ឬក៏គម្រោងដោយកូនក្តីរបស់ខ្ញុំ នួន ជា ទេ។

លោកប្រធាន លោក លោកស្រីចៅក្រម! ដោយទស្សនៈរួមនេះ ខ្ញុំសូមអនុញ្ញាតត្រឡប់ទៅខ្លឹមសារនៃការពិភាក្សានៅព្រឹកនេះ។ គឺនិយាយអំពីភាពយុត្តិធម៌នៃការជំនុំជម្រះនេះ ហើយនិងធម្មានុរូបនៃសាលាក្តីមួយនេះ។ ដូចដែលអង្គជំនុំជម្រះបានជម្រាបហើយ សាធារណជនក៏បានជម្រាបដែរ នេះគឺជាការផ្តោតអារម្មណ៍ជាបន្តបន្ទាប់ ហើយនិងជាសំខាន់ទៅលើមេធាវីការពារក្តី នួន ជា ចាប់តាំងពីមានការចាប់ខ្លួនលោក នួន ជា។ ហើយដោយមានមូលហេតុល្អ ភាពមិនប្រក្រតីខាងនីតិវិធីនៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយនៅក្នុងការជំនុំជម្រះនេះ កើតមានឡើងជាញឹកញាប់ជានិច្ចកាល ហើយធ្វើឲ្យមានការរំខានខ្លាំង ដែលយើងមានការលំបាកក្នុងការជំទាស់ឲ្យបានគ្រប់ទាំងអស់នោះណាស់។

[០៩:១៦:១៦]

ដូចនោះដែរ ផលវិបាកនៃការត្រួតត្រារបស់រដ្ឋាភិបាលលើការជំនុំជម្រះនីតិវិធីទាំងអស់នេះ។ ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ យើងនឹងជម្រាបជូនអំពីការបរាជ័យទាំងអស់

នេះនៅព្រឹកនេះ។ ប៉ុន្តែខ្ញុំនឹងជម្រាបជូនអំពីគំនិតទូទៅមួយចំនួនជាមុនសិន។ តាមពិត គឺថាសេចក្ដីពិស្ដារនៃនីតិវិធីសំខាន់ណាស់ ប៉ុន្តែមានហានិភ័យក្នុងការផ្ដោតអារម្មណ៍ទៅលើសេចក្ដីលម្អិត ដែលយើងមិនបានផ្ដោតទៅលើរូបភាពឲ្យបានទូលាយ។ នៅក្នុងសហចៅក្រមស៊ើបអង្កេត ហើយនិងអង្គជំនុំជម្រះនេះមិនបានធ្វើសេចក្ដីសម្រេចមួយចំនួនដែលល្អត្រឹមត្រូវទេ គឺមានផ្នែកមួយចំនួនតូចដែលបានធ្វើត្រឹមត្រូវ ហើយមានមូលហេតុជាក់លាក់។ ដូច្នេះ សូមជម្រាបថា គ្មាននរណាម្នាក់នៅក្នុងតុលាការនេះមានការចាប់អារម្មណ៍ក្នុងការស្វែងរកការពិតទេ។

តុលាការនេះ មិនត្រូវបានបង្កើតឡើងដើម្បីរកឲ្យឃើញអំពីអ្វីដែលកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ។ តុលាការនេះត្រូវបានបង្កើតឡើងដោយមូលហេតុផ្ទុយពីនេះទៅវិញ។ ដោយហេតុថាប្រជាជនបានដឹង ឃើញ គិតឃើញថា គេបានដឹងពីអ្វីដែលបានកើតឡើងនោះរួចហើយ។ គេបានគិតថាគេដឹងថាអ្នកណាជាអ្នកទទួលខុសត្រូវ។ ហើយគេបង្កើតតុលាការនេះឡើង ក្នុងគោលបំណងដាក់ទោសអ្នកទាំងនោះ។ អ្នកទាំងនោះដែលគេបានសម្រេចរួចហើយថាមានពិរុទ្ធភាព មុនពេលដែលអគារនេះដែលយើងកំពុងតែស្ថិតនៅក្នុង អគារនេះមិនទាន់បានបង្កើតនោះ។ សូម្បីតែខ្ញុំឈរនៅទីនេះដើម្បីនិយាយពាក្យទាំងអស់នេះ ខ្ញុំអាចដឹងពីប្រតិកម្មរបស់សាធារណជន ហើយខ្ញុំស្ទើរតែដឹងថាមនុស្សទាំងអស់នៅក្នុងសាលសវនាការនេះ និយាយខ្លួនឯងថា "បាទ មែនហើយ", ដោយតែអ្នកទាំងអស់នោះមានពិរុទ្ធភាព។ តើអ្នកណាខ្លះដែលសួរខ្លួនឯងនៅថ្ងៃនេះថា "ហេតុអ្វី? តើវាមានបញ្ហាអី ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងដំណើរការនីតិវិធី? នៅទីបញ្ចប់ នួន ជា នឹងត្រូវគេថាមានពិរុទ្ធភាពទៅហើយ។ ឥឡូវនេះ គឺថាមានចម្លើយពីរ ទៅនឹងសំណួរនេះ ទាក់ទងនឹងបញ្ហានេះ។ ទី១ គឺចម្លើយរបស់មេធាវី។ ចម្លើយហ្នឹងគឺថានៅក្នុងតុលាការដែលប្រើច្បាប់ ភាពយុត្តិធម៌នៃនីតិវិធីចោទជាបញ្ហាចម្បងបំផុត។ មានមូលហេតុមួយចំនួនដែលត្រូវបង្កើត អ.វ.ត.ក នេះឡើង។ តុលាការកើតឡើង ដោយសារសហគមន៍អន្តរជាតិ អង្គការសហប្រជាជាតិ។ គ្រប់ៗគ្នាដឹងថា មិនមានការជំនុំជម្រះសមស្របទេ នៅក្នុងប្រព័ន្ធតុលាការជាតិកម្ពុជានោះទេ។

[០៩:១៩:១៩]

មូលហេតុដែលយើងមកទីនេះ នៅថ្ងៃនេះ គឺត្រូវគោរពទៅតាមនីតិវិធីបែបនោះ។ អនុញ្ញាតឲ្យរដ្ឋាភិបាលកម្ពុជាឲ្យអួតសរសើរដោយមោទនភាពថា កូនក្ដីរបស់យើងខ្ញុំ ត្រូវបានជំនុំជម្រះ ដោយជំនុំជម្រះ ដោយយុត្តិធម៌ ដោយឯករាជ្យ និងអព្យាក្រិត។ ហើយប៉ុន្តែយើងមិនអាចសម្រេចបានទេ បើ

ដូច្នោះទេការអនុវត្តរបស់យើងនេះមិនជោគជ័យ។ ហើយយើងគិតបែបនេះ គឺថាវាសព្វគ្រប់ ជាមូលដ្ឋានសព្វគ្រប់។ ក៏មានចម្លើយទី២ទៅនឹងសំណួរនេះដែរ។ ចម្លើយទី២នោះគឺថា គឺមានបញ្ហាជាក់ស្តែងហើយបញ្ហាមិនដោះស្រាយបានអំពីការទទួលខុសត្រូវរបស់ នួន ជា ចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងការជំនុំជម្រះនេះ។ សូម្បីតែក្រោយពីបីឆ្នាំនៃការស៊ើបអង្កេតរបស់តុលាការ ហើយនិងពីរឆ្នាំទៀតនៃការជំនុំជម្រះ ការពិតភស្តុតាងពិតប្រាកដអំពីការដឹង ហើយនិងចេតនារបស់លោក នួន ជា ទៅនឹងបទឧក្រិដ្ឋនេះគឺមិនអាចរកឃើញទេ។ ការយល់ឃើញជាទស្សនៈជាសាធារណៈយល់ថាភស្តុតាងលើសលប់ពី នួន ជា, ពិរុទ្ធភាព នួន ជា ហ្នឹងគឺមិនពិតទេ។ មិនមានបញ្ហាអីដែលថាសហព្រះរាជអាជ្ញាអន្តរជាតិអះអាងថាមានភស្តុតាងដ៏លើសលប់។ ហើយការអះអាងបែបនេះគឺថាជាភស្តុតាងជាភស្តុតាងដែលមិនគួរឲ្យជឿជាក់បាន គួរឲ្យអស់សំណើច។ គឺអត្ថបទសារព័ត៌មាន អ្នកកាសែតបរទេស ការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលនិយាយអំពីលទ្ធិកុម្មុយនីស្ត ហើយនិងទ្រឹស្តីវណ្ណៈ។ ប៉ុន្តែមិនដែលណែនាំឲ្យអ្នកណាម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋ។ ផ្ទុយទៅវិញ មិនបានបង្ហាញពីពិរុទ្ធភាព នួន ជា ទេ។ តែបង្ហាញថាមិនមានពិរុទ្ធភាពទៅវិញ ភស្តុតាងទាំងនេះ។

[០៩:២១:១៤]

លោកប្រធាន យើងនឹងពន្យល់ពីបង្ហាញនេះឲ្យបានលម្អិតក្នុងរយៈពេលពីរថ្ងៃខាងមុខនេះ ដូចដែលយើងបានបញ្ជាក់ក្នុងសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សររបស់យើង។ ប៉ុន្តែ ខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញអំពីឧទាហរណ៍ជាក់ស្តែងមួយ។ ជាសេចក្តីសន្និដ្ឋានមួយដ៏ច្បាស់អំពីកម្ពុជាប្រជាធិបតេយ្យនោះដែលថាបក្សកុម្មុយនីស្តកម្ពុជាបង្កើតឡើងនូវការសម្លាប់ជាប្រព័ន្ធនូវអតីតសាធារណរដ្ឋខ្មែរ។ ប៉ុន្តែយើងមិនដឹងថាតើអ្វីជាការផ្សាយដំណឹងល្អដែលគេទទួលស្គាល់ទេ ប្រហែលជាគេចាប់ផ្តើមឡើងដោយគំនិតដំបូងរបស់ *ហ្វាន់ស្វ័រ* ប៉ុងស្វ៊ ដែលនិយាយអំពីហេតុការណ៍របស់ភូមិភាគពាយ័ព្យដែលនិយាយពីការកាប់សម្លាប់។ លោក ប៉ុងស្វ៊ បានធ្វើសក្ខីកម្មថាគាត់ទទួលស្គាល់ថាសេចក្តីសន្និដ្ឋានរបស់គាត់អំពីនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការសំណេររបស់គាត់នោះ គឺផ្អែកលើភស្តុតាងតិចតួចទេ ដែលមិនអាចជាតំណាងអ្វីៗទាំងអស់នៅក្នុងប្រទេសកម្ពុជាទេ។ ប៉ុន្តែគំនិតនោះបានដាក់ចូលទៅក្នុងសេចក្តីពិស្តាររបស់កម្ពុជាប្រជាធិបតេយ្យ គឺថាយើងមិនអាចចាត់ទុកដកចេញគំនិតនេះទេ។ ប៉ុន្តែវាចូលទៅក្នុងបន្ទប់មួយដែលមានអេកូ គឺថាអ្នកផ្សេងទៀត អ្នកជំនាញផ្សេងទៀតបានប្រើពាក្យនេះ ហើយអ្នកផ្សេងម្នាក់ទៀតប្រើជាបន្តគ្នា។ ជាយថាហេតុគឺម្នាក់ៗចាត់ខ្លួនថា ខ្លួនដឹងពីអ្វីដែលនឹងកើតឡើង។ ប៉ុន្តែមិនមានភស្តុតាង

អ្វីបញ្ជាក់ថាឲ្យពិតជាកើតមាននោះទេ។

[០៩:២៣:០១]

លោក លោកស្រីចៅក្រម ខ្ញុំសូមអញ្ជើញឲ្យអង្គជំនុំជម្រះប្រៀបធៀបសេចក្ដីសន្និដ្ឋានរបស់យើង អំពីប្រព្រឹត្តកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើទាហានសាធារណរដ្ឋ ហើយនិងមន្ត្រីរដ្ឋការរបស់គេ ដែលព្រះរាជអាជ្ញាបានលើកឡើង។

អង្គជំនុំជម្រះនឹងពិនិត្យឃើញថា សេចក្ដីសន្និដ្ឋានរបស់យើងគឺមានលក្ខណៈពិស្ដារ និងជាក់លាក់ជាង។ យើងបានសន្និដ្ឋាន យើងមើលចម្លើយសាក្សី យើងពិនិត្យមើល តើគេនិយាយអ្វី ហើយសួរថាពីអ្វី? ជាក់ស្ដែង តើវាបង្ហាញភស្ដុតាងពីអ្វី? សហព្រះរាជអាជ្ញាបានអះអាងដោយផ្អែកលើ ទៅលើភស្ដុតាងដែលមិនប្រាកដនិយម។ គេបានលើកឡើងទ្រឹស្ដីបក្សកុម្មុយនីស្តកម្ពុជាដែលមិនច្បាស់លាស់ដែលមិនបាននិយាយអ្វី ឬក៏មិនបាននិយាយជាក់លាក់អ្វីពីការកាប់សម្លាប់ទេ។ គេមិនបានផ្ដល់ភស្ដុតាងជាក់ស្ដែងណាមួយអំពីចេតនារបស់លោក នួន ជា ទេ។ ផ្ទុយទៅវិញគេបានបង្ហាញ -- ដែលយើងខ្ញុំនឹងបង្ហាញពេលក្រោយពួកគេបានសម្រេចមិនប្រើភស្ដុតាងផ្ទាល់ដែលទាក់ទងពីចេតនារបស់លោក នួន ជា ទេ។ ប៉ុន្តែដោយការសន្និដ្ឋានពួកគាត់មិនបង្ហាញពីអ្វីដែលបញ្ហានោះវាចោទឡើង។ ទឡ្ហីករណ៍របស់គាត់នោះ គឺថាមិនមានអ្វីក្រៅពីការលើកឡើងដដែលៗជាបន្តបន្ទាប់ដោយគ្មានមូលដ្ឋាន ជាការសន្និដ្ឋានថាបក្សកុម្មុយនីស្តពិតជាបានធ្វើបែបនោះ។ អ្វីដែលបានធ្វើឡើងពីព្រោះថា ខ្លួនបានដឹងបក្សកុម្មុយនីស្តធ្វើអាក្រក់។ យើងបានដឹង គឺមិនបានគោរពទៅលើជីវិតរបស់មនុស្សទេ។

[០៩:២៤:៤១]

សហព្រះរាជអាជ្ញានៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនចុងក្រោយនោះ បានក្របដណ្ដប់ឡើងដោយវិធីសាស្ត្រនៃការបង្ហាញភស្ដុតាងបែបនេះឯង។ ភស្ដុតាងជាក់ស្ដែងអំពីការទទួលខុសត្រូវរបស់កូនក្ដីរបស់ខ្ញុំលើបទឧក្រិដ្ឋនោះគឺថាមានកម្រិតណាស់ ដែលយុទ្ធសាស្ត្ររបស់សហព្រះរាជអាជ្ញានោះ ពិបាកនឹងពន្យល់ឲ្យអង្គជំនុំជម្រះយល់ថាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាគឺជាបិសាចនោះ។ ពួកគេបានប្រាប់រឿងរ៉ាវគួរឲ្យរន្ធត់អំពីបទពិសោធន៍នៃបុគ្គលមួយចំនួនដោយមិនបានអះអាងថា បទពិសោធន៍ទាំងអស់នោះបានឆ្លុះបញ្ចាំង ឬក៏ជាផលវិបាកនៃនយោបាយបក្សកុម្មុយនីស្តកម្ពុជាទេ។ គេបានប្រើពាក្យសម្ដីភាសាសាមញ្ញដែលគួរឲ្យស្អប់ខ្ពើមដើម្បីពិពណ៌នាអំពីប្រវត្តិសាស្ត្រដ៏ស្មុគស្មាញនោះ។

[០៩:២៥:៣៥]

ពួកគាត់បានដកស្រង់ដោយចោះៗអំពីអត្ថបទរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយមិនបានបញ្ជាក់ថាការបោះពុម្ពផ្សាយនោះនិយាយជាក់លាក់ណែនាំកម្មាភិបាលឱ្យយកចិត្តទុកដាក់បញ្ញវន្ត ហើយនិងពួកគហបតីឱ្យបានល្អដោយមានការគោរពផងនោះ។ ការចុចយកភស្តុតាងដោយចោះៗរបស់សហព្រះរាជអាជ្ញានោះគឺបង្ហាញឱ្យយើងឃើញយ៉ាងច្បាស់ថា គឺជាការមិនយកចិត្តទុកដាក់ទៅលើចម្លើយរបស់នួនជាទៅនឹង ថេត សម្បត្តិ។ ប៉ុន្តែផ្ទុយទៅវិញ សហព្រះរាជអាជ្ញាបញ្ជាក់ម្តងហើយម្តងទៀត អំពីភាពជឿជាក់របស់កូនក្តីខ្ញុំ។ ពួកគេបានហៅថា ជាការបោកបញ្ឆោតភាពមិនស្មោះត្រង់ ហើយចោទប្រកាន់គាត់ថាជាបង្កើតការកុហកដើម្បីបំភ័ន្តលោក លោកស្រីចៅក្រម។ ប៉ុន្តែផ្ទុយទៅវិញ ពួកគាត់បានដកស្រង់បន្តបន្ទាប់អំពីសៀវភៅរបស់ ថេត សម្បត្តិ ហើយនិងខ្សែភាពយន្តរបស់ ថេត សម្បត្តិ។ ហើយគាត់និយាយថាដកស្រង់ពីលោក នួន ជា គឺថាដកយកចំណុចមួយចំនួនតូចដែលនិយាយអំពីភស្តុតាងដាក់បន្ទុក ហើយនិងសូមបង្ហាញម្តងទៀត "ហើយពួកគេបញ្ជាក់ថាវាមានការសារភាពគួរឱ្យច្បាស់លាស់ដែលគួរឱ្យជឿទុកចិត្តបានខ្លាំង ដោយថាមិនមានការសម្ពាធនោះ"។ ប៉ុន្តែពួកគេមិនបានប្រាប់លោក លោកស្រីចៅក្រមអំពីចម្លើយរបស់គាត់ទៅ ថេត សម្បត្តិ ដែលឆ្លើយជាសម្ងាត់ទៅបុគ្គលដែលគាត់ជឿដែលតាមពិតជាការដោះបន្ទុកទៅលើលោក នួន ជា នោះ។ ឧទាហរណ៍មួយដែលមានសារៈសំខាន់ទាក់ទងទៅនឹងការជំនុំជម្រះពាក់ព័ន្ធទៅចម្លើយកូនក្តីរបស់ខ្ញុំពាក់ព័ន្ធទៅនឹងការកាប់សម្លាប់ទាហានលន់ នល់ ហើយនិងការជម្លៀសទីក្រុងភ្នំពេញនោះ យើងនឹងនិយាយបញ្ហានេះនៅពេលក្រោយ នៅពេលដែលយើងនិយាយពីការចោទប្រកាន់ជាក់លាក់ទាំងអស់នេះ។

ជាទូទៅសហព្រះរាជអាជ្ញាបានដកស្រង់ចោះៗទៅលើចម្លើយរបស់លោក នួន ជា ដែលបង្ហាញអំពីការកាប់សម្លាប់មេដឹកនាំខ្ពស់របស់សាធារណរដ្ឋខ្មែរដែលហៅថា "ជនមហាក្បត់"។ ប៉ុន្តែផ្ទុយ ពួកគាត់ មិនបានលើកឡើងអំពីថាមានគោលនយោបាយទំលំទូលាយទេ។ លោក លោកស្រីចៅក្រមសូមពិនិត្យមើលតើអ្វីដែលយើងពិនិត្យមើលវីដេអូ៥នាទី ដោយមិននិយាយចោះៗអំពីគំនិតអ្វីដូចសហព្រះរាជអាជ្ញាបានលើកឡើងនោះ។

[០៩:២៨:៤៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"សៈនេះសូមបញ្ជាក់អំពីចំណុចនេះមួយទាក់ទងនឹងខ្ញុំសួរកាលមុនម្តងហើយប៉ុន្តែចង់បញ្ជាក់ដាក់នៅក្នុងនេះបន្តិចទ័យថា ទាក់ទិននឹងទាហានលន់នល់បាទ កាលដែលរំដោះថ្ងៃ១៧ មេសា ៧៥ នោះបាទ*

តើមានគោលនយោបាយយ៉ាងណាខ្លះចំពោះទាហានលន់នល់ ហើយ ឬមួយក៏មានតែនយោបាយដោះស្រាយតែពួកពីរបីនាក់ខាងលើ តើមានអ្នកណាខ្លះ ឬយ៉ាងម៉េចបាទ? ព្រោះថាពេលក្រោយរំដោះមកវាមានការយកទាហានទៅសម្លាប់អ៊ីចឹងបាទ នេះសូមអ៊ំជួយដោះស្រាយតើបញ្ហាហ្នឹងយ៉ាងណា តាមអ៊ំជ្រាបបាទ? ធ៖ "តាមខ្ញុំដឹង មាគ៌ាចំពោះទាហាននេះចាញ់ មួយដាក់អាវុធៗ គេដាក់អាវុធហើយណាស់ ត្បិតពីរ បញ្ជូនគេទៅស្រុកគេ ទៅផ្ទះគេនៅឯណាឲ្យគេទៅនុ៎ងទៅ អាហ្នឹងតាមខ្ញុំចាំ ប៉ុន្តែការពិតទៅអត់យ៉ាងម៉េចៗយើងមិនដឹងទេ។ ស៖ អ៊ឹៗ បញ្ជាក់មាគ៌ានយោបាយចំពោះអ្នកប៉ុន្មាននាក់ហ្នឹង បីបួនប្រាំនាក់យ៉ាងម៉េចបាទ គោលនយោបាយ? ធ៖ គោលនយោបាយគឺកម្ទេច។ និយាយពាក្យងាយៗគឺកម្ទេច ព្រោះពួកនេះវាទោសធ្ងន់ណាលក់ប្រទេសជាតិធ្វើបរិវារគេអាហ្នឹងមានប៉ុណ្ណឹង។ ស៖ ចុះក្រោយមកអ៊ំមានបានឮគេជម្រាបទាក់ទិនទៅនឹងរឿងបញ្ហាដូចជាការ ក្រោយពីថ្ងៃ១៧មេសា បីបួនប្រាំថ្ងៃបាទ មានការដោះស្រាយទាហានជាច្រើនពាន់នាក់ ដូចជានៅពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ តើបញ្ហានេះអ៊ំមានបានជម្រាបទេពេលនោះ? ធ៖ ពេលនោះខ្ញុំមិនដឹងទេ គឺការដោះស្រាយអីផ្សេងៗណា៎ មិនបានដឹងទាល់តែសោះមែន។ ខ្ញុំដឹងខ្លះនៅពេលដែលធ្វើសមាហរណកម្មនេះហើយ បានដឹងយ៉ាងម៉េចៗខ្លះបន្តិចបន្តួច និងគេឲ្យនិយាយ -- ដែលគេឲ្យដឹងហ្នឹងណា៎។ ប៉ុន្តែអង្កាល់នុ៎ងអត់ដឹងទេ។ ហើយបើដឹងកាលដឹងថាមានបញ្ហាហ្នឹងយ៉ាងម៉េច ក៏ត្រូវមានវិធានការទប់ទល់ដែរ កុំឲ្យមានអ៊ីចឹង។ មានវិធានការទប់ទល់ ពីព្រោះអ្នកអស់នេះគ្នាគ្មានទោសកំហុសអីទេ ជាកូនទាហានធម្មតានោះ ហើយជានិយាយរួមដូចជាប្រជាជនធម្មតាអ៊ីចឹង។ ស៖ ព្រោះអង្កាល់ហ្នឹងក្រោយរំដោះបីបួនប្រាំថ្ងៃហ្នឹង បីថ្ងៃហ្នឹង ឬពីរថ្ងៃហ្នឹង គេប្រាប់ថា ឲ្យទៅទទួលសម្តេច ហើយទៅទទួលសម្តេចប្រាប់អ្នកណាដែលមានឋានន្តរសក្តិ ពីស័ក្តិ ដូចជា ស័ក្តិ៥អីឡើងទៅ ឬក៏ស័ក្តិ៣អី ឬក៏ស័ក្តិ១ ស័ក្តិ២អីឡើងទៅណាអ៊ំ ឲ្យមក។ អ៊ីចឹងអ្នកខ្លះប្រជាជនធម្មតាក៏មកបន្លំថា ឯងជាស័ក្តិដែរ ហើយអ៊ីចឹងក៏បានគេដឹកចេញទៅបាទ។ ធ៖ បញ្ហានេះខ្ញុំមិនដឹងទេ។ ខ្ញុំមិនដឹង អាហ្នឹងមូលដ្ឋានហើយធ្វើ ធ្វើហើយមើលទៅ។ ខ្ញុំមិនដឹងទេ។ ស៖ ចំពោះដែលមានហេតុភេទកើតឡើងអ៊ីចឹង តើអ៊ំយល់ឃើញថា តើព្រឹត្តិការណ៍ហ្នឹងកើតឡើងដោយសារយ៉ាងណាបាទ? ធ៖ បើតាមខ្ញុំមានព្រឹត្តិការណ៍អ៊ីចឹង ខ្ញុំថាមកពីការគំនុំគុំគួន។ គំនុំគុំគួនគ្នាណា៎ ព្រោះពីដើមយើងដឹងដូចគ្នាហើយធ្វើការសម្លាត់ ត្រូវចាប់ត្រូវចងអី តិញ្ញអី ត្រូវតែវ៉ៃ ដូចអ៊ីចឹងការគំនុំគុំគួន សងសឹកវិញអាចមាន។ អានេះខ្ញុំមិនបដិសេធថា គ្មានទេ ប៉ុន្តែខ្ញុំវាមិនដឹង ខ្ញុំមិនដឹងណា៎ អាចនឹងមានអ៊ីចឹង។ ស៖ នយោបាយចំពោះ លន់ នល់ ហើយនិង សិរិមតៈ ពេលរំដោះហើយភ្លាមៗ តើមាននយោបាយ

*យ៉ាងណាដែរបាទ? គេបានចោទប្រកាន់អាពីរឿងកំហុសភ្លាម មានសម្លាប់ទាហានលន់នល់ ដឹកយកទៅសម្លាប់អីអ៊ីចឹង តើមាននយោបាយរបស់ថ្នាក់ដឹកនាំទេ? ឆ៖ ខ្ញុំដូចមិនដឹងទេ គឺថាមិនដឹងជាដឹកទាហាន លន់ នល់ ទៅអីណា? យកទៅអីណាអត់ដឹងទេ ពីព្រោះមិនមែនជានាទីខាងយោធា។ ប៉ុន្តែថាបើគេចាញ់ហើយ អង្គាល់នោះរំសាយឲ្យទៅសហករណ៍ទាំងអស់គ្នា ពួកទាហាន លន់ លន់ ពួកសំណល់អីគេហ្នឹង គឺទៅសហករណ៍ទាំងអស់គ្នាទៅ ពីព្រោះនៅក្រុងវាគ្មានអីចិញ្ចឹម។ ឯការខុសឆ្គងយ៉ាងម៉េចៗអីយ៉ាងម៉េចនោះ ការអីយ៉ាងម៉េចៗក៏យើងពិបាកយល់ដែរ ពីព្រោះពេលនោះវាច្របូកច្របល់ណាស់ ដូចខ្ញុំថាអ៊ីចឹងវាសង្គ្រាមចារកម្មវាចាប់ផ្តើមឡើងណ៎ា។ អានេះថាអានោះ អានោះថាអានេះ វាពិបាកណាស់។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៣៣:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

លោក លោកស្រីចៅក្រម វាមានមូលហេតុអ្វីដែលកូនក្តីយើងត្រូវកុហសអំពីបញ្ហានេះ ហេតុអ្វីក៏ទើបតែត្រូវនិយាយកុហសឥឡូវនេះ។ នួន ជា ឥឡូវគាត់អាយុ៨៧ឆ្នាំហើយ គាត់ជិតស្លាប់ទៅហើយ ហើយគាត់ដឹងច្បាស់ថា គាត់នឹងស្លាបនៅក្នុងគុក គាត់យល់ព្រម យល់ស្របថា គាត់គឺជាអនុលេខានៃបក្សកុម្មុយនីស្តកម្ពុជា គាត់យល់ស្របថាគាត់ឯកភាព ហើយបានចូលរួមនៅក្នុងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ គាត់បានឯកភាព គាត់បានយល់ព្រមថាគាត់បានឯកភាពជាមួយសេចក្តីសម្រេចក្នុងការសម្លាប់ជនមហាក្បត់ ហើយគាត់បញ្ជាក់ថាគាត់ដឹងអំពីសេចក្តីសម្រេចក្នុងការសម្លាប់ សោ ភឹម ដែលជាមិត្តភក្តិជិតស្និទ្ធនិងចាស់បំផុតរបស់គាត់។ ដូច្នេះខ្ញុំចង់សួរថាហេតុអ្វីគាត់ទទួលស្គាល់ថា គាត់ដឹងអំពីអង្គហេតុទាំងអស់នេះ តែបដិសេធអំពីទួលពោធិ៍ជ្រៃទៅវិញ? ហេតុអ្វីក៏គាត់ទទួលស្គាល់ពីតួនាទីរបស់គាត់នៅក្នុងការជម្លៀសប្រជាជនលើកទី១ ប៉ុន្តែបដិសេធតួនាទីនៅក្នុងការជម្លៀសលើកទី២ទៅវិញ?

លោកប្រធាន លោក លោកស្រីចៅក្រម ព្រះរាជអាជ្ញាគាត់ព្យាយាមធ្វើឲ្យសាធារណជន និងអង្គជំនុំជម្រះយល់ច្រឡំ ដោយការប្រើប្រាស់នូវចំណងជើងដ៏គួរឲ្យយល់ខុសចំពោះហេតុការណ៍ពិតហេតុការណ៍ប្រវត្តិសាស្ត្រទាំងអស់នេះ។ ឥឡូវនេះគឺជាអ្វីដែលព្រះរាជអាជ្ញាគេកំពុងតែប្រើប្រាស់នូវពាក្យថ្មីមួយដើម្បីបិទភ្ជាប់ទៅនឹងកម្ពុជាប្រជាធិបតេយ្យ ដែលគេហៅពាក្យមួយថាជា "រដ្ឋទាសករ"។ បន្ទាប់ពីដំណើរការនីតិវិធីប្រាំមួយឆ្នាំរួចមកហើយ ឥឡូវនេះព្រះរាជអាជ្ញាគាត់មានការក្លាហានគ្រប់គ្រាន់ក្នុងការនិយាយថា គោលដៅជារួមរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា គឺដើម្បីបង្កើននូវរដ្ឋ

ទាសករ។ ការប្រើប្រាស់ពាក្យនេះ គឺវាគ្មានន័យអីទាំងអស់ ដែលថាជាការស្វែងយល់អំពីកម្ពុជាប្រជាធិបតេយ្យ ហើយនិងការស្វែងយល់អំពីចេតនារបស់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។

[០៩:៣៥:៤៧]

ឥឡូវនេះខ្ញុំសូមជម្រាបជូនដល់អង្គជំនុំជម្រះថា ទោះបីជាកិច្ចនីតិវិធីប្រឆាំងនឹងលោក នួន ជា ត្រូវបានធ្វើឡើងអស់រយៈជាងប្រាំមួយឆ្នាំក៏ដោយ ពាក្យថា"រដ្ឋទាសករ" ទើបតែចូលមកក្នុងវចនានុក្រមរបស់អង្គជំនុំជម្រះនេះមិនដល់ប្រាំមួយខែមុនផង គឺនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ នៅក្នុងសក្ខីកម្មរបស់លោក ហ្វីលីព ស្សូត។ យើងធ្វើការស្រាវជ្រាវទៅលើសំណុំរឿងដើម្បីរកពាក្យ "រដ្ឋទាសករ" គឺថាពាក្យនេះប្រើប្រាស់ដំបូង គឺនៅរយៈពេលពីរថ្ងៃបន្ទាប់ពីលោក ហ្វីលីព ស្សូត មកផ្តល់សក្ខីកម្មនៅថ្ងៃទី ១០ ខែឧសភា។ លោក ស្សូត ដែលជាអ្នកបង្កើតពាក្យនេះឡើង គឺថាទើបតែបានមកជាន់ស្រុកខ្មែរនៅក្នុងឆ្នាំ១៩៩៣ ជាលើកដំបូងបំផុត។ គាត់ចាប់ផ្តើមការស្រាវជ្រាវរបស់គាត់អំពីបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ៩៩ គាត់មិនចេះភាសាខ្មែរ គាត់មិនអាចនិយាយ និងអានភាសាខ្មែរបាននោះទេ។ គ្មានអ្នកនិពន្ធ អ្នកសង្កេត ឬក៏សាក្សីផ្ទាល់ ឬក៏អ្នកសិក្សាស្រាវជ្រាវនានាអំពីព្រឹត្តិការណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ធ្លាប់ប្រើប្រាស់ពាក្យនេះពីមុនមកទេ។ ក៏ប៉ុន្តែឥឡូវនេះ ព្រះរាជអាជ្ញាទើបតែប្រាប់យើងទាំងអស់គ្នាថាគំនិតរបស់លោក ហ្វីលីព ស្សូត គឺជាគំនិតដ៏ល្អបំផុតទាក់ទងទៅនឹងគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា។ សូម្បីតែសារាចររបស់បក្សកុម្មុយនីស្តកម្ពុជាផ្ទាល់ សូម្បីតែសុន្ទរកថារបស់លោក ប៉ុល ពត ផ្ទាល់ក៏មិនមានបញ្ហាអំពីបញ្ហាទាំងអស់នេះដែរ។ ដូច្នេះហើយការយកគំនិតដែលមិនមានការគាំទ្ររបស់អ្នកសារព័ត៌មានអង់គ្លេសដែលទើបតែមកដល់កម្ពុជា ២០ឆ្នាំក្រោយមានការកើតហេតុ ហើយមិននិយាយភាសាខ្មែរមួយម៉ាត់សោះ តើវាមានន័យយ៉ាងដូចម្តេចដែរ។

[០៩:៣៧:៣៣]

ដូច្នេះ អ្វីដែលព្រះរាជអាជ្ញាបានប្រើប្រាស់ថា គោលដៅជារួមរបស់អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គឺដើម្បីបង្កើតរដ្ឋទាសករហ្នឹង គឺមិនបាន -- គឺមិនមានលក្ខណៈជាពិតប្រាកដនោះឡើយ។ នៅក្នុងដីកាដំណោះស្រាយដែលបានចេញនៅថ្ងៃ០៩ ខែ-- ២០១២ សហចៅក្រមស៊ើបអង្កេតបានដកស្រង់ថា "គោលដៅរួមរបស់បមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គឺដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមឆាប់រហ័សតាមរយៈមហាលោតផ្លោះ មហាអស្ចារ្យ និងការពារបក្សពីខ្មាំងទាំងក្នុង និងខាងក្រៅតាមគ្រប់មធ្យោបាយដែលចាំបាច់"។ សូមបញ្ចប់ការដកស្រង់។

ទោះបីជារដ្ឋអាជ្ញាបាន -- ព្រះរាជអាជ្ញាបានជំទាស់នៅក្នុងសារណាបញ្ចប់ការពិភាក្សានៅក្នុងសារណាចុងក្រោយរបស់គេក៏ដោយ ថាការទាក់ឲ្យទៅជាទាសករ គឺជាគោលនយោបាយមួយបក្សកម្ពុជា ក៏ប៉ុន្តែគេប្រកាសថា ចេតនាជារួមនៃសហកម្មឧក្រិដ្ឋកម្ម គឺដើម្បីជំរុញបដិវត្តន៍នយោបាយ និងកម្ទេចពួកជំទាស់ ពួកផ្នែកនយោបាយនានាចំពោះការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។

ឥឡូវនេះយើងធ្វើការជំទាស់ជាមួយនឹងការបង្កើតពាក្យថ្មី ដែលរៀបរាប់អំពីអាកប្បកិរិយារបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះខ្មាំង។ ប៉ុន្តែហោចណាស់ក៏ដោយ ការបង្កើតទាំងអស់នេះបានបង្ហាញថាបក្សកុម្មុយនីស្តកម្ពុជាមានគោលដៅមួយ។ ពួកគេមានគោលដៅនយោបាយ ដែលថាពួកគេវាយប្រយុទ្ធដើម្បីគោលដៅអ្វីមួយ។

[០៩:៣៨:៥៩]

នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលចុងក្រោយរបស់សហព្រះរាជអាជ្ញា គឺបញ្ហាទាំងអស់នេះវាអត់មានអ្វីទាក់ទងទាល់តែសោះ។ គោលដៅគឺគ្មានប្រយោជន៍ មិនមានការប្រើប្រាស់អំពីបរិបទគឺថាបក្សកុម្មុយនីស្តកម្ពុជាបានក្លាយពីចលនានយោបាយទៅជាចលនាឧក្រិដ្ឋជន។ វាក្លាយទៅជាស្ថាប័នមួយដែលគោលដៅ គឺដើម្បីគ្រាន់តែដាក់ប្រជាជនឲ្យទៅជាទាសករតែប៉ុណ្ណោះ។ នេះគឺជាការយល់ឃើញខុស ដែលគេព្យាយាមទាញអំពីបញ្ហាដែលអង្គជំនុំជម្រះគួរតែសួរខ្លួនឯងផ្ទាល់។ បញ្ហាគឺថាតើលោក នួន ជា មានចេតនាឲ្យបដិវត្តន៍សង្គមនិយមរបស់ -- បក្សកុម្មុយនីស្តកម្ពុជាក្លាយទៅជាអំពើឧក្រិដ្ឋដែរឬទេ? ចម្លើយពិតប្រាកដគឺថាអត់ទេ។

លោកប្រធានការវិភាគរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺនៅតែមិនអាចយល់បាន។ សហព្រះរាជអាជ្ញានៅតែអះអាងថា គឺគោលដៅនៃការជម្លៀស គឺដើម្បីផ្តន្ទាទោសដល់ប្រជាជនទីក្រុងភ្នំពេញ។ ហើយពួកគេហាក់ដូចជាភ្ញាក់ផ្អើលដោយសារចេតនារបស់លោក នួន ជា ដែលថាគោលដៅសំខាន់គឺដើម្បីធ្វើការកែតម្រូវគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជា។ ពួកគេសួរថា ហេតុអ្វីបានគេគិតថាគួរតែជម្លៀសប្រជាជនកម្ពុជាចេញទីក្រុងភ្នំពេញ បន្ទាប់ពីមានកិច្ចដំណើរការនីតិវិធីប្រាំមួយឆ្នាំនេះ។

[០៩:៤០:៣២]

លោក លោកស្រីចៅក្រម យើងភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសំណួររបស់ព្រះរាជអាជ្ញានេះ។ កូនក្តីរបស់យើង គឺជាអនុលេខាស្ថាប័នមួយដែលគេហៅថា បក្សកុម្មុយនីស្តកម្ពុជា។ គាត់មានឋានៈទី២

នៅក្នុងថ្នាក់ដឹកនាំនៃចលនាបដិវត្តកុម្មុយនីស្ត។ ចលនាកុម្មុយ -- រចនាសម្ព័ន្ធបក្សកុម្មុយនីស្ត គឺជាទម្រង់ និងវិធីសាស្ត្រមួយនៃការបង្កើតនូវសេដ្ឋកិច្ច។ ពួកគេអនុវត្តគោលនយោបាយសេដ្ឋកិច្ចជារួម ហេតុដូច្នេះ ហើយទើបមានបក្សកុម្មុយនីស្តកម្ពុជា។ នេះហើយគឺជាអ្វីដែលពួកគេធ្វើ។ ទោះបីជាដីកាដំណោះស្រាយ បានចោទប្រកាន់ថា គោលដៅនៃការជម្លៀសប្រជាជន គឺដើម្បីបង្កើនចំនួនប្រជាជននៅសហករណ៍ របស់បក្សកុម្មុយនីស្តតែប៉ុណ្ណោះ។

[០៩:៤១:២៦]

ដូចគ្នានឹងការប្រើប្រាស់ពាក្យ “រដ្ឋទាសករ” សហព្រះរាជអាជ្ញាក៏បានបង្កើតធ្វើឲ្យមានការភ្ញាក់ផ្អើលដែលថានិយាយថា ការជម្លៀសទីក្រុងភ្នំពេញ គឺជាផ្នែកព្យាយាមមួយ ដើម្បីធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជាខុសច្បាប់។ ការបង្កើតឲ្យមាននូវស្ថាប័នមួយដែលមានលក្ខណៈជាការប្រឌិតបែបនេះ ហើយជាការបង្កើតឲ្យមានស្ថាប័នមួយដែលមានចេតនាឧក្រិដ្ឋកម្ម។ សារៈសំខាន់នៃការប្រើប្រាស់ពាក្យថា “រដ្ឋទាសករ” ចំពោះគោលគំនិតរបស់សហព្រះរាជអាជ្ញាទៅលើរបបកម្ពុជាប្រជាធិបតេយ្យនោះ បង្កើតឲ្យមានបញ្ហាមួយទៀតដែលមានសារៈសំខាន់ផងដែរ។ នោះគឺជាលក្ខណៈនូវប្រភពព័ត៌មានដែលសហព្រះរាជអាជ្ញាពឹងផ្អែកទៅលើ។ យើងបានធ្វើការកត់សម្គាល់ ហើយបានជំទាស់ទៅលើបញ្ហានេះតាំងពីពេលមុនរួចមកហើយ។ ការប្រើប្រាស់ប្រភពព័ត៌មានទី២ ដើម្បីគាំទ្រការចោទប្រកាន់អង្គហេតុសំខាន់នោះគឺជាលក្ខណៈពិសេសដែលមានបញ្ហាយ៉ាងធ្ងន់ធ្ងររបស់នីតិវិធីនៅក្នុងអង្គជំនុំជម្រះមួយនេះ។

[០៩:៤២:៣៣]

លោកប្រធាន លោក លោកស្រីចៅក្រម ការវិភាគជាលក្ខណៈក្រៅផ្លូវការទៅលើភស្តុតាងដែលពឹងផ្អែកដោយសហព្រះរាជអាជ្ញាជាតិ កាលពីថ្ងៃអង្គារមុននេះ បានបង្ហាញថាសារណារយៈពេលមួយថ្ងៃហ្នឹង គឺថាខាងសហព្រះរាជអាជ្ញាបានដកស្រង់នូវពាក្យសម្ដីរបស់លោក ហ្វីលីព ស្សូត ដល់ទៅ១៧ដង។ ហើយជាថ្មីម្ដងទៀត គឺខ្ញុំបញ្ជាក់ថា គាត់គឺជាអ្នកសារព័ត៌មានអង់គ្លេសដែលមិនមានជំនាញអ្វីឲ្យបានច្បាស់លាស់នោះឡើយ។ ហើយនេះគឺបានន័យថា ពួកគេដកស្រង់ ហ្វីលីព ស្សូត មួយដងក្នុងរយៈ១៧នាទី។ បានន័យថា១៧នាទីដកម្ដង នៅក្នុងការបកស្រាយរបស់ពួកគេ។ ដូច្នេះ ការពឹងផ្អែកទៅលើប្រភពទី២ ចំពោះឲ្យការពឹងផ្អែកទៅលើប្រភពឯកសារផ្ទាល់ ហើយនិងសក្ខីកម្មជាលក្ខណៈផ្ទាល់នោះ គឺជាការប៉ះពាល់ទៅដល់ការព្យាយាមរបស់គេ ក្នុងការបកស្រាយទៅលើទ្រឹស្ដីអំពីបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះហើយ គឺថាការធ្វើបែបនេះ គឺបានន័យថា ធ្វើឲ្យតុលាការព្រមទទួលយកការវិភាគ

របស់អ្នកនិពន្ធដែលមិនបានដឹងច្បាស់លាស់អំពីតុលាការ។ គ្រោះថ្នាក់សំខាន់ដែលត្រូវបានបង្ហាញនៅក្នុងសំណុំរឿងដោយសារតែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ គឺការកំណត់ឲ្យមានជាអ្នកជំនាញដែលមានសូវដឹងច្បាស់អំពីបក្សកុម្មុយនីស្ដកម្ពុជា។ លោកស្រី អេលីហ្សាប៊ែត បេកឃ័រ, លោក ហ្វីលីព ស្សូត គឺត្រូវបានគេចាត់ថា ជាអ្នកជំនាញ។ ប៉ុន្តែជាអ្នកសារព័ត៌មានដែលមិនចេះភាសាខ្មែរ ហើយមិនមានលក្ខណៈពិសេសខាងបណ្ឌិតសភាអ្វីទាំងអស់។ ពួកគេបានសរសេរសៀវភៅរួមគ្នាចំនួនពីរ ហើយនិងអត្ថបទសារព័ត៌មានជាច្រើនទាក់ទងទៅនឹងប្រទេសកម្ពុជា។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបដិសេធមិនកោះហៅលោក ម៉ៃខល វីកឃើរី ដែលជាសាស្ត្រាចារ្យដែលចេះភាសាខ្មែរ ទាំងនិយាយ ទាំងសរសេរច្បាស់លាស់ ហើយមកដល់ប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៦១ ហើយបាននិពន្ធនូវអត្ថបទសិក្សាស្រាវជ្រាវជាច្រើនអំពីកម្ពុជា និងខ្មែរក្រហម។

[០៩:៤៤:៣៧]

តាមរយៈលោក ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍ គឺថាគុណវិបត្តិមួយរបស់ វីកឃើរី គឺថាគាត់ជាជនកុម្មុយនីស្ត។ ហ្គារេត ផតធ័រ និង វីល្លៀម សក្រូស ព្រមទាំងសាក្សីអ្នកជំនាញដទៃទៀត ដែលមេធាវីការពារក្តីស្នើសុំហ្នឹង គឺថាមិនត្រូវបានគោរពទៅតាម -- គឺត្រូវបានគេគិតថាមិនស្របទៅតាមគោលដៅ ហើយត្រូវបានបដិសេធដោយអង្គជំនុំជម្រះ។ ទោះបីជាយ៉ាងណាកក៏ដោយ គឺថាសហព្រះរាជអាជ្ញាបានប្រើប្រាស់នូវប្រភពជាច្រើន ដែលជាការអះអាងរបស់ពួកគេ។ ខ្ញុំសូមដកស្រង់មួយ សហព្រះរាជអាជ្ញាបានដកស្រង់នូវសក្ខីកម្មរបស់លោក ស៊ីដនី ស្កេនប៊ឺក*(Sydney Schanberg)* ដែលថាការបាញ់ផ្ដោងទីក្រុងភ្នំពេញ គឺជាសង្គ្រាមចិត្តសាស្ត្រ។ នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ពួកគេ ពួកគេបានបញ្ជាក់ថា លោក ស៊ីដនី ស្កេនប៊ឺក បានបដិសេធថាលក្ខខណ្ឌនៃការអត់ឃ្លាននៅក្នុងទីក្រុងភ្នំពេញមិនមែនជាហេតុផលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញទេ។ លោកប្រធាន លោក លោកស្រីចៅក្រមជាការអះអាងដ៏ខុសឆ្គងទាំងស្រុង។ ហេតុអ្វីបានជាអង្គជំនុំជម្រះចាប់អារម្មណ៍អំពីទស្សនៈរបស់លោក ស៊ីដនី ស្កេនប៊ឺក ទាក់ទងទៅនឹងចេតនារបស់បក្សកុម្មុយនីស្ដកម្ពុជា។ បន្ទាប់ពីមានការជម្លៀសភ្លាមៗ គឺមានអត្ថបទមួយនៅក្នុងសារព័ត៌មានញូវយ៉កថាមស៍ ដែលនិពន្ធដោយបុរសម្នាក់ឈ្មោះ វីល្លៀម ហ្គូដហ្វេឡូ។ ហ្គូដហ្វេឡូ បានលើកឡើងថា "ការជម្លៀសគឺដោយសារតែមូលហេតុនៃកង្វះខាតស្បៀងអាហារនៅក្នុងទីក្រុង"។ ដូច្នេះ តើយើងគួរតែដោះស្រាយបញ្ហាជម្លោះផ្នែកគតិយុត្តនេះតាមរយៈកាពិភាក្សារបស់អ្នកសរសេរព័ត៌មានញូវយ៉កថាមស៍ដែរឬទេ។ ក្នុងកន្លែងដទៃទៀត សហព្រះរាជអាជ្ញាបានអះអាង

ថា ក្នុងឆ្នាំ១៩៦០។ ប៉ុល ពត ទទួលឥទ្ធិពលយ៉ាងខ្លាំងដោយចលនាម៉ៅនិយមរបស់ចិន។ ភស្តុតាងរបស់ពួកគេ គឺការសន្និដ្ឋានរបស់អ្នកសរសេរសៀវភៅ ជនជាតិបរទេសដែលសរសេរប្រហែលជា៣០ ទៅ ៤០ឆ្នាំក្រោយហេតុការណ៍បានកើតឡើង។

[០៩:៤៦:៣២]

អ្នកនិពន្ធទាំងអស់នេះមិនអាចដឹងអំពីអ្វីជាគោលគំនិតដែលបះពាល់ទៅដល់ការគិតរបស់មនុស្ស នៅពេលណាមួយជាក់បាននោះទេ។ ការពិតដូចដែលយើងបានពន្យល់ គឺថាលោក នួន ជា មិនត្រូវបាន គេគោរពក្នុងចំណោមក្រុមទាំងបួននោះឡើយ។ គឺគាត់បដិសេធគំនិតរបស់ម៉ៅ។ ហើយការពិតទៅ គឺ គាត់គាំទ្រទៅដល់គំនិតរបស់ម៉ាក្ស-ឡេនីន ទៅវិញទេ។

លោក លោកស្រីចៅក្រមប្រសិនបើយើងធ្វើការជំនុំជម្រះបែបព្រហ្មទណ្ឌ គឺយើងអាចចំណាយ លុយយ៉ាងច្រើនសម្រាប់ជនបរទេសដែលជាអ្នកបង់ពន្ធ។ យើងប្រហែលជាមិនចំណាយអស់២០០លាន ដុល្លារសម្រាប់ចៅក្រម និងមេធាវីនោះទេ។ គឺថាសៀវភៅរបស់លោក ស្សូត គឺមានលក់នៅវេបសាយ អាម៉ាហ្សូន តម្លៃត្រឹមតែ២៤,៧៥ ប៉ុណ្ណោះ។ គឺថាបេក្ខជនទាំងប្រាំពីរ សម្រាប់ការជំនុំជម្រះដោយ ស្ទីវ ហេដឌ័រ ក៏អាចទិញបានត្រឹមតែតម្លៃ១៦,៥០ដុល្លារតែប៉ុណ្ណោះ។ ដូច្នេះយើងអាចធ្វើការជំនុំជម្រះហ្នឹង អស់ប្រហែលជា៤១ដុល្លារប៉ុណ្ណោះ។ ដូច្នេះហើយ ខ្ញុំគិតថានេះគឺជាហេតុផលដែលយើងមិនគួរធ្វើបែប នេះដោយពឹងផ្អែកទៅលើសៀវភៅរបស់អ្នកនិពន្ធតែពីរនោះទេ។

[០៩:៤៧:៤៣]

សហព្រះរាជអាជ្ញាក៏បានព្យាយាមបង្កើតនូវរឿងរ៉ាវដ៏ងាយស្រួលសាមញ្ញទាក់ទងទៅនឹងប្រវត្តិ- សាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា។ ជាឧទាហរណ៍ ពួកគេអះអាងថា មេដឹកនាំជាន់ខ្ពស់ -- មេដឹកនាំ អនាគតរបស់បក្សកុម្មុយនីស្តកម្ពុជារួមបញ្ចូលទាំង នួន ជា គឺអាននូវសៀវភៅរបស់ស្តាលីន ហើយនិង ម៉ៅ នៅពេលដែលពួកគេនៅពីក្មេង។ តើវាមានអីពាក់ព័ន្ធទាក់ទងទៅនឹងសវនាការនេះ? តើសហព្រះរាជ អាជ្ញាពឹងផ្អែកដែលថា ដោយសារមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាអានសៀវភៅរបស់ស្តាលីន នៅឆ្នាំ ១៩៥៣ ទើបធ្វើឲ្យពួកគេធ្វើអំពីដូចស្តាលីននៅឆ្នាំ៧៥អីចឹងអ្ហេះ! តើពួកគេចង់និយាយថាការពន្យល់អំពី ហេតុការណ៍នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺមិនមែនស្ថិតនៅក្នុងរយៈពេល២២ឆ្នាំនៃហេតុការណ៍ដែល បានជ្រៀតជ្រែកកើតឡើងទេ។ ប៉ុន្តែគ្រាន់តែពឹងផ្អែកទៅលើការអានរបស់លោក ខៀវ សំផន កាលគាត់ រៀននៅមហាវិទ្យាល័យហ្នឹងអីចឹង។ ដូច្នេះការអះអាងអំពីប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង

គឺហាក់ដូចខុសឆ្គង ដោយសារតែអង្គហេតុដែលព្រះរាជអាជ្ញាបានជ្រើសរើស។ ហើយក្នុងពេលជាមួយគ្នាហ្នឹង គាត់តែជ្រើសរើសយកមក តែគាត់មិនបានបញ្ជាក់ឲ្យបានច្បាស់។ សហព្រះរាជអាជ្ញានៅតែបន្តទម្លាប់របស់ពួកគេដែលថា ធ្វើពុតជាមិនដឹងថារដ្ឋាភិបាលអាមេរិកបានទម្លាក់គ្រាប់បែកទម្លាក់២លាន៥សែនតោនទៅលើប្រទេសកម្ពុជាចន្លោះពីឆ្នាំ៦៥ ដល់៧៣នោះទេ។

យើងនឹងពិភាក្សាអំពីការទម្លាក់គ្រប់បែកបន្ថែមនៅពេលក្រោយ។ ប៉ុន្តែវាមានហេតុផលច្រើនថាហេតុអ្វីបានជាបញ្ហាទម្លាក់គ្រាប់បែកនេះសំខាន់ចំពោះអង្គជំនុំជម្រះនេះ? ប៉ុន្តែឥឡូវនេះខ្ញុំចង់ធ្វើការប្រៀបធៀបរវាងព័ត៌មានដែលព្រះរាជអាជ្ញាបានគិតថា ពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាជាមួយព័ត៌មានដែលពួកគេគិតថាមិនពាក់ព័ន្ធ។ ឥឡូវនេះ យើងចាប់ផ្តើមនិយាយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងខ្មាំង។

[០៩:៤៩:៣៨]

ព្រះរាជអាជ្ញាបានប្រាប់យើងថានៅឆ្នាំ៥៣ នួន ជា អានសៀវភៅមួយដែលសរសេរដោយស្តាលីន អំពីខ្មាំង។ បន្ទាប់មកទៀតព្រះរាជអាជ្ញាបានប្រាប់យើងថា បក្សកុម្មុយនីស្តកម្ពុជាបង្កើតគោលនយោបាយមួយប្រឆាំងនឹងខ្មាំង ចន្លោះពីឆ្នាំ៦០ ដល់៧៥។ ប៉ុន្តែពួកគេបមិនបានបង្ហាញថាតើនៅក្នុងរយៈពេលប៉ុន្មានឆ្នាំដូចគ្នានេះ ថាតើអ្វីដែលគេចាត់ទុកថាជាខ្មាំងសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា គឺចក្រពិត្តអាមេរិកហ្នឹង គឺកំពុងតែធ្វើការទម្លាក់គ្រាប់បែកកាន់តែច្រើនឡើងៗទៅលើប្រទេសកម្ពុជា គឺជាចំនួនគ្រាប់បែកដែលខ្លាំងជាងចំនួនគ្រាប់បែកដែលពួកសម្ព័ន្ធមិត្តទម្លាក់នៅក្នុងសង្គ្រាមលោកលើកទី២តទៅទៀត។ សហព្រះរាជអាជ្ញាគិតថា មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាព្រួយបារម្ភអំពីចេតនាប៉ុន្តែមិនមែនដោយសារតែអាមេរិកទម្លាក់គ្រាប់បែកជាងប្រាំបីឆ្នាំនោះទេ ប៉ុន្តែដោយសារតែ ពួកគេអានសៀវភៅ ហើយឃើញថា អាមេរិកជាមនុស្សអាក្រក់ដែលគេយល់បែបនេះ។

លោកប្រធាន លោក លោកស្រីចៅក្រម! ខ្ញុំចង់ឲ្យអង្គជំនុំជម្រះធ្វើការពិចារណាជាមួយខ្ញុំអំពីការពិសោធមួយ។ ឥឡូវយើងគិតអ៊ីចេះវិញថា សហអង្គការសហប្រជាជាតិបានបង្កើតតុលាការមួយដើម្បីជំនុំជម្រះអតីតប្រធានាធិបតី ចច ដាប់ប៊ឺយូ ប៊ូស ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអ៊ីរ៉ាក់ចន្លោះឆ្នាំ២០០៣ និង ២០០៨។ ឥឡូវយើងសម័យថា ប៊ូស ត្រូវបានគេចោទប្រកាន់ដោយសារតែការប្រើប្រាស់កងកម្លាំងដែលខុសច្បាប់ព្រមទាំងការស្លាប់របស់ប្រជាជនស៊ីវិលរាប់ម៉ឺននាក់ ព្រមទាំងការឃុំខ្លួន និងការធ្វើទារុណកម្មខុសច្បាប់ចំពោះប្រជាជនរាប់ពាន់នាក់។ ឥឡូវយើងសម័យអ៊ីចេះថា មេធាវី

ការពារក្តីនៅពេលនោះបានប្រាប់ថា ព្រឹត្តិការណ៍ថ្ងៃទី១១ ខែ៩ ឆ្នាំ២០០១ គឺមិនពាក់ព័ន្ធទេ ព្រោះហេតុការណ៍នោះវាកើតឡើង១៨ខែ ក្រោយពេលចាប់ផ្តើមរបស់យុត្តាធិការពេលវេលានៃតុលាការនេះ។ តើស្តាប់ទៅវាមានន័យអត់? តើយើងយល់ថាវាជាការត្រឹមត្រូវអត់? ថាតើវាសមស្របដែលឬអត់ដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏សារណាបញ្ចប់ការពិភាក្សាដេញដោល គឺមិនបាននិយាយអ្វីអំពីហេតុការណ៍ថ្ងៃទី១១ ខែ៩ នោះ? តើវាជាការត្រឹមត្រូវដែរឬទេដែលថាជនជាប់ចោទ មិនអាចពន្យល់អំពីផលប៉ះពាល់នៅព្រឹត្តិការណ៍ថ្ងៃ១១ ខែ៩ ហ្នឹង?

[០៩:៥២:១១]

លោកប្រធាន លោក លោកស្រីចៅក្រម ការទម្លាក់គ្រាប់បែករបស់អាមេរិកក៏ធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងការបង្កើតសហករណ៍កសិកម្ម។ យោងទៅតាមព្រះរាជអាជ្ញា គោលដៅសំខាន់នៃការជម្លៀសទីក្រុងភ្នំពេញហើយនិងការបង្កើតសហករណ៍គឺដើម្បីដាក់ប្រជាជនឲ្យទៅជាទាសករនៅក្នុងប្រទេស។ ប៉ុន្តែឥឡូវនេះយើងប្រើប្រាស់ពាក្យ "ទាសករ"ទៀតហើយ។ សហព្រះរាជអាជ្ញាគិតថា ប្រសិនបើគេប្រើប្រាស់ពាក្យទាសករ ពេលនោះវានឹងក្លាយទៅជាគោលដៅរបស់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ប៉ុន្តែរដ្ឋអាជ្ញាមិនបានបង្ហាញថា ភាគច្រើននៃប្រជាជនដែលគេជម្លៀសចេញពីទីក្រុងភ្នំពេញគឺជាកសិករដែលមកពីទីជនបទហើយពួកគាត់ចង់ត្រឡប់ទៅវាលស្រែរបស់ពួកគេវិញ។ ពួកគេមិនបានបង្ហាញអំពីការពិតដែលថាប្រទេសកម្ពុជាប្រឈមនឹងគ្រោះមហន្តរាយសេដ្ឋកិច្ច ដោយសារតែការបំផ្លាញវាលស្រែ និងចំការរបស់ពួកគេព្រមទាំងការបំផ្លិចបំផ្លាញទៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ចដោយការទម្លាក់គ្រាប់បែករបស់អាមេរិក។ គឺថាយើងសឹងថាមិនអាចមើលប្រមើលឃើញអំពីគ្រោះថ្នាក់នេះ ថាតើយើងធ្វើយ៉ាងដូចម្តេចដើម្បីអាចវាយតម្លៃលក្ខណៈ និងគោលដៅរបស់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ពាក់ព័ន្ធទៅនឹងសហករណ៍កសិកម្មដែលមិនបានពិចារណាអំពីស្ថានភាពនៃការផលិតកសិកម្មរបស់ប្រទេសកម្ពុជាទៅវិញ។ តើហេតុអ្វីបានជារដ្ឋព្រះរាជអាជ្ញាហ៊ានគិតថា ពួកគេអាចកាត់បន្ថយការបង្កើតសហករណ៍ដោយគ្រាន់តែប្រើប្រាស់ពាក្យតែមួយគត់ថាជាការដាក់ឲ្យទៅជាទាសករនោះ។

[០៩:៥៣:៥៣]

លោកប្រធាន លោក លោកស្រីចៅក្រម ទាំងអស់នេះគឺវាមានលក្ខណៈមិនច្បាស់លាស់ ហើយវាគឺជាទ្រឹស្តីដែលព្រះរាជអាជ្ញាបង្ហាញដោយមិនមានលក្ខណៈច្បាស់លាស់។ គោលដៅរបស់ព្រះរាជអាជ្ញា

គឺដើម្បីធ្វើការលាបពណ៌ទៅលើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថា ជាអង្គការដែលអនុវត្តពីលើចុះមកក្រោមដែលមានកម្មាភិបាលនៅក្នុងគ្រប់ភូមិភាគទាំងអស់ ត្រូវគោរពទៅមជ្ឈិមបក្សដោយមាន នួន ជា ហើយនិង ប៉ុល ពត គឺស្ថិតនៅកំពូលនៃថ្នាក់ដឹកនាំនោះ។

សហព្រះរាជអាជ្ញាព្យាយាម មិនលើកបង្ហាញពីការពិតដែលកើតឡើងមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ គឺថាវាមានផ្នែកពីរសំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាផងដែរ។ ផ្នែកទាំងពីរនោះគឺ សោភឹម ហើយនិង រស់ ញឹម ដែលធ្វើការដឹកនាំចលនាប្រឆាំងនឹងមជ្ឈិមបក្ស។ ចលនាទាំងពីរនេះគឺព្យាយាមដើម្បីធ្វើវិទ្ធង្សនាចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីការជម្លៀសប្រជាជនចេញពីទីក្រុងត្រូវបានបញ្ចប់មកម្ល៉េះ។ គោលដៅ -- បញ្ហាសំខាន់នៃការក្បត់របស់សមាជិកទាំងអស់នេះ គឺត្រូវបានគាំទ្រដោយវៀតណាម ហើយបន្ទាប់មកត្រូវបានគាំទ្រនិងដោយរដ្ឋាភិបាលកម្ពុជាទី១ ទី២ និងទី៣ ហើយហេតុការណ៍ទាំងអស់នេះ ទើបតែគេដឹងនៅក្នុងឆ្នាំ៧៧ ឬក៏៧៨ ប៉ុន្តែហេតុការណ៍ទាំងអស់នេះកើតឡើងមុនពេលនេះមកម្ល៉េះ។

[០៩:៥៥:២៨]

ជាជាងការបង្កើត -- ព្យាយាមបង្ហាញថា អ្វីដែលកើតឡើងពិតប្រាកដនៅក្នុងប្រទេសកម្ពុជានោះ ព្រះរាជអាជ្ញាបានព្យាយាមចោទប្រកាន់ ប៉ុល ពត ហើយនិង នួន ជា ថាមានការភ័យខ្លាចដែលថាមានការបារម្ភខ្លាំងក្លាពេកជាមួយនឹងខ្លាំង ហើយនិងទ្រឹស្តីនៃការក្បត់ ប៉ុន្តែមិនមានសំណួរធ្ងន់ច្បាស់លាស់ថា តើលេខា រស់ ញឹម ហ្នឹងគឺវាមានលក្ខណៈជាមនុស្ស ជាមេដឹកនាំភូមិភាគដែលធ្ងន់ៗសាហាវប៉ុនណា។ ហើយការប្រព្រឹត្តរបស់គាត់ គឺឃ្លាតឆ្ងាយយ៉ាងខ្លាំងពីចេតនារបស់ ប៉ុល ពត និង នួន ជា ហើយក៏មិនមានការសួរនាំថា តើ ប៉ុល ពត ព្រួយបារម្ភបែបណាចំពោះ សោ ភឹម។ ប៉ុល ពត ភ័យខ្លាចសូម្បីតែចូលទៅភូមិភាគបូព៌ាក៏មិនហ៊ានទៅផង។ នួន ជា បានសង្កត់ធ្ងន់ថា សោ ភឹម ហើយនិង រស់ ញឹម គឺមិនគ្រាន់តែជាស្តេចត្រាញ់ស្វយ័តនោះទេ។ ព្រះរាជអាជ្ញាគ្រាន់តែបញ្ជាក់ដោយមិនច្បាស់លាស់អំពីតួនាទីរបស់ នួន ជា កាលពីសប្តាហ៍មុន។ ពាក្យថា “ស្តេចត្រាញ់” គឺលើកមកបង្ហាញតែម្តងគត់នៅក្នុងសារណារបស់ពួកគេ។ ប៉ុន្តែវាមិនបានជាការប្រើប្រាស់របស់ព្រះរាជអាជ្ញា ដើម្បីរៀបរាប់ពី នួន ជា ទេ ប៉ុន្តែជាការរៀបរាប់ដែលប្រើប្រាស់ដោយសាក្សី និងអ្នកជំនាញដែលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះ។ វាប្រាកដណាស់ថា មេដឹកនាំភូមិភាគ គឺត្រូវបំពេញការងារដោយស្វ័យភាព ប៉ុន្តែអ្វីដែលសំខាន់បំផុត គឺទាក់ទងទៅនឹង រស់ ញឹម ហើយនិង សោ ភឹម។

[០៩:៥៧:០០]

ការពិតសំខាន់អំពី រស់ ញឹម និងសោ ភឹម គឺថា ពួកគេធ្វើការ -- គឺពួកគេគឺសមាជិកដែលបង្កើតបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែពួកគេជំទាស់យ៉ាងខ្លាំងក្លាទៅនឹង ប៉ុល ពត ហើយនិង នួន ជា គឺដំបូងជំទាស់ដោយសម្ងាត់ទេ ប៉ុន្តែក្រោយមកជំទាស់ដោយចំហ។ ការពិតសំខាន់អំពី រស់ ញឹម ហើយនិង សោម ភឹម គឺថាបក្សកុម្មុយនីស្តកម្ពុជាមិនមែនជាស្ថាប័នមួយដែលមានការឯកភាពគ្នាតែមួយនោះទេ។ ជម្លោះផ្ទៃក្នុងបានបំផ្លាញបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែមិនមែនតែដោយសារតែការភ័យខ្លាចរបស់ ប៉ុល ពត នោះឡើយ។ ការពិតទៅការភ័យខ្លាចរបស់ ប៉ុល ពត គឺជាប្រតិកម្មត្រឹមត្រូវចំពោះអ្វីដែលបានកើតឡើងនៅក្នុងការគ្រប់គ្រង។ ពួកវៀតណាម ហើយនិងចុងក្រោយការចូលរួមផ្ទាល់របស់រដ្ឋាភិបាលវៀតណាម គឺជាសមាសភាពដ៏សំខាន់នៃការតស៊ូនេះ។ ការរៀបរាប់ដ៏សាមញ្ញរបស់សហព្រះរាជអាជ្ញាអំពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា គឺវាមានលក្ខណៈច្បាស់លាស់នៅក្នុងការប្រើប្រាស់ពាក្យថា "ប្រជាធិបតេយ្យប្រមូលផ្តុំ"។ ព្រះរាជអាជ្ញាបានប្រើប្រាស់ពាក្យដដែលៗដោយព្យាយាមដាក់បញ្ចូលទាំងលោក នួន ជា និងលោក ខៀវ សំផន ទៅក្នុងក្រោមឆ័ត្ររួមគ្នានៃការធ្វើសេចក្តីសម្រេចរួម ដែលធ្វើដោយគណៈអចិន្ត្រៃយ៍ ប៉ុន្តែការប្រើប្រាស់ពាក្យហ្នឹងបង្ហាញថា មិនមានអ្វីច្បាស់លាស់ពាក់ព័ន្ធទៅនឹងរដ្ឋាភិបាលដែលបង្កើតឡើងដោយមនុស្ស មិនមែនគ្រាន់តែជាការបង្កើតដោយឯកសារនៅលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានោះឡើយ។

[០៩:៥៨:៣៨]

សហព្រះរាជអាជ្ញាទំនងជាជឿជាក់ថា គឺមានទំនាក់ទំនងផ្ទាល់រវាងសេចក្តីសម្រេចដែលធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ ហើយនិងអំពើនៃកម្មាភិបាលម្នាក់ៗគ្រប់ទីកន្លែងនៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ។ នោះវាអាចនឹងជាការពិតនៅក្នុងប្រព័ន្ធទំនើបដែលមានរចនាសម្ព័ន្ធរដ្ឋបាល ដូចជា: អូស្ត្រាលី បារាំង ញូវហ្សេឡែន ប៉ុន្តែវាមិនច្បាស់ទេ នៅក្នុងរដ្ឋបដិវត្តន៍នុំង គឺថាអាចនឹងបន្សល់ទុកនៅ មានការបែងចែកដូចជាកម្ពុជាប្រជាធិបតេយ្យ។ ការយល់ស្របទៅលើគោលនយោបាយអរូបី អនុលោមតាមគោលការណ៍អរូបី ដូចជាប្រជាធិបតេយ្យប្រមូលផ្តុំ ហើយការផ្សាភ្ជាប់ទៅនឹងអំពើរបស់ប្រជាជននោះទៅតាមឋានានុក្រមរបស់គេ។ សហព្រះរាជអាជ្ញាចាត់ទុកប្រជាធិបតេយ្យប្រមូលផ្តុំហ្នឹង គឺថាជាការមិនស្មោះត្រង់ ប៉ុន្តែម្យ៉ាងទៀត គឺថាសមាជិកទាំងអស់នៃគណៈអចិន្ត្រៃយ៍ គឺស្មើ -- ជាអ្នកចូលរួមស្មើគ្នាក្នុងការធ្វើសេចក្តីសម្រេច ប៉ុន្តែ នួន ជា ជាទូទៅ -- សូមដកស្រង់៖ "ថាចេញបញ្ហា ហើយនិងសេចក្តីណែនាំ"

(សូមដកស្រង់) ទៅមេដឹកនាំភូមិភាគដូចជា សោ ភឹម រស់ ញឹម នោះ។ ដូចដែលខ្ញុំបានបញ្ជាក់ហ្នឹង គឺថា គឺមិនមែនជាសមាជិកធម្មតាទេ គាត់ជាសមាជិកគណៈអចិន្ត្រៃយ៍ផងដែរ អ្នកទាំងនោះ។ សហព្រះរាជអាជ្ញាមិនអាចប្រើគំនិតទាំងពីរបានទេ ពួកគេមិនអាចដាក់ ខៀវ សំផន, នួន ជា, ប៉ុល ពត ដោយផ្អែកលើថាគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ប៉ុន្តែបញ្ជាក់ថា រស់ ញឹម និង សោ ភឹម គោរពតាមបញ្ជារបស់គាត់ជារៀងរហូតនោះទេ។

[១០:០០:២៦]

ការសេចក្តីសន្និដ្ឋានទៅតាមឋានុក្រមបក្សកុម្មុយនីស្តកម្ពុជានេះគឺ មិនស្របគ្នាទេនៅក្នុងការអះអាងរបស់សហព្រះរាជអាជ្ញាថា មិនមានរចនាសម្ព័ន្ធពិតប្រាកដរបស់រដ្ឋាភិបាល របស់កម្ពុជាប្រជាធិបតេយ្យ។ គេនិយាយថាមិនមាន មិនមានក្រសួង មិនមាននីតិបញ្ញត្តិ ហើយមិនមានយន្តការរដ្ឋាភិបាល។ ប៉ុន្តែគឺយន្តការទាំងអស់នៃរដ្ឋាភិបាលនោះ មានការទទួលខុសត្រូវក្នុងការការធានានូវការអនុវត្ត ហើយនិងការណែនាំច្បាប់ទម្លាប់ ដូចជានៅក្នុងរដ្ឋបស្ចិមប្រទេសនោះទេ។

នៅកម្ពុជាប្រជាធិបតេយ្យ លទ្ធផលគឺមិនកំណត់ដោយរចនាសម្ព័ន្ធទេ ហើយក៏មិនកំណត់ដោយលក្ខន្តិកៈបក្សដែរ គឺវាកំណត់ដោយតុល្យភាពនៃអំណាចនៅក្នុងបក្ស។ សហព្រះរាជអាជ្ញានឹងធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា ប៉ុល ពត និង នួន ជា បានមានអំណាចដ៏ពិតប្រាកដនៅក្នុងកម្ពុជាប្រជាធិប-តេយ្យ។ ផ្ទុយទៅវិញ មិនមានភស្តុតាងបញ្ជាក់ និងគាំទ្រគំនិតនេះទេ ដូចដែលបញ្ជាក់នៅក្នុងសារណារបស់យើង គឺថាមានអង្គហេតុសំខាន់មួយដែលច្បាស់ ដែលថាសេចក្តីភ័យខ្លាចរបស់លោក ប៉ុល ពត គឺថាអាចនឹងបង្កឡើង។ គឺថាវាកើតឡើងដោយសារពួកគេមានការភ័យខ្លាចថាអាចនឹងមាន នួន ជា យល់ថាអាចនឹងត្រឹមត្រូវ ដែលថាប្រកាសប្រាប់សមាជិកនៅគណៈអចិន្ត្រៃយ៍នៅខែមីនា ឆ្នាំ១៩៧៦ ថាគាត់ថា៖ "ឲ្យប្រុងប្រយ័ត្នចំពោះអ្វីដែលថាអ្នកដែល -- ចំពោះអ្នកដែលរត់ទៅវៀតណាម ហើយបានត្រឡប់មកវិញ ហើយធ្វើការឃោសនា នាំអ្នកផ្សេងទៀតឲ្យធ្វើការបះបោរ"។ សូមបញ្ចប់ការដកស្រង់។

[១០:០២:១២]

ដូចដែលយើងបានបញ្ជាក់នៅក្នុងសារណារបស់យើង គឺភស្តុតាងច្បាស់បំផុតរបស់បក្សកុម្មុយ-នីស្តកម្ពុជាហ្នឹង គឺបានបែងចែកទៅក្នុងភាគីមួយចំនួន គឺនៅពេលដែលមានវិវាទ។ ដូចជាការធ្វើសង្គ្រាមដែលកើតឡើងនៅភូមិភាគផ្សេងៗ ស្ទើរតែពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ សោ ភឹម ត្រូវបានបោសសម្អាត, រស់ ញឹម ត្រូវបានបោសសម្អាត, វន វ៉េត ត្រូវបានបោសសម្អាត, កុយ ធួន ត្រូវបាន

បោសសម្អាត។ ហេតុអ្វីបានជាការចាំបាច់ដែលថា នួន ជា និង ប៉ុល ពត អាចនឹងធ្វើការអនុវត្តនូវការត្រួតត្រាទៅលើរដ្ឋាភិបាល គ្រឿងម៉ាស៊ីនរបស់រដ្ឋាភិបាលនេះបាននោះ។

លោកប្រធាន នៅតាមវិធីនេះ សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានបន្តថា បន្តប្រាប់នូវសេចក្តីសន្និដ្ឋានដោយឆោតល្ងង់ ដោយសាមញ្ញ ដោយលម្អៀង ហើយដោយផ្តាំផ្តួងអំពីកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែផ្ទុយទៅវិញការខកខាននេះ គឺថាមិនមានតម្លៃទេ ការខកខាននេះគឺថាអាចនឹងធ្វើឱ្យមានការភ័ន្តច្រឡំ ការមិនដឹងមិនឮពីយុត្តិធម៌។ ប៉ុន្តែមានអ្វីដែលលើសពីនេះទៅទៀត ដែលថាសំខាន់ក្នុងការងារនេះ។ ការដឹងពីកិច្ចប្រឹងប្រែងភាគីចូលរួមនៃសាលាក្តីនេះ គឺថាអាចនឹងបន្ទោសលើអ្នកផ្សេងឱ្យទទួលខុសត្រូវលើការឈឺចាប់របស់ប្រជាជន ចំពោះ -- ដោយទុកដាក់ទៅលើតែជនជាប់ចោទពីរនាក់ដែលនៅទីនេះ។ ហើយមានទិសដៅជាច្រើនដែលថា មិនទាន់បានកំណត់ពីពិរុទ្ធភាពរបស់អ្នកទាំងអស់នោះទេ ដូចជាពួកអាមេរិកាំង ស្តេចសីហនុ លន់ នល់ និងពួកបារាំង។ ប៉ុន្តែយើងដឹងច្បាស់ថា ពាក្យថាភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការជំនុំជម្រះនេះមួយ គឺថា គឺមានអ្នកខ្លះខ្ពស់ជាងអ្នកផ្សេងទៀត។ ទិសដៅនោះគឺថាតាមពិតគឺមេដឹកនាំជាន់ខ្ពស់នៃបក្សប្រជាជនកម្ពុជា ដែលបន្តការលួចការបោះឆ្នោត ដីធ្លី ហើយនិងធនធានធម្មជាតិពីប្រជាជន ហើយពួកក៏បានប្រើតួនាទីដ៏សំខាន់នៅក្នុងហេតុការណ៍ដែល នួន ជា ដែលទទួលការចោទប្រកាន់នេះ។

[១០:០៤:៣៦]

ប្រសិនបើកម្ពុជាប្រជាធិបតេយ្យជាសហឧក្រិដ្ឋកម្មដ៏ធំនោះ ដែលគោលបំណងសំខាន់ដើម្បីដាក់ប្រជាជនខ្មែរឱ្យទៅជាទាសករ តើមេដឹកនាំបីនាក់សំខាន់ៗនៃរដ្ឋាភិបាលបច្ចុប្បន្ននេះមានការទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយនោះដែរទេ? គោលដៅនោះទេ? នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រធានព្រឹទ្ធសភា ជា ស៊ីម និងប្រធានរដ្ឋសភា ហេង សំរិន ក៏បានចូលរួមក្នុងការតួនាទីអនុវត្តគោលនយោបាយដែលសហព្រះរាជអាជ្ញានិយាយថាជាគោលនយោបាយឧក្រិដ្ឋនោះដែរ។ មិនមានការសង្ស័យអ្វីទេ នេះជាការពិតយ៉ាងច្បាស់លាស់។ ប៉ុន្តែបុរសទាំងអស់នេះ គឺអាចមានការលាក់ខ្លួនអំពីការទទួលខុសត្រូវការចោទប្រកាន់ ហើយទុកផ្តាក់ការទទួលខុសត្រូវមកលើលោក នួនជា។ ប្រសិនបើលោក នួន ជា ទទួលពិរុទ្ធភាព អ្នកទាំងនោះក៏មានពិរុទ្ធភាពដែរ។ ប្រសិនបើ នួន ជា ដាក់ប្រជាជនឱ្យទៅជាទាសករ ហើយបុរសទាំងបីនាក់នេះក៏បានធ្វើដូច្នោះដែរចំពោះអ្វីៗដែលពួកគេបានអនុវត្តនៅទីក្រុងភ្នំពេញ។ ការបញ្ជាក់ជាពិសេសអំពីតួនាទីរបស់ ហេង សំរិន ដែលមានតួនាទីក្នុងការអនុវត្តការជម្លៀសទីក្រុងភ្នំពេញ

ដែលជាលក្ខណៈពិសេស ដូចដែលយើងបញ្ជាក់ម្តងហើយម្តងទៀត គាត់ជាយោធាជាន់ខ្ពស់ម្នាក់ដែលរស់នៅដល់ថ្ងៃនេះ ហើយបានចូលរួមនៅក្នុងការជម្លៀសទីក្រុងភ្នំពេញ។ គាត់ជាអ្នកអនុបញ្ជាការនៃកងពលមួយក្នុងកងពលទាំងបី នៅក្នុងភូមិភាគបូព៌ា។

[១០:០៦:១១]

ដោយសាមញ្ញគឺថាក្នុងចំណោមមេដឹកនាំខ្មែរក្រហមជាង២០នាក់ដែលបានចូលរួមក្នុងការអនុវត្តការជម្លៀសនោះ គាត់បានមកដល់វិមានឯករាជ្យក្នុងគោលបំណងមួយ នៅម៉ោងប្រាំបួនព្រឹក នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ដូចជាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដែរ អង្គភាពទាំងអស់នេះ គឺត្រូវបានថា ហើយគេបានឃើញថា គួរឲ្យចាប់អារម្មណ៍ ដើម្បីសន្និដ្ឋានថាអង្គហេតុទាំងអស់នេះ គឺមិនពាក់ព័ន្ធទេ។ ប៉ុន្តែហើយមិនត្រូវធ្វើឲ្យយើងភាន់ច្រឡំនោះទេ។ ការសមគំនិតដោយច្បាស់លាស់អំពីបទឧក្រិដ្ឋរបស់មេដឹកនាំរដ្ឋាភិបាលបច្ចុប្បន្ននៅក្នុងបទឧក្រិដ្ឋដែលចោទចំពោះ នួន ជា នោះ គឺមានសារៈសំខាន់ៗណាស់ចំពោះលោក នួន ជា។ ដូចដែលយើងបានបញ្ជាក់ខាងដើម គឺការទទួលខុសត្រូវរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ហើយបានត្រូវបានបញ្ចប់ ហើយនិងត្រូវបានលុបបំបាត់ដោយកម្មាភិបាលថ្នាក់ក្រោម។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ហេង សំរិន ជាមួយលោក ជា ស៊ីម ហើយនិងនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយនិងមនុស្សរាប់រយមួយទៀត គឺពាក់ព័ន្ធជាក់លាក់ទៅនឹងលោក នួន ជា ដែលជាការទទួលខុសត្រូវក្នុងការដែលកើតឡើង ហើយការទទួលខុសត្រូវដែលត្រូវលុបបំបាត់ពី នួន ជា។ ហើយដោយមូលហេតុនេះហើយ ការជ្រៀតជ្រែករដ្ឋាភិបាលលើការជំនុំជម្រះនេះ គឺធ្វើឲ្យយើងមានការបដិសេធ ហើយគួរឲ្យការបដិសេធ ហើយបុគ្គលទាំងអស់នេះ ដែលមាន ដែលប៉ះពាល់ដល់ឯករាជ្យភាពដល់តុលាការនេះ ហើយមានការទទួលខុសត្រូវដោយសារគេជាមេដឹកនាំរបស់បក្ស ដូចគ្នានឹងបុគ្គលដែលមានលទ្ធភាពនៅក្នុងភស្តុតាងទាំងឡាយដែលបានដាក់ជូនសាលាក្តីនេះ។

[១០:០៨:១១]

រដ្ឋាភិបាលរបស់រដ្ឋាភិបាលនេះ គឺថាមិនបានរក្សាជាការសម្ងាត់ទេ នាយករដ្ឋមន្ត្រីបានជំទាស់ជាចំហអំពីការស៊ើបអង្កេត ការទទួលខុសត្រូវរបស់អ្នកផ្សេងទៀត នៅក្នុងរឿងក្តី០០២នោះ។ គាត់បានស្បថថា មិនឲ្យមានការជម្លៀស -- ការធ្វើការស៊ើបអង្កេតនូវរឿងក្តី០០៤ទេ។ តើសាលាក្តីនេះ ចង់បានអ្វីដើម្បីវាយតម្លៃព្រហ្មទណ្ឌកូនក្តីរបស់ខ្ញុំបាន? តើសាលាក្តីនេះ អាចនឹងមានសេចក្តីទុកចិត្ត ឬក៏ថាមាន

ការយល់ត្រឹមត្រូវអំពីការទទួលខុសត្រូវរបស់កម្មាភិបាលដែលអាចនឹងរាយការណ៍ នួន ជា ទេ? តើអង្គជំនុំជម្រះនេះ អាចសន្និដ្ឋានអំពីអំពើឧក្រិដ្ឋរបស់កម្មាភិបាលដែលទាបជាង នួន ជា ដែលស្របទៅជាមួយ ហើយមិនផ្ទុយទៅនឹងចេតនារបស់គាត់ដែរឬទេ?

លោក លោកស្រីចៅក្រម លោកប្រធាន នេះជាគំនិតទូទៅដែលយើងនឹងត្រូវនិយាយឲ្យបានច្បាស់នៅក្នុងការជំនុំជម្រះនេះ។ នេះជាមូលហេតុទាំងឡាយដែលសវនាការទាំងអស់នេះ គឺមានការបរាជ័យធ្ងន់ណាស់ ក្នុងការពិនិត្យអំពីការទទួលខុសត្រូវរបស់កូនក្តីខ្ញុំ ការការពារខ្លួនរបស់គាត់នៅក្នុងលក្ខណៈសារធាតុ។ ប៉ុន្តែដែលខ្ញុំបានបញ្ជាក់នៅក្នុងសារណារបស់ខ្ញុំ វាជារូបភាពទូលំទូលាយ ការខកខាននឹងដំណើរការនីតិវិធីនេះ គឺមានផលប៉ះពាល់ដ៏អាក្រក់បំផុត និងធំធេងណាស់នៅក្នុងការស៊ើបអង្កេតដូចជាការស៊ើបអង្កេត ហើយខុសឆ្គងនោះ ក៏បន្តនៅក្នុងដំណើរការសវនាការនេះដែរ។

[១០:០៩:៤៥]

ខ្ញុំនឹងចាប់ផ្តើមអំពីការស៊ើបអង្កេត។ បញ្ហាជាសំខាន់ទាក់ទងទៅនឹងការស៊ើបអង្កេតក្នុងរឿងក្តី ០០២នោះ គឺមិនបានផ្តោតអារម្មណ៍ទៅលើការស្វែងរកការពិតក្នុងការប្រមូល។ ផ្ទុយទៅវិញ គឺប្រមូលតែភស្តុតាងដាក់បន្ទុក។ សហចៅក្រមស៊ើបអង្កេត គឺមិនស្ថិតនៅក្នុងលក្ខណៈសារធាតុ ការពិតនៅក្នុងការស្វែងរកជាអ្នកវិនិច្ឆ័យនោះទេ។ ការស៊ើបអង្កេតគឺដឹកនាំដោយនីតិវិធីដែលប្រឆាំងនឹងជនជាប់ចោទ ហើយគោលបំណងតែមួយគឺដើម្បីផលិតនូវភស្តុតាងដែលដាក់បន្ទុកតែប៉ុណ្ណោះ។ យើងត្រូវតែមើលឲ្យឆ្ងាយទៅលើការចោទប្រកាន់របស់ វេន បាស្ទីន *(Wayne Bastin)* សហចៅក្រមស៊ើបអង្កេតដែលនិយាយអំពីលោក ម៉ាស្សែល ឡឺមុងដ៍ ដែលថាគាត់ណែនាំឲ្យធ្វើការស៊ើបអង្កេតតែភស្តុតាងដាក់បន្ទុកដើម្បីបង្ហាញឲ្យឃើញពីភស្តុតាងមួយចំនួន។ នេះជាកំហុសមួយ។ ចៅក្រម ឡឺមុងដ៍ ក៏បានបដិសេធដែលថាគាត់មិនបាននិយាយទេ គាត់បាននិយាយគ្រាន់តែជារឿងភ្លាត់មាត់ កំប្លែងតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ គឺថា ហើយធ្វើឲ្យលោកចៅក្រម ឡឺមុងដ៍ លាលែងពីតំណែងរបស់ខ្លួន។ ការស៊ើបអង្កេតទាំងអស់នេះ គឺបានធ្វើឡើងដោយមានលក្ខណៈមិនគ្រប់គ្រាន់ ហើយដីកាដំណោះស្រាយក៏បានផ្អែកលើចំណុចដ៏អាក្រក់ទាំងអស់នោះ។ កំហុសឆ្គងក្នុងការស៊ើបអង្កេតនោះ គឺស្ថិតនៅក្នុងការធ្វើជាការសម្ងាត់ វាខុសពីទម្លាប់អនុវត្តរបស់ប្រព័ន្ធស៊ីវិលឡូ។ មេធាវីការពារក្តីត្រូវបានដកចេញពីដំណាក់កាលស៊ើបអង្កេត។ មានការហាមឃាត់មិនឲ្យយើងធ្វើការស៊ើបអង្កេតដោយខ្លួនឯងបានទេ។ ទោះបីជាមានលទ្ធភាពរបស់សហព្រះរាជអាជ្ញានឹងធ្វើដូច្នេះក៏ដោយ។

[១០:១១:៤៤]

ច្រើនជាងពីរឆ្នាំនៃការស៊ើបអង្កេតបីឆ្នាំ សហចៅក្រមស៊ើបអង្កេតមិនបានផ្ដល់ព័ត៌មានជាមូលដ្ឋានអំពីការណែនាំជាទូទៅ ហើយនិងយុទ្ធសាស្ត្រនៃការស៊ើបអង្កេត ឬក៏បែបបទនៃការអនុវត្តរបស់អ្នកស៊ើបអង្កេតនោះទេ។ មេធាវីការពារក្ដីបានទទួលការណែនាំឲ្យរងចាំនៅពេលដែលសហចៅក្រមស៊ើបអង្កេត ហើយនិងបន្ថែមបទសម្ភាសន៍ទៅក្នុងសំណុំរឿង។ តាមវិធីដែលជាផលប្រយោជន៍ ហើយជាលក្ខណៈនៃការរៀបរាប់អំពីប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា ឬអំពីតួនាទី ហើយនិងការទទួលខុសត្រូវរបស់លោក នួន ជា ជាកូនក្ដីខ្ញុំ។ នៅព័ត៌មានមូលដ្ឋានដែលទាក់ទងទៅនឹងដំណើរការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបង្ហាញឃើញនោះ យើងមើលឃើញថាឯកសារទាំងនោះមិនបានបំពេញទៅតាមគោលការណ៍នៃការស៊ើបអង្កេតដោយសេរី និងដោយអព្យាក្រិត្យនោះទេ។ វិធីសាស្ត្រស៊ើបអង្កេតនោះគឺថា ពិនិត្យមើលតែសំបកក្រោយនៃចម្លើយសាក្សី មិនបានលម្អិត។ គោលបំណងដែលបានសួរនោះ គឺថាមិនបានដេញដោលប្រភពនៃការដឹងរបស់សាក្សី ហើយនិងអំពីការចងចាំរបស់សាក្សីក្នុងរយៈពេល៣០ឆ្នាំទេ។ បន្តទៅទៀតការវិភាគនោះគឺថា អ្នកស៊ើបអង្កេតមិនបានប្រើវិធីការពារដើម្បីចៀសវាងសំណួរនាំមុខ ហើយនិងការស្វែងរកមានភាពជឿជាក់នៃចម្លើយនោះទេ។ ភាពមិនប្រក្រតីជាច្រើនដែលនៅក្នុងកំណត់ហេតុនោះគឺថាមានភាពមិនត្រឹមត្រូវក៏បានបង្ហាញនៅក្នុងចម្លើយសារភាពទាំងអស់នោះដែរ។

[១០:១៣:២៣]

លោកប្រធាន ការខ្វះចន្លោះនៅក្នុងដីកាដំណោះស្រាយនោះ គឺថាមិនអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដីកាដំណោះស្រាយគឺមិនមានលក្ខណៈជាឯកសារតុលាការទេ ដែលបង្ហាញពីសមតុល្យនៃភាពដែលរកឃើញ។ ប៉ុន្តែផ្ទុយទៅវិញគឺជាការទទ្បីករណ៍ដែលគាំទ្រការចោទប្រកាន់ពិរុទ្ធភាពលោក នួន ជា ទៅវិញ។ ពាក្យថា "ភាពគួរជឿជាក់បាន" មិនដែលមានឃើញទេ ហើយដីកាដំណោះស្រាយនោះក៏មិនបានផ្ដល់ភស្តុតាងផ្ទុយដើម្បីទាញយកសេចក្ដីសន្និដ្ឋាននោះទេ។ ដីកានេះបានបញ្ជាក់ការអះអាងអំពីអង្គហេតុដោយផ្អែកទៅលើសាក្សីតែមួយចំនួនតូចដែលមិនមានតួនាទីអ្វីដែលនឹងអាចបញ្ជាក់ពីបញ្ហានោះបានផង។ សហចៅក្រមស៊ើបអង្កេតក៏មិនបានអនុវត្តការងារក្នុងឋានៈជាអ្នកស៊ើបអង្កេតនោះទេ ប៉ុន្តែពួកគេបានប្រមូលភស្តុតាងដើម្បីគាំទ្រពិរុទ្ធភាពទៅវិញ។ ឧទាហរណ៍បែបនេះគឺមានច្រើនណាស់។

[១០:១៤:៣០]

ការព្រួយបារម្ភមួយដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញនោះ គឺថា គឺការចោទប្រកាន់ពីបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃ។ ទីតាំងបទឧក្រិដ្ឋដែលថា វាត្រូវតែមានការវិភាគដេញដោលឲ្យបានច្បាស់លាស់នៅ អ.វ.ត.ក។ មេធាវីការពារក្តីបានបង្ហាញស្ទើរតែការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតនោះគឺមិនមានការគាំទ្រ មិនអាចប្រើជាភស្តុតាងបានទេដូចដែលបានបញ្ជាក់នៅក្នុងឯកសារលេខយោង។ ដើម្បីបញ្ជាក់ឧទាហរណ៍មួយឡើងវិញ អ្នកស៊ើបអង្កេតបានផ្តល់ការប៉ាន់តម្លៃអំពីចំនួនមនុស្សដែលគេចោទថាមានការសម្លាប់នៅទួលពោធិជ្រៃ ដែលគេនិយាយថា ២០០ ទៅ ៣០០០នាក់។ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើប អង្កេតបញ្ជាក់អំពីរបាយការណ៍ពិនិត្យទីកន្លែងគឺថាការកាប់សម្លាប់ពីរបីរយនាក់ ២០០នាក់ ឬក៏ ១០០០នាក់ឬក៏លើសពីហ្នឹង។ ប៉ុន្តែដីកាដំណោះស្រាយនិយាយថា សាក្សីបានបញ្ជាក់ថាជនរងគ្រោះពី ២០០០នាក់ ទៅប្រហែល ៣០០០ នាក់ដែលគាត់បានឃើញសាកសព។ ការព្រួយបារម្ភមួយទៀត អំពីការជឿជាក់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹងគឺចម្លើយរបស់ ឌុច ដើម្បីគាំទ្រទៅនឹងជំហរដែលគេមិនអាចរកអ្វីបានអំពីការដឹងនៅក្នុងរយៈពេលនោះ មានដាក់បញ្ចូលទាំងការអះអាងអំពីហេតុការណ៍នៅក្នុងគណៈកម្មាធិការដែលមានការសម្ងាត់ខ្ពស់បំផុត ហើយនិងការទំនាក់ទំនងរវាងមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ស្ទើរតែគ្មានអ្នកណាម្នាក់ដែលអ្នកទាំងនោះដែលអ្នកស៊ើបអង្កេតបានជួបទេ។ ហើយសហចៅក្រមស៊ើបអង្កេតក៏មិនបានគិតថា ឌុច ជាសាក្សីសមស្របទាក់ទងនឹងហេតុការណ៍នេះដែរឬទេ? រហូតមកទល់ខែមករា ឆ្នាំ២០១៣ នៅពេលដែលចៅក្រម ឡឺម៉ុងដ៍ ទទួលស្គាល់ជាសាធារណៈថា ការធ្វើការរបស់គាត់នៅ អ.វ.ត.ក គាត់បានសួរសំណួរខ្លួនឯងបែបនេះ។

[១០:១៦:៣៧]

នៅក្នុងដីកាដំណោះស្រាយបានធ្វើសេចក្តីសន្និដ្ឋានដែលផ្តល់អាក្រក់ជាច្រើនដែលផ្អែកលើមូលដ្ឋានដែលសាក្សីដែលមិនគួរទុកចិត្តបានយ៉ាងច្បាស់លាស់។ ការចោទប្រកាន់ថាកូនក្តីរបស់ខ្ញុំបានសម្រេចនិងការបោសសម្អាតនៅក្នុងយោធា ហើយនិងអ្នកដែលស្ថិតនៅក្នុងកម្មវិធីអនុវត្តការបោសសម្អាតដែលគាំទ្រដោយយោធាផ្សេងទៀត ដូចដែល សួង ស៊ីគឿន ពន្យល់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ គាត់មិនបានដឹងអ្វីទេអំពីមេដឹកនាំបក្ស។ ដីកាដំណោះស្រាយដែលនិយាយអំពី នង សុផង់ ជាអ្នកបកប្រែទូរលេខនោះ គាត់ថាគាត់មិនបានដឹងអ្វីអំពីការងាររបស់បក្សទេ ហើយសន្និដ្ឋានថា កិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍គេហៅពេលណាដែលមានសារៈសំខាន់តម្រូវឲ្យមានការពិភាក្សា។ សហចៅក្រម

ស៊ើបអង្កេតមិនដែលបានពិចារណាអំពីមូលភាព អំពីភាពជឿជាក់បានរបស់ការអះអាងរបស់ អៀង សារី អំពី នួន ជា ដែលថាគាត់ជាអ្នកទទួលខុសត្រូវច្រើនក្នុងការងាររបស់កម្ពុជាប្រជាធិបតេយ្យ។ ដីកាដំណោះស្រាយក៏មិនបានដាក់ចូលនូវភស្តុតាងដោះបន្ទុកដែលមិនស្របជាមួយទៅនឹងការរកឃើញ ដែលខ្លួនចង់លើកឡើងនោះទេ។ នៅក្នុងឧទាហរណ៍មួយ ដីកាដំណោះស្រាយបានយោងទៅរកឯកសារតែបីដែលគាំទ្រការចោទប្រកាន់ថា នួន ជា បានចូលរួមនៅក្នុងគោលនយោបាយកំណត់អតីតទាហាន និងរដ្ឋការសាធារណរដ្ឋខ្មែរ។ ក្នុងចំណោមនេះគឺថាការអះអាងរបស់ ហេង សំរិន ថា នួន ជា គឺជាអតីតខ្មែរ សាធារណរដ្ឋខ្មែរគឺមិនស្ថិត មិនគប្បីឲ្យនៅក្នុងក្របខ័ណ្ឌនៅក្នុងរបបថ្មីទេ។ ប៉ុន្តែដីកាដំណោះស្រាយមិនបានបញ្ជាក់ចំណុចសំខាន់របស់ ហេង សំរិន ថា នួន ជា ចង់ឲ្យដកអ្នកទាំងអស់នោះចេញមិនឲ្យសម្លាប់ទេ។ ដីកាដំណោះស្រាយមិនបានទទួលស្គាល់នូវចម្លើយសាក្សីសំខាន់ៗដែលមជ្ឈិមបក្សដែលណែនាំកម្មាភិបាលមិនឲ្យធ្វើបាបអ្នកសាធារណរដ្ឋខ្មែរជាឃោធាក្តីនៅក្នុងសមរភូមិ។

[១០:១៨:៥៣]

សាក្សីពីរនាក់ មាស វឿន ហើយនិង ភី ភួន បានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេត ១២០ដងនៅក្នុងដីកាដំណោះស្រាយហើយស្ទើរតែទាំងស្រុងជាក្នុងគោលបំណងនៃការដោះបន្ទុក -- ក្នុងការដាក់បន្ទុក។ ហើយការមិនដឹងអំពីភស្តុតាងដកបន្ទុកហ្នឹង ដីកាដំណោះស្រាយបានសន្និដ្ឋានដោយខុសថា នួនជា ទទួលខុសត្រូវព្រហ្មទណ្ឌ ហើយដូច្នេះហើយក៏មានចេតនាក្នុងការប្រព្រឹត្ត ហើយនិងការសម្លាប់អតីតរដ្ឋការ និងទាហានលន់នល់។ ដើម្បីឲ្យការជំនុំជម្រះយុត្តិធម៌ការស៊ើបអង្កេតត្រូវតែយុត្តិធម៌ ត្រូវតែមានតុល្យភាព ហើយនិងអព្យាក្រឹត។ ការស៊ើបអង្កេតនេះគឺវាមានលក្ខណៈ វិការៈខ្លាំងបែបនេះដូចដែលខ្ញុំនិយាយ។ កូនក្តីរបស់ខ្ញុំទទួលរងសិទ្ធិរបស់គាត់ក្នុងការបានទទួលយុត្តិធម៌ក្នុងការ ជំនុំជម្រះដ៏ត្រឹមត្រូវមុនពេលដែលសវនាការនេះបានចាប់ផ្តើមទៅទៀត។

លោកប្រធាន លោក លោកស្រីចៅក្រម! ដោយសារមានកំហុសឆ្គងដ៏ធ្ងន់ធ្ងរនៅក្នុងការស៊ើបអង្កេតបែបនេះ ឱកាសចុងក្រោយក្នុងការធានានូវភាពយុត្តិធម៌នៃដំណើរការនីតិវិធី គឺស្ថិតនៅក្នុងដៃអង្គជំនុំជម្រះសាលាដំបូង។ ប៉ុន្តែផ្ទុយទៅវិញ ដើម្បីដោះស្រាយនូវបញ្ហាដែលកើតឡើងនៅក្នុងការស៊ើបអង្កេតនេះ យើងខ្ញុំយល់ថាអង្គជំនុំជម្រះបានធ្វើផ្ទុយពីនោះទៅវិញ។ អង្គជំនុំជម្រះធ្វើសេចក្តីសម្រេចគឺមិនត្រឹមតែមិនស្រប ដោយមិនយុត្តិធម៌ គ្មានមូលដ្ឋាន គ្មានសំអាង មិនសមហេតុសមផល ប៉ុន្តែការសេចក្តីសម្រេចទាំងអស់គឺមិនយុត្តិធម៌ដែលច្បាស់ណាស់ ហើយគឺថាវាមានការបូកប្រមូលផ្តុំ ហើយដាក់

ទម្ងន់ខ្លាំងដែលបះពាល់ទៅលើការស៊ើបអង្កេតដូចគ្នា។ ដូចការិយាល័យសហចៅក្រមស៊ើបអង្កេតបញ្ជាក់ នៅក្នុងដីកាដំណោះស្រាយ គឺអង្គជំនុំជម្រះ គឺមិនដែលបានផ្តោតអារម្មណ៍ ហើយមិនដែលបានដឹកនាំរឿងក្តីទៅអ្វីដែលយើងចង់បាននៅក្នុងសេចក្តីសន្និដ្ឋាននោះទេ។

[១០:២១:០៤]

តាមអ្វីដែលយើងយល់ គឺថាការបែបនេះធ្វើឡើង គឺថាដោយសារមានការរំខានក្នុងការបង្ហាញនូវភស្តុតាងមួយចំនួនដែលដាក់បន្ទុក។ ហើយរំខានលទ្ធភាពរបស់យើងក្នុងការជំទាស់លើសាក្សី ហើយខកខានចាត់វិធានការដើម្បីបន្ធូរបន្ថយការរំខានជ្រៀតជ្រែកពីរដ្ឋាភិបាលក្នុងដំណើរការនីតិវិធី។ ក្នុងការបែបនេះ អង្គជំនុំជម្រះបណ្តោយឲ្យមានការសង្ស័យថា ភាពយុត្តិធម៌នៃដំណើរការនេះត្រូវតែបន្តទៅទៀត។

ដូច្នេះការទទួលស្គាល់នូវភស្តុតាងដោះបន្ទុក ហើយនិងការស្វែងរកទ្រឹស្តីដោះបន្ទុកហ្នឹង គឺយើងបានទាមទារជាបន្តបន្ទាប់។ ការព្រួយបារម្ភជាសំខាន់នោះគឺថា ដើម្បីកោះហៅសាក្សីដ៏សំខាន់បំផុតនៅក្នុងរឿងក្តី០០២/០១ គឺ ហេង សំរិន។ ដូចដែលខ្ញុំបានបញ្ជាក់ជាញឹកញាប់ គាត់ជាមនុស្សសំខាន់ណាស់ជាសាក្សីសំខាន់ដែលទាក់ទងទៅនឹងការជម្លៀសទីក្រុងភ្នំពេញ ហើយនិងការអះអាងចោទប្រកាន់ពីទួលពោធិ៍ជ្រៃ ហើយក៏ជាសាក្សីដ៏សំខាន់បញ្ជាក់ពីអត្តចរិតរបស់កូនក្តីរបស់ខ្ញុំ នួន ជា ដែរ។ ទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ ហេង សំរិន គឺជាសាក្សីតែម្នាក់គត់ ដែលមានភស្តុតាងផ្ទាល់ទាក់ទងទៅនឹងចេតនាកូនក្តីរបស់ខ្ញុំក្នុងការប្រព្រឹត្តទៅលើអ្នករដ្ឋការ និងទាហាន លន់ លន់។

[១០:២២:៣៤]

ដូចដែលយើងបានពន្យល់ឲ្យច្បាស់នៅពេលក្រោយហ្នឹង គឺគាត់បានប្រាប់ ប៉ែន យៀវនិន ថា "កូនក្តីរបស់ខ្ញុំបានណែនាំកម្មាភិបាលមិនឲ្យសម្លាប់អតីតរដ្ឋការ និងទាហានសាធារណរដ្ឋទេ"។ ដូចដែលខ្ញុំបានកត់សម្គាល់ខាងដើម ហេង សំរិន គឺជាមេដឹកនាំយោធាខ្ពស់តែម្នាក់គត់ដែលបានចូលរួមក្នុងការជម្លៀសទីក្រុងភ្នំពេញ។ សក្ខីកម្មរបស់គាត់អាចនឹងដោះបន្ទុកនៅក្នុងបរិបទនោះដែរ។ គាត់អាចនឹងបានបញ្ជាក់ថា គណៈអចិន្ត្រៃយ៍មិនមានការត្រួតត្រាជាមានប្រសិទ្ធភាពទៅលើកងទ័ពដែលបានទទួលខុសត្រូវជម្លៀស រំដោះ និងជម្លៀសទីក្រុងភ្នំពេញ ហើយក៏មិនមានការបញ្ជាក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋពីកូនរបស់ខ្ញុំទេ។ ការរារាំងមិនឲ្យ ហេង សំរិន ចូលរួមក្នុងសវនាការនេះ ក្នុងឋានៈជាសាក្សី គឺបះពាល់ដល់សិទ្ធិរបស់កូនក្តីរបស់ខ្ញុំ។ ប៉ុន្តែអង្គជំនុំជម្រះបានបដិសេធ ឬក៏មិនដឹងមិនឮទៅលើសំណើជាញឹកញាប់របស់ខ្ញុំ ដើម្បីឲ្យគាត់មកបង្ហាញជាសាក្សីបញ្ជាក់ពីអត្តចរិតរបស់លោក នួន ជា។ អង្គជំនុំជម្រះមិនបាន

ធានាឲ្យគាត់មកធ្វើសក្ខីកម្មទេ ដូចដែលខ្ញុំបានបញ្ជាក់នៅក្នុងសេចក្ដីសន្និដ្ឋាននោះគឺថា អង្គជំនុំជម្រះបានរារាំងមិនឲ្យយើងធ្វើការអះអាងលើកឡើងនោះ។ ពេលខ្លះបានកាត់ផ្ដាច់ការពិភាក្សា ការប្រឹងប្រែងរបស់យើងអំពីតួនាទីរបស់គាត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

[១០:២៤:០៩]

អង្គជំនុំជម្រះបានបដិសេធសំណើរបស់យើង សុំឲ្យ ជា ស៊ីម ហើយនិង អ៊ុក ប៊ុនឈឿន មកផ្ដល់សក្ខីកម្មនិយាយអំពីករណីរបស់ ឈូក រីន ផងដែរ។ ក្នុងទស្សនៈរបស់យើង អង្គជំនុំជម្រះរបស់យើងមិនចាប់អារម្មណ៍ក្នុងការផ្ដល់ឲ្យយើងផ្ដល់សាក្សីដែលស៊ើសង្វាក់របស់ ហេង សំរិន ទេ។ ចំពោះ ហេង សំរិន គឺអង្គជំនុំជម្រះបានហាមឃាត់មិនឲ្យមានការពិភាក្សា ដូចជាការិយាល័យចៅក្រមស៊ើបអង្កេតបានកោះហៅពួកគាត់នោះ។ អង្គជំនុំជម្រះក៏មិនបានអនុញ្ញាតឲ្យមានការបញ្ជាក់អំពីការបដិសេធពីទីកន្លែងរបស់ពួកគេនៅក្នុងបញ្ជីទេ។ ប៉ុន្តែអង្គជំនុំជម្រះក៏បានបន្តប្រើចម្លើយរបស់ពួកគេអំពីគោលបំណងដាក់បន្ទុក ដែលលាតត្រដាងអំពីការលម្អៀងយ៉ាងជាក់ច្បាស់ គាំទ្រខាងសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះបានបដិសេធសាក្សីខ្លះដែលទាក់ទងទៅនឹងមេធាវីការពារក្ដី គឺវាមានកម្រិតទៅនឹងសាក្សីដែលមានឋានៈខ្ពស់នៅក្នុងរដ្ឋាភិបាល។ យើងបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងចំណុចថា យើងយកបញ្ហានេះជាបញ្ហាសំខាន់របស់មេធាវីការពារក្ដី។ ដូចដែលបានបញ្ជាក់ពីរឿងនេះ គឺថាយើងត្រូវមើលឲ្យលម្អិតអំពីបរិបទនៃសាក្សី ជាសំខាន់ក្នុងការបង្កើតនូវកាលៈទេសៈជុំវិញបដិវត្តសង្គមរបស់កម្ពុជា ហើយនិងជាកត្តាសំខាន់នៃសារធាតុនៃការការពារក្ដីរបស់លោក នួន ជា។

[១០:២៥:៥៣]

ដូចដែលយើងបានប៉ុនប៉ងពន្យល់ម្ដងហើយម្ដងទៀត អំពីបញ្ហានេះ មិនមានលទ្ធភាពក្នុងការវាយតម្លៃនយោបាយបក្សកុម្មុយនីស្តក្រៅពីបរិបទ អំពីរបៀបណា អំពីមូលហេតុនៃគោលនយោបាយនេះ។ សហចៅក្រមស៊ើបអង្កេតបានខកខានមិនបានពន្យល់ពីការពិចារណានេះទេ។ អង្គជំនុំជម្រះក៏មិនបានផ្ដល់ភស្តុតាងនេះដែរ មិនបានពិនិត្យឲ្យបានច្បាស់ទេ។ អង្គជំនុំជម្រះម្ដងហើយម្ដងទៀត បដិសេធមិនស្ដាប់ចម្លើយ ការអះអាងសន្និដ្ឋានផ្ទាល់ ហើយនិងភាពពាក់ព័ន្ធពីបញ្ហានេះ។ ហើយការផ្ដល់មូលដ្ឋានជាផ្លូវច្បាប់ដែលថាអ្វីដែលវាពាក់ព័ន្ធនឹងការចោទប្រកាន់លើកូនក្ដីរបស់យើងខ្ញុំ។ ហើយនៅក្នុងវិសាលភាពតូចចង្អៀតនៅក្នុងស្នើរបស់យើងប្អូនដង ជាពិសេសសាក្សីសំខាន់ៗប្អូន អង្គជំនុំជម្រះបានបដិសេធ។ មិនមានមូលដ្ឋានអ្វីដែលគាំទ្រការធ្វើសេចក្ដីសម្រេចនោះទេ។

នៅក្នុងការធ្វើសេចក្តីសម្រេចមិនស្តាប់សាក្សីនោះ គឺជាការបំពានទៅលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះ។ សក្ខីកម្មទាំងអស់នេះ គឺបង្កើតនូវឱកាសដែលធ្វើឲ្យយើងអាចស៊ើបអង្កេតមិនត្រឹមតែប៉ុណ្ណោះទេ គឺនាំឲ្យអង្គជំនុំជម្រះអាចនឹងពិនិត្យមើលបញ្ហាបានទូលំទូលាយ ដែលរួមបញ្ចូលទាំងស្ថានភាពស្បៀងអាហារ និងសន្តិសុខនៅភ្នំពេញ និងទីកន្លែងផ្សេងទៀត នៅកម្ពុជាឆ្នាំ១៩៧៥។ ទី២ សេចក្តីលម្អិតអំពីការទម្លាក់គ្រាប់បែកសហរដ្ឋអាមេរិកនៅក្នុងប្រទេស។ ហើយចំណុចទី៣ ការយល់ដឹង ហើយនិងចេតនារបស់កូនក្តីរបស់ខ្ញុំ ពាក់ព័ន្ធទៅនឹងផលវិបាកនៃការជម្លៀស។

[១០:២៧:៣៩]

ដោយយើងមិនអាចការហៅសាក្សីដែលពាក់ព័ន្ធនឹងបរិបទរបស់យើង គឺមេធាវីការពារក្តីមិនមានជម្រើសអ្វី ត្រូវតែពិនិត្យមើលដែលសហព្រះរាជអាជ្ញាបានកោះមក ហើយនិងពិនិត្យមើល ហើយអ្វីដែលអង្គជំនុំជម្រះបានជ្រើសរើស។ គ្មានសាក្សីណាមួយក្នុងអ្នកទាំងអស់នេះ បានបញ្ជាក់ពីកត្តាជាប្រព័ន្ធដែលជាការជំរុញរបស់បក្សកុម្មុយនីស្តកម្ពុជាទេ។ នៅក្នុងកាលៈទេសៈទាំងអស់នេះ អង្គជំនុំជម្រះបានរារាំងជាញឹកញាប់ក្នុងការមិនឲ្យចូលរួមការសួរសំណួរលក្ខខណ្ឌមុនឆ្នាំ១៩៧៥នៅកម្ពុជា ដែលមានផលប៉ះពាល់ផ្ទាល់ទៅក្នុងហេតុការណ៍នៅកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ផលប៉ះពាល់ដ៏សំខាន់នៃការសម្រេចទាំងអស់នេះ គឺបង្ហាញភាពមិនស្មើគ្នាពាក់ព័ន្ធទៅនឹងឱកាសក្នុងការការពារក្តី។ នៅក្នុងភស្តុតាងជាក់ស្តែង គឺថាមិនបាន អង្គជំនុំជម្រះបានស្តាប់សាក្សី៧៥។ ៣៥ ត្រូវបានជ្រើសរើសដោយសហព្រះរាជអាជ្ញា ឬក៏ដោយដើមបណ្តឹងរដ្ឋប្បវេណី ហើយមានតែបួនទេ ដែលត្រូវបានជ្រើសរើសដោយមេធាវីតាំងពីរក្រុមរួមគ្នា។ អតុល្យភាពនេះបំពានទៅលើសមភាពនៃអំណាច ហើយបង្កើតបាននូវបរិយាកាសមិនយុត្តិធម៌ជាមួយរឿងក្តីរបស់លោក នួន ជា ដែលត្រូវបង្ហាញនូវគុណវិបត្តិសំខាន់ដែលពាក់ព័ន្ធ -- ដែលគាំទ្រទៅខាងសហព្រះរាជអាជ្ញា។

[១០:២៩:១៨]

លោកប្រធាន អង្គជំនុំជម្រះបានរារាំងយើងមិនឲ្យយើងបង្ហាញនូវហេតុការណ៍ទាំងឡាយ មុនឆ្នាំ១៩៧៩។ ទោះបីជាមានការអះអាងយ៉ាងពិស្តារពាក់ព័ន្ធទៅនឹងហេតុការណ៍ទាំងអស់នោះ។ ជាពិសេសនៅក្នុងករណី០០២/០១នេះក្តី។ អានេះគឺទាក់ទងទៅនឹងការប្រមូលឯកសារដោយ ភី.អិល.ខេ ហើយនិងតួនាទីរបស់វៀតណាមនៅក្នុងការសរសេរប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជានៅក្នុងកម្មវិធីនយោបាយរបស់គេ។ បញ្ហាទាំងអស់នេះ គឺស្ថិតនៅក្នុងការដេញដោល ពាក់ព័ន្ធទៅនឹងការភាពដោះបន្ទុក ហើយ

និងធម្មានុរូបរបស់តុលាការ ហើយនិងឯករាជ្យភាពរបស់តុលាការ យថាភាពនៃភស្តុតាងទាំងឡាយប្រឆាំងនឹង នួន ជា ហើយនិងភាពលម្អៀងនៅក្នុងផលិតភស្តុតាងដោះបន្ទុក-ដាក់បន្ទុក ហើយនិងសេចក្តី -- ក្នុងខណៈពេលដែលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាច។ បញ្ហាទាំងអស់នេះត្រូវបានអង្គជំនុំជម្រះបដិសេធ។

លោកប្រធាន ការបដិសេធបន្តទៅទៀតចំពោះការតាមដានភស្តុតាងដោះបន្ទុករបស់ នួន ជា ដែលលើកឡើង រ៉ប់ លឹមគិន *(Rob Lemkin)* គឺជាអ្នកនិពន្ធ និងអ្នកផលិតខ្សែភាពយន្តដែលមានចំណងជើងថា “សត្រូវប្រជាជន” និង “ថ្ងៃមួយនៅទួលពោធិ៍ជ្រៃនោះ”។ លោក លឹមគិន ដែលខ្សែភាពយន្តរបស់គាត់គឺជាភស្តុតាង ហើយត្រូវបានពឹងផ្អែកយ៉ាងខ្លាំងដោយសហព្រះរាជអាជ្ញានោះបានជម្រាបយើងនៅក្នុងអ៊ីម៉ែលដែលមានលក្ខណៈច្បាស់លាស់មួយថា ខ្សែវីដេអូដែលច្បាស់លាស់ជាងនេះ គឺថាត្រូវបានគេកាត់ចេញពីខ្សែភាពយន្តរបស់គាត់ ហើយវាបានបញ្ជាក់ថា ឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅទួលពោធិ៍ជ្រៃគឺមិនមែនបញ្ជាដោយមជ្ឈិមបក្សនោះទេ។

[១០:៣១:០៦]

ខ្សែវីដេអូនោះក៏បានបង្ហាញដែលថាតុលាការយោធាបាន គឺថាមុននឹងមានការ -- គឺតុលាការយោធាត្រូវបានធ្វើឡើងមុននឹងមានការសម្លាប់មន្ត្រីជាន់ខ្ពស់របស់របបសាធារណរដ្ឋខ្មែរ។ បន្ទាប់ពីបានស្តាប់ទៅលើព័ត៌មានដោះបន្ទុកទាំងអស់នេះ លោកប្រធានអង្គជំនុំជម្រះបានសម្រេចថា គឺត្រូវបដិសេធដោយមិនធ្វើដឹង ធ្វើឮអីទាំងអស់ ទៅលើសំណើររបស់មេធាវីការពារក្តីសុំឱ្យកោះហៅលោក រ៉ប់ លឹមគិន។ មិនត្រឹមតែប៉ុណ្ណោះទេ វាមានការរំលោភបំពានទៅលើសិទ្ធិរបស់កូនក្តីរបស់ខ្ញុំក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺការផ្លាស់ប្តូរនីតិវិធីក្នុងការកម្រិតសមត្ថភាពរបស់យើង មិនអាចធ្វើការជំទាស់ទៅលើភស្តុតាងដែលទទួលបានដោយអង្គជំនុំជម្រះ។ អង្គជំនុំជម្រះនេះក៏បានហាមឃាត់ការប្រើប្រាស់ឯកសារក្នុងការសួរផ្ទុញទៅលើសាក្សី ដែលជាការអនុវត្តដែលគេធ្វើជាទូទៅ ទាំងច្បាប់កម្ពុជាក៏ដូចជាការច្បាប់អន្តរជាតិ។ ហេតុដូច្នេះហើយ ទើបថាកូនក្តីរបស់ខ្ញុំត្រូវបានគេរាំងជាប្រព័ន្ធមិនឱ្យមានការសួរដេញដោលទៅលើសាក្សីប្រឆាំងរូបគាត់។

[១០:៣២:១៣]

អង្គជំនុំជម្រះនេះ អនុញ្ញាតឱ្យសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការពិនិត្យទៅលើកំណត់ហេតុស្តាប់ចម្លើយកាលពីពេលមុនៗ ពេលដែលផ្តល់សក្ខីកម្ម។ ជាលទ្ធផល អង្គជំនុំជម្រះធ្វើឱ្យមេធាវីកំណត់

ឲ្យបានច្បាស់អំពីភាពមិនស៊ីសង្វាក់គ្នានៃការចងចាំរបស់សាក្សីដែលបានផ្តល់សក្ខីកម្មទៅលើហេតុ-ការណ៍ដែលកើតឡើងប្រហែលជា៣០ ទៅ៣៥ឆ្នាំ។ អង្គជំនុំជម្រះនេះបានទទួលនូវកំណត់ហេតុស្តាប់ចម្លើយរាប់ពាន់ដែលមិនឲ្យសាក្សីមកបង្ហាញដើម្បីការសួរដេញដោលនោះឡើយ។ ដូចដែលយើងបានពិភាក្សាពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ កំណត់ហេតុស្តាប់ចម្លើយមួយចំនួនត្រូវបានពឹងផ្អែកដោយសហព្រះរាជអាជ្ញាសម្រាប់គោលដៅនៃការបង្ហាញអំពីវត្តមានរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់ទាហាននិងអ្នករដ្ឋការលន់នល់។ សាក្សីដែលអង្គជំនុំជម្រះក៏ដូចជាសាធារណជនមិនដែលឃើញ។ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបាននិយាយក្នុងពេលថ្មីៗនេះ យុត្តិធម៌មិនគួរតែត្រូវបានធ្វើប៉ុណ្ណោះទេ គួរតែត្រូវបានឃើញតែគេធ្វើ។ ប៉ុន្តែសាក្សីទាំងអស់នោះ គឺសាក្សីដែលព្រះរាជអាជ្ញាបាននិយាយថាបន្ទាប់ពីរយៈពេលប្រាំមួយឆ្នាំហ្នឹងហើយ គឺជាសាក្សីដែលសំខាន់ ប៉ុន្តែមិនដែលបានបង្ហាញខ្លួនឲ្យនរណាម្នាក់បានឃើញនោះឡើយ។ អង្គជំនុំជម្រះនេះបានអនុម័តបានយល់ ទទួលស្គាល់នូវឯកសាររបស់ពាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយមិនមានការស៊ើបអង្កេតឲ្យបានលម្អិតទាក់ទងទៅនឹងអ្វីដែលបានធ្វើឡើងនៅ ឌី.ស៊ី.ខេម តាំងពីឆ្នាំ១៩៩៥។ ជាលទ្ធផលអង្គជំនុំជម្រះនេះពឹងផ្អែកទៅលើឯកសារដែលមិនអាចបង្ហាញយថាភាពឲ្យគ្រប់គ្រាន់នោះឡើយ។

អង្គជំនុំជម្រះមិនត្រឹមតែបដិសេធសំណើរបស់យើងសុំឲ្យមជ្ឈមណ្ឌលឯកសារផ្តល់ព័ត៌មានអំពីការរក្សាទុកឯកសារប៉ុណ្ណោះទេ។ ប៉ុន្តែអង្គជំនុំជម្រះបង្ហាញនូវការមិនចាប់អារម្មណ៍ទាល់តែសោះក្នុងការពិនិត្យទៅលើយថាភាពនៃឯកសារដែលទទួលយកប្រឆាំងនឹងលោក នួន ជា។ ទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ អង្គជំនុំជម្រះនេះជ្រើសរើសការបដិសេធ គឺថាអង្គជំនុំជម្រះមិនបានធ្វើការពិនិត្យទៅលើការចោទប្រឆាំងនឹងលោក នួន ជា ឲ្យមានលក្ខណៈស៊ីជម្រៅនោះឡើយ។

[១០:៣៤:៣៦]

ការរារាំងមួយទៀតទៅលើសមត្ថភាពរបស់ នួន ជា ក្នុងការជំទាស់ទៅលើភស្តុតាងប្រឆាំងរបស់ពួកគាត់ គឺជាការរារាំងសឹងតែទាំងស្រុងទៅលើការសាកសួរចំពោះការស៊ើបអង្កេតតាមផ្លូវតុលាការ។ ខ្ញុំបានបង្ហាញរួចមកហើយថា ការស៊ើបអង្កេតទៅលើសំណុំរឿង០០២ ត្រូវបានខូចខាតទៅដោយកំហុសឆ្គងនិងការមើលរំលង។ នៅពេលដែលយើងតវ៉ាអំពីបញ្ហាទាំងអស់នេះនៅក្នុងស៊ើបអង្កេតយើងត្រូវបានគេប្រាប់ដោយសហចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះថា វិការៈណាមួយនៅក្នុងការស៊ើបអង្កេតនឹងត្រូវបានជំនួស នឹងត្រូវបានបះប៉ូវដោយការសួរដេញដោលនៅក្នុងសវនាការ។ ប៉ុន្តែនៅពេលដែល

យើងចង់សួរដេញដោលទៅលើសាក្សីទាក់ទងទៅនឹងចម្លើយដាក់បន្ទុករបស់ពួកគេ សំណើរបស់យើងត្រូវបានគេបដិសេធជាទៀងទាត់។ នៅពេលដែលសាក្សីបង្ហាញ គឺថាយើងព្យាយាមសិក្សាអំពីកំហុសឆ្គងនៅក្នុងចម្លើយរបស់ពួកគេ ប៉ុន្តែអង្គជំនុំជម្រះបានប្រាប់ថា យើងគួរតែលើកបញ្ហានេះនៅពេលស៊ើបអង្កេតមិនមែននៅពេលនេះទេ។ ចៅក្រម ឡាវ៉ែន៍ ព្យាយាមទាមទារចង់ ដឹងថាតើអ្វីដែលមេធាវីការពារក្ដីបានធ្វើនៅក្នុងរយៈពេលរាប់ឆ្នាំនៃការស៊ើបអង្កេតតុលាការនោះ? លោកប្រធាន ចម្លើយគឺថា ពួកយើងបានដាក់នូវសារណារាប់សិបរាប់រយដើម្បីទាមទារឲ្យមានការជួសជុលចំពោះការខូចខាតនេះ ប៉ុន្តែយើងមិនបានទទួលនូវការជួសជុល ឬក៏មិនទទួលបាននូវការឆ្លើយតបណាមួយឡើយ។ ដោយសារតែមានបញ្ហាជាច្រើនពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត មិនត្រូវបានអង្គជំនុំជម្រះនេះហាមឃាត់ ក្នុងនោះរួមមានដូចជាថាតើសាក្សីត្រូវបានគេផ្ដល់ព័ត៌មាន ត្រូវបានគេឲ្យព័ត៌មាន ឬក៏ត្រូវបានគេបង្ហាញព័ត៌មាន។ ទី២ ត្រូវបានគេបង្ខំ ត្រូវបានគេបំពារបំពាន ឬក៏ត្រូវបានគេដឹកនាំ ឬក៏ត្រូវបានគេយល់ខុស ឬក៏បានដកស្រង់ខុស ឬក៏ពេលខ្លះត្រូវបានសម្ភាសដោយមិនមានការថតជាខ្សែអាត់សំឡេងទៀតផង។

[១០:៣៦:៣៤]

នៅក្នុងឧទាហរណ៍ពិសេសមួយទៀត អង្គជំនុំជម្រះបានបដិសេធមិនឲ្យយើងធ្វើការសួរដេញដោលចំពោះសាក្សីថាតើអ្នកស៊ើបអង្កេតមានបាននិយាយក្រៅពីកំណត់ត្រានៅក្នុងពេលសម្ភាសដែរឬក៏អត់? ទោះបីថា វាមានការបង្ហាញថា អ្នកស៊ើបអង្កេតបានធ្វើដូច្នេះជាមួយនឹងសាក្សីដទៃទៀតក៏ដោយដែលរស់នៅក្នុងទីក្រុង ឬក៏នៅក្នុងទីរួមខេត្តជាមួយគ្នាក៏ដោយ ហើយគឺជាសហការីរបស់សាក្សីនៅក្នុងរបបខ្មែរក្រហមក៏ដោយ។ ហើយថាសាក្សីហ្នឹងត្រូវបានអ្នកស៊ើបអង្កេតធ្វើឡើង២០នាទីមុនពេលដែលមានការសួរដេញដោល។ ឧទាហរណ៍មួយទៀតគឺសំណួរពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលសាក្សីត្រូវបានគេស្ដាប់ឮនៅក្នុងការស៊ើបអង្កេតដែលគេនិយាយថា តើសាក្សីហ្នឹងអាចពិនិត្យមើលទៅលើកំណត់ត្រាមុនពេលឆ្លើយសំណួរ។

លោកប្រធាន ទាក់ទងទៅនឹងបញ្ហាទាំងអស់នេះយើងមានការអន់ចិត្តយ៉ាងខ្លាំង ប៉ុន្តែសេចក្ដីសម្រេចដែលធ្ងន់ធ្ងរបំផុតទាក់ទងនឹងការពិនិត្យមើលទៅលើសក្ខីកម្មគឺនៅពេលដែលមានសក្ខីកម្មរបស់ស្ទីវ ហេដឌ័រ។ ដោយសារហេតុផលយើងដឹងច្បាស់ថាលោក ហេដឌ័រ គឺជាសាក្សីពិសេសមួយ។ នៅក្នុងឆ្នាំ២០០៤ លោក ហេដឌ័រ បានបោះពុម្ពសៀវភៅមួយដែលមានចំណងជើងថា "បេក្ខជនទាំងប្រាំពីរសម្រាប់ការផ្ដន្ទាទោស" គឺជាសៀវភៅដែលគេនិយាយអំពីការជំនុំជម្រះទៅលើជនជាប់ចោទ

ប្រាំពីររូប ដែលក្នុងនោះរួមមាន នួន ជា នៅពេលដែលអង្គជំនុំជម្រះត្រូវបានបង្កើតដោយសារគោលដៅនោះ ហេងឌ័រ ត្រូវបានជួលដោយការិយាល័យសហព្រះរាជអាជ្ញាដើម្បីជួយដល់ពួកគេក្នុងការសរសេរសារណាដីកាបញ្ជូនរឿងទៅស៊ើបសួរ។ បន្ទាប់ពីដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបានដាក់ លោក ស្ទីវ ហេងឌ័រ ត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតជ្រើសរើសឲ្យមកធ្វើការងារដើម្បីធ្វើការ ស៊ើបអង្កេតទៅលើការចោទប្រកាន់ដែលគាត់បានធ្វើ។ ដំបូងគាត់សរសេរសៀវភៅ "បេក្ខជនទាំងប្រាំពីរ" បន្ទាប់មកគាត់សរសេរដីកាបញ្ជូនរឿងឲ្យស៊ើបសួរ បន្ទាប់មកទៀតគាត់ជួយសរសេរដីកាដំណោះស្រាយ ដែលនៅក្នុងនោះគឺថាយើងមិនមានការភ្ញាក់ផ្អើលអ្វីនោះទេ ដែលថាគាត់យល់ស្របជាមួយនឹងការចោទប្រកាន់ផ្ទាល់ខ្លួនរបស់គាត់។

[១០:៣៨:៤៥]

នៅពេលដែលការចោទប្រកាន់ទាំងនេះ លើកមកចំពោះមុខអង្គជំនុំជម្រះ លោក ហេងឌ័រ ត្រូវបានគេកោះហៅមកធ្វើជាសាក្សីទៀត។ គាត់បានផ្តល់ភស្តុតាងអំពីការចោទប្រកាន់ដែលគាត់បានបង្ហាញនៅក្នុងសៀវភៅរបស់គាត់ ហើយគាត់បានធ្វើឡើងក្នុងនាមជា សហព្រះរាជអាជ្ញា ធ្វើការស៊ើបអង្កេតក្នុងនាមជាសហចៅក្រមស៊ើបអង្កេត បន្ទាប់មកទៀតគាត់បានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយ។ ឥឡូវនេះសហព្រះរាជអាជ្ញាបានពឹងផ្អែកទៅលើភស្តុតាងរបស់លោក ហេងឌ័រ យ៉ាងខ្លាំងក្នុងការគាំទ្រទៅលើការចោទប្រកាន់ក្នុងនាមឲ្យពួកគេក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងមកនោះ។ ដូច្នេះ គឺគ្មានអ្នកណាម្នាក់ជំទាស់អំពីសមាសភាពរបស់លោក ហេងឌ័រ ជាអ្នកស្រាវជ្រាវ និងជាអ្នកសិក្សានោះទេ ប៉ុន្តែអ្នកចូលរួមមួយនៅក្នុងដំណើរការនេះ ហើយជាសាក្សីនេះ គឺថាវាមានបញ្ហាយ៉ាងខ្លាំង។ តុលាការនានាដែលគិតអំពីការជឿទុកចិត្តចំពោះភស្តុតាង គឺតម្រូវឲ្យមានការពន្យល់យ៉ាងលម្អិតពាក់ព័ន្ធទៅនឹងលក្ខណៈ និងកម្រិតនៃតួនាទីរបស់លោក ហេងឌ័រ នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងការស៊ើបអង្កេតដែលធ្វើបន្ត។ ស្របទៅតាមឥទ្ធិពលរបស់លោក ហេងឌ័រ ដ៏ពិសេសទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីទាំងអស់នេះតុលាការណាក៏ដោយក៏គួរតែព្យាយាមស្វែងរកការពិត ថាតើអ្វីដែលជំរុញឲ្យមានមូលដ្ឋាននៃការសន្និដ្ឋានរបស់គាត់នេះ។

[១០:៤០:១១]

**ប្រធានអង្គជំនុំ៖**

បាទ បានហើយលោកសម្រាកសិន ដល់ម៉ោងសមល្មមសម្រាកហើយ។

អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងត្រូវពេលប្រហែលជាកន្លះម៉ោងទៀតដើម្បីបញ្ចប់សេចក្តីសន្និដ្ឋានបឋមរបស់ខ្ញុំ។

មុនពេលសម្រាកនេះ ខ្ញុំបាននិយាយអំពីលោក ហេដឌ័រ ហើយខ្ញុំបាននិយាយថា មិនមានអ្នកណាសង្ស័យទេអំពីគុណវុឌ្ឍិរបស់គាត់ជាអ្នកស៊ើបអង្កេតនិងសិក្សា។ ដូច្នេះការចូលរួមនៅក្នុងដំណើរការនេះក្នុងឋានៈជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ មានបញ្ហាមួយចំនួនដែលត្រូវដោះស្រាយចំពោះគាត់។

តុលាការមានការព្រួយបារម្ភអំពីភាពជឿជាក់នៃភស្តុតាងដែលគាត់បង្ហាញ ហើយតម្រូវឲ្យមានការពន្យល់ឲ្យច្បាស់អំពីតួនាទីរបស់គាត់នៅក្នុងដីកាបញ្ជូនរឿងទៅឲ្យស៊ើបអង្កេត និងការស៊ើបអង្កេតនៅក្នុង -- គាត់មានឥទ្ធិពលដ៏ខ្លាំងនៅក្នុងដំណាក់កាលសវនាការ ហើយក្នុងតុលាការ និងការស្វែងរកការពិត។ ហើយជាពិសេសវាជាការជំរុញឲ្យមានការ មានមូលដ្ឋាននៃការសន្និដ្ឋានរបស់គាត់។

ផ្ទុយទៅវិញអង្គជំនុំជម្រះបានរកមើលនូវលទ្ធភាពតូចមួយដែលអាច។ ទោះបីជាលោក ហេដឌ័របានបង្ហាញខ្លួននៅតុលាការនេះក្តី ហើយគាត់ធ្វើសក្ខីកម្ម អង្គជំនុំជម្រះបានហាមឃាត់មិនឲ្យសួរសំណួរអំពីការស៊ើបអង្កេតទេ។ អង្គជំនុំជម្រះបានហាមរាល់សំណួរអំពីវិធីសាស្ត្រដែលគាត់បានប្រើក្នុងការស្វែង

រកសេចក្តីសន្និដ្ឋាននោះ។ អង្គជំនុំជម្រះមិនបានសម្រេចថា សំណួរទាំងអស់នោះគឺមិនមានតម្លៃទេ ហើយក៏មិនមានភាពពាក់ព័ន្ធ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានសម្រេចថា បញ្ហាទាំងអស់នោះគឺមិនអាចទទួលយកបានទេ ដោយហេតុថាវាមានការពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត។ ហើយដូចដែលលោកជ្រាបហើយថា នេះហើយការផ្លាស់ប្តូរបែបនេះគឺជាការបំពានធ្ងន់ធ្ងរទៅលើសិទ្ធិរបស់កូនក្តីរបស់ខ្ញុំ នៅពេលដែលអាចនឹងធ្វើឱ្យគាត់រារាំងមិនអាចនឹងបង្ហាញពីសក្ខីកម្មដោះបន្ទុកនោះបាន។

[១១:០៤:១៤]

ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតត្រឡប់ទៅរកចំណុចអ្វីមួយដែលខ្ញុំបាននិយាយពីរដងរួចមកហើយ។ គឺការជ្រៀតជ្រែករបស់រដ្ឋាភិបាលទៅនឹងការងាររបស់តុលាការ។ ហើយខ្ញុំបានយោងទៅនឹងការលើកឡើងជាបឋមរបស់ខ្ញុំ ខ្ញុំបានពន្យល់ថា មានពេលជាច្រើនហើយពីមុន ដែលអំពីមូលហេតុដែលការជ្រៀតជ្រែករបស់រដ្ឋាភិបាលប៉ះពាល់សិទ្ធិរបស់កូនក្តីខ្ញុំក្នុងការជំនុំជម្រះដោយយុត្តិធម៌។ ហើយខ្ញុំបានពន្យល់បន្ថែមទៀតថា ការជ្រៀតជ្រែករបស់រដ្ឋាភិបាលនេះ គឺប៉ះពាល់ផ្ទាល់ទៅលើលទ្ធភាពរបស់ នួន ជា ក្នុងការស្តាប់ភស្តុតាងដោះបន្ទុករបស់គាត់។ ការជ្រៀតជ្រែកនេះចាប់ផ្តើមតាំងពីតុលាការចាប់ផ្តើម ហើយក៏បន្តរហូតមកដល់ពេលនេះ ហើយមានការកត់ត្រាត្រឹមត្រូវ ហើយមិនអាចប្រកែកបាន ដែលរាប់បញ្ចូលទាំងការប្រឹងប្រែងរបស់មន្ត្រីរដ្ឋាភិបាល ដើម្បីរារាំងនូវអតីតព្រះមហាក្សត្រ នរោត្តម សីហនុ មិនឱ្យធ្វើជាសាក្សី,ពីរ, ហើយនិងការបរាជ័យក្នុង -- រារាំងមិនឱ្យមន្ត្រីជាន់ខ្ពស់មកបង្ហាញខ្លួនចំពោះសហចៅក្រមស៊ើបអង្កេត ហើយជាពិសេសគឺតួនាទីរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយនិងសមាជិករបស់រដ្ឋាភិបាល។ ទី៣) ការប្រឹងប្រែងរបស់នាយករដ្ឋមន្ត្រីដោយមានការគាំទ្រសម្រួលរបស់មន្ត្រីរដ្ឋាភិបាលផ្សេងៗទៀត ដើម្បីរារាំងរឿងក្តី០០៣ និង ០០៤។ មេធាវីការពារក្តីបានលើកឡើងពីការព្រួយបារម្ភអំពីការសមគំនិត អំពីសហព្រះរាជអាជ្ញាជាតិ ហើយនិងសហចៅក្រមស៊ើបអង្កេតចៅក្រម យូ ប៊ុនឡេង ដែលបានតម្រូវឱ្យចៅក្រម យូ ប៊ុនឡេង លាលែងនោះ។

[១១:០៦:០២]

ដោយមិនមានការសង្ស័យអ្វីអំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាល ដែលអាចនឹងកើតមានឡើងហើយអាចនឹងបញ្ជាក់នៅក្នុងការលាលែងរបស់ចៅក្រម កាស្ពើ អានសឺមេត*(Kasper-Ansermet)* នៅក្នុងតុលាការនេះ ហើយគាត់បានចាកចេញទៅបានសរសេរសេចក្តីពន្យល់ ១០ទំព័រថា មានការជ្រៀតជ្រែកជាបន្តបន្ទាប់ក្នុងការងាររបស់គាត់នៅសាលាក្តី។ ដូចដែលចៅក្រម កាស្ពើ នោះបានបញ្ជាក់ថា "មាននៅ

ក្នុង អ.វ.ត.ក គឺភាពមិនប្រក្រតីធ្ងន់ធ្ងរ ដំណើរការខុស ហើយនិងការបំពានទៅលើនីតិវិធីត្រឹមត្រូវដែលធ្វើឲ្យមានគ្រោះថ្នាក់ ហើយនិងប៉ះពាល់ទៅដល់នីតិវិធីផ្លូវច្បាប់ត្រឹមត្រូវ" បញ្ចប់ការដកស្រង់។

ភស្តុតាងអំពីការជ្រៀតជ្រែកនេះមានភាពច្បាស់លាស់ ហើយនិងបញ្ជាក់ឲ្យមានការយោបល់ ហើយនិងការព្រួយបារម្ភពីសមាគមន៍អន្តរជាតិផង។ អង្គការ *អូផិន សូសាយអេធី ចាស្ទីស អីនីធីអេតធីវ (តាមសួរស័ព្ទ)* ដែលជាតាមដានតុលាការ។ អង្គការសហប្រជាជាតិ ហើយម្ចាស់ជំនួយក៏បានបញ្ជាក់មានការរំខានពីរដ្ឋាភិបាល ហើយត្រូវពិចារណាពីការប្តេជ្ញារបស់តុលាការមួយនេះផង។ ក្រៅពីការបំពានអំពីសិទ្ធិកូនក្តីរបស់ខ្ញុំនេះ ហើយរារាំងមិនឲ្យគាត់ស្តាប់ភស្តុតាងដោះបន្ទុកសំខាន់ៗ ឥទ្ធិពលរបស់រដ្ឋាភិបាលទៅលើនីតិវិធីរបស់ អ.វ.ត.ក មានផលប៉ះពាល់ផ្ទាល់ទៅលើលោក នួន ជា។ តាំងពីចំណុចចាប់ផ្តើមនៃសវនាការរឿងក្តី០០២ មន្ត្រីហើយនិងភ្នាក់ងាររបស់រដ្ឋាភិបាលបានសម្តែងមតិដោយមិនត្រឹមត្រូវអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។

[១១:០៧:៤៦]

នៅក្នុងខែមករា ឆ្នាំ២០១២ នៅក្នុងសន្និសីទសារព័ត៌មានអន្តរជាតិ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសជាសាធារណៈថា "កូនក្តីរបស់ខ្ញុំគឺនិយាយបោសប្រាស់ ហើយជាឃាតករ ហើយជាចារីនៃអំពើប្រល័យពូជសាសន៍"។ ពាក្យហ្នឹងត្រូវបាននិយាយដោយអង្គជំនុំជម្រះ ដោយសហព្រះរាជអាជ្ញាពីរបីថ្ងៃកន្លងមកនេះ។ មេធាវីការពារក្តីស្នើភ្លាមៗ សុំឲ្យអង្គជំនុំជម្រះថ្កោលទោសការអះអាងរបស់នាយករដ្ឋមន្ត្រីទៅលើរឿងកូនក្តីរបស់ខ្ញុំនិយាយពីបទប្រល័យពូជសាសន៍ ហើយទាមទារកុំឲ្យធ្វើសេចក្តីសន្និដ្ឋាន ឬក៏យោបល់បែបនោះទៀត បើធ្វើវាបំពានទៅលើសិទ្ធិរបស់កូនក្តីរបស់ខ្ញុំ។

ក្រៅពីវិធានការដើម្បីដោះស្រាយបញ្ហានេះ អង្គជំនុំជម្រះបានធ្វើកិច្ចការរបស់ខ្លួន គឺឆ្លើយទៅនឹងសំណួរដោយសម្ងាត់ ដោយអនុញ្ញាតឲ្យមានយោបល់របស់នាយករដ្ឋមន្ត្រីកាន់តែខ្លាំងឡើង។ ហើយក្នុងរយៈពេលប៉ុន្មានក្រោយ អង្គជំនុំជម្រះបានបញ្ជាក់ថា "យើងពេញចិត្តមិនឆ្លើយតបជាការប្រតិកម្មទៅទៀត" បញ្ចប់សេចក្តី។ មួយសប្តាហ៍ក្រោយមក អង្គជំនុំជម្រះក៏មិនបានថ្កោលទោសការអះអាងរបស់នាយករដ្ឋមន្ត្រីទៅលើការនិយាយពីពិរុទ្ធភាពកូនក្តីខ្ញុំទេ ក្នុងរយៈកន្លងមកគឺនាយករដ្ឋមន្ត្រី ហ៊ុន សែនបានបន្តនិយាយជាសាធារណៈ ដោយសង្ខេបពីពិរុទ្ធភាពរបស់លោក នួន ជា។

មេធាវីការពារក្តីមានការខកចិត្ត ដោយសារអង្គជំនុំជម្រះគឺមិនបានជម្រាបជូនសាធារណជនឲ្យបានដឹងថា អំពីការបញ្ជាក់ពីលោក ហោ ណាំហុង ជារដ្ឋមន្ត្រីការបរទេសលើកូនក្តីរបស់ខ្ញុំ ហើយអង្គ

ជំនុំជម្រះក៏បានកាត់ផ្តាច់មីក្រូដែលយើងបានបញ្ជាក់ជាញឹកញាប់នៅក្នុងអង្គជំនុំជម្រះ។ ជាការឆ្លើយតបទៅនឹងនេះ យើងបានស្នើឲ្យមានការកោះអញ្ជើញលោក ហោ ណាំហុង ដើម្បីបង្ហាញជាសាក្សីនៅតុលាការនេះ។ ប៉ុន្តែអង្គជំនុំជម្រះបានបន្តបដិសេធ ហើយក៏មិនបានផ្តល់សំអាងហេតុឲ្យបានត្រឹមត្រូវទេ ជាពិសេសគឺទាក់ទងនឹងប្រតិកម្មទៅនឹងការបំភិតបំភ័យរបស់លោក ហោ ណាំហុង។ ប៉ុន្តែអង្គជំនុំជម្រះ ដូចការិយាល័យចៅក្រមស៊ើបអង្កេត ដូចអង្គបុរេអង្គជំនុំជម្រះដែរ គឺបានបដិសេធមិនបានដោះស្រាយបញ្ហានោះទេ។ ជាពិសេសនិយាយអំពីសិទ្ធិរបស់គាត់ក្នុងការទទួលបានយុត្តិធម៌ ហើយនិងសិទ្ធិសច្ចៈធារណ៍នាទោសរបស់គាត់ ហើយជាពិសេសគាត់ សិទ្ធិរបស់គាត់ក្នុងការទទួលការជំនុំជម្រះពីតុលាការដែលឯករាជ្យ។

[១១:១០:៣២]

លោក លោកស្រីចៅក្រម! បញ្ហានេះ គឺថាខ្ញុំបានបញ្ចប់អំពីការបរាជ័យខាងនីតិវិធីនៅក្នុងការជំនុំជម្រះនេះ ហើយមុននឹងជូនវេទិកាទៅសហសេវិកជាតិ សុន អរុណ ដើម្បីបញ្ជាក់អំពីប្រវត្តិកូនក្តីរបស់ខ្ញុំ ហើយនិងតួនាទីរបស់គាត់នៅក្នុងបដិវត្តសង្គមនិយមកម្ពុជានោះ។ ខ្ញុំសូមបញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្ញុំអំពីធម្មានុរូបនៃសាលាក្តីនេះ ជាពិសេសមតិទាំងអស់នេះ ឆ្លុះបញ្ចាំងអំពីផ្នែកអ្វីដែលខ្ញុំបានបញ្ជាក់ជាសង្ខេបកាលពីខែមុន។ ហើយភាពបន្ទាន់ដែលត្រូវធ្វើឃោបល់នៅក្នុងសាធារណៈនោះ គឺអំពីសាលាក្តីអង្គជំនុំជម្រះនេះ គឺក្លាយកាន់តែមានលក្ខណៈច្រើនឡើង អំពីសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានៅក្នុងប៉ុន្មានថ្ងៃចុងក្រោយនេះ។ ជាពិសេសម្សិលមិញនេះ គឺបានបង្កើនឲ្យមានវោហាសាស្ត្រខឹងសម្បាកាន់តែខ្លាំងឡើង។ សហព្រះរាជអាជ្ញាបានចាប់ផ្តើមធ្វើការបង្ហាញអំពីព្រឹកថ្ងៃព្រហស្បតិ៍នោះ និយាយហើយថា អំពីលក្ខណៈកុម្មុយនីស្តនិយម។ គឺថាជាទស្សនវិស័យរបស់កុម្មុយនីស្តត្រូវតែបញ្ជាក់ចំពោះមុខអង្គជំនុំជម្រះនេះ។ ប៉ុន្តែអ្វីដែលយើងបានឃើញពីសហព្រះរាជអាជ្ញា ជាពិសេសសហព្រះរាជអាជ្ញាអន្តរជាតិនោះ អាចរៀបរាប់បានថា គឺជាការវាយប្រហារទៅលើមនោគមន៍វិជ្ជាពីក្នុងមកខាងក្រៅ។ ហើយនិងវាជាការវាយប្រហារទៅលើលទ្ធិកុម្មុយនីស្ត ហើយនិងអត្ថប្រយោជន៍កុម្មុយនីស្តតែប៉ុណ្ណោះ។

[១១:១២:១០]

ប្រសិនបើនៅក្នុងការជំនុំជម្រះ ការអះអាងរបស់សហព្រះរាជអាជ្ញានោះ គឺអំពីបទឧក្រិដ្ឋ ប៉ុន្តែគប្បីតែផ្តោតអាមុរណ៍ទៅលើអង្គហេតុ។ សហព្រះរាជអាជ្ញាក៏បានបង្ហាញពីភស្តុតាង -- មិនបានបង្ហាញពីចេតនារបស់ នួន ជា ក្នុងការសម្លាប់ទាហាន លន់ នល់ ទេ។ គេបង្ហាញថា កូនក្តីរបស់យើងមាន

ចេតនាលុបបំបាត់ក៏គាត់មិនបានបង្ហាញដែរ។ ប៉ុន្តែផ្ទុយទៅវិញ អ្វីដែលយើងបានដឹងពីសហព្រះរាជអាជ្ញានោះ គឺជាកិច្ចប្រឹងប្រែងរបស់គាត់ដើម្បីកំណត់ថាបក្សកុម្មុយនីស្តកម្ពុជាខុសច្បាប់។ ហើយប្រាប់អង្គជំនុំជម្រះថាមិនមែនជាចលនានយោបាយទេ ជាចលនាឧក្រិដ្ឋជន។ បង្ហាញភស្តុតាងដើម្បីថា ភស្តុតាងនីមួយៗដែលថា បក្សកុម្មុយនីស្តកម្ពុជាមិនបានព្យាយាមបង្កើតនយោបាយសេដ្ឋកិច្ច ដែលគេជឿជាក់ពិតប្រាកដនោះទេ។ ប៉ុន្តែផ្ទុយទៅវិញ បញ្ជាក់ម្តងហើយម្តងទៀត ពាក្យថា "ទាសករ" ហើយនិង "ដាក់ឲ្យទៅទាសករ" ម្តងហើយម្តងទៀត ជាបន្តបន្ទាប់។

យើងសូមឲ្យអង្គជំនុំជម្រះពិចារណាបញ្ហា ហេតុអ្វីបានជាសហព្រះរាជអាជ្ញាចាត់ទុកថាបញ្ហានេះសំខាន់ ដើម្បីប្រើពាក្យថា "ទាសករ" នេះច្រើនដងម្ល៉េះ។ ច្បាប់តម្រូវឲ្យមានអ្វីដែលសាមញ្ញជាងហ្នឹង។ ច្បាប់តម្រូវឲ្យមានភស្តុតាងថាកូនក្តីរបស់ខ្ញុំបានធ្វើ ដោយមានចេតនា ដើម្បីប្រព្រឹត្តនៃអំពើដែលគេចាត់ទុកថាជាឧក្រិដ្ឋតាមច្បាប់។ ប្រសិនបើភស្តុតាងពីចេតនានោះមាន សហព្រះរាជអាជ្ញាប្រហែលជាអាចនឹងយោងទៅរកភស្តុតាង ហើយបង្ហាញភស្តុតាងអំពីការទទួលខុសត្រូវរបស់ នួន ជា។ ផ្ទុយទៅវិញ ពួកគាត់បានព្យាយាមមានបង្ហាញពីអ្វីដែលទូលំទូលាយ។ ពួកគាត់បានបញ្ចុះបញ្ចូលឲ្យអង្គជំនុំជម្រះថា បក្សកុម្មុយនីស្តកម្ពុជាមានគោលបំណងឧក្រិដ្ឋ។ ដូចដែលបានឃើញ គឺថានេះជាអះអាងថា ទោះបីជាសហចៅក្រមស៊ើបអង្កេតមិនបានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយផង។ ហើយមិនមែនជាការអះអាងថាដែលសហព្រះរាជអាជ្ញាខ្លួនឯងបានបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនេះផងដែរ។

[១១:១៤:២៦]

សហព្រះរាជអាជ្ញាអន្តរជាតិបាននិយាយអំពីអ្នកឈ្នះ ហើយនិងអ្នកចាញ់។ យើងក៏ដូចគ្នាដែរ យើងយល់ស្របថា មានអ្នកចាញ់ និង អ្នកឈ្នះ។ អ្នកឈ្នះ គឺសហរដ្ឋអាមេរិក ហើយនិងសម្ព័ន្ធមិត្តរបស់គេ។ អាមេរិកក៏បានឈ្នះសង្គ្រាមមនោគមន៍វិជ្ជាប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត។ អ្នកឈ្នះជាទី២ ហើយរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃនេះឯងជាអ្នកឈ្នះ។ មេដឹកនាំរដ្ឋាភិបាលបច្ចុប្បន្នឈ្នះសង្គ្រាម ហើយនិងត្រួតត្រាលើកម្ពុជា។ សង្គ្រាមដែលបានចាប់ផ្តើមនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែដែលអាចទៅរួចនៅថ្ងៃដំបូងៗនៃកម្ពុជាប្រជាធិបតេយ្យ ហើយបានបន្តជាទម្រង់យោធារហូតដល់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានដួលរលំនៅឆ្នាំ១៩៩៨។ តើចំណុចទាំងពីរហ្នឹងដូចម្តេច? គឺថាយើងមើលថាក្រុមទាំងពីរខុសគ្នាតើវាដូចគ្នាដែរឬទេ? អ្វីដែលដូចគ្នានោះគឺថា ក្នុងអត្ថប្រយោជន៍ក្នុងការធានាប្រវត្តិសាស្ត្រកម្ពុជា គឺត្រូវ

ដាក់ទោសទៅលើលទ្ធិកុម្មុយនីស្តកម្ពុជាកម្ពុជាឲ្យបានខ្លាំងបំផុត។ ចំពោះអាមេរិកាំង និងសម្ព័ន្ធមិត្ត គឺរុញឲ្យលិទ្ធិកុម្មុយនីស្តកម្ពុជាគឺស្ថិតនៅក្នុងយុត្តិធម៌ជាមូលដ្ឋានមួយពាក់កណ្ដាលសតវត្សរ៍នៅក្នុងចុងក្រោយនោះ គឺបង្ហាញពីបទឧក្រិដ្ឋដ៏អាក្រក់ ប៉ុន្តែខ្លួនគេថាជាអ្នកការពារពិភពលោកទល់នឹងកុម្មុយនីស្តទៅវិញ។ ប៉ុន្តែមេដឹកនាំកម្ពុជា រដ្ឋាភិបាលកម្ពុជា ការដាក់ទោសពួកកុម្មុយនីស្តខ្មែរ គឺអាចនឹងជាយុត្តកម្មឲ្យគេមានអំណាចដោយធម្មានុរូប។ តាមពិតគឺយុត្តកម្មជាបន្តដែលអះអាងដូចជានាយករដ្ឋមន្ត្រីព្រមានការបះបោរស៊ីវិល ហើយនិងបក្សផ្សេងទៀតក្នុងការយកអំណាច គឺជាភស្តុតាងបន្ទាក់។ នេះហើយជាមូលហេតុគឺយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ គឺជាដំណើរមួយដ៏វែងក្នុងការចោទប្រកាន់គ្រប់ភាគី។ ការជំនុំជម្រះដែលផ្ដោតអារម្មណ៍ទៅលើភាគីតែមួយនៃជម្លោះ មិនមែនភាគីម្ខាងទៀត។ ហើយភាគីម្ខាងទៀតមិនអាចរួចផុតពីការសង្ស័យដែលគេបានប្រើជាឧបករណ៍នៃអំណាចនយោបាយ។ ការជំនុំជម្រះបែបនេះគឺមិនមែនរួចផុតពីការសង្ស័យដែលគេបានប្រើជាវិធីសាស្ត្រដើម្បីបញ្ជាក់តែភាគីម្ខាងដែលសម្រេចថាពិតប្រាកដថាជាការរៀបរាប់ត្រឹមត្រូវនៃប្រវត្តិសាស្ត្រនោះ។ គ្មានការជំនុំជម្រះព្រហ្មទណ្ឌអន្តរជាតិណាមួយដែលមានការព្រួយបារម្ភដែលទាក់ទងទៅនឹងតុលាការយោធានៅចុងបូព៌ា ដែលគេស្គាល់ថាសាលាក្ដីតូក្យូ ដែលបាននិយាយនៅក្នុងមតិជំទាស់គឺថាចៅក្រម រ៉ាដ ដាបីណូ ប៉ាល់*(តាមសូរស័ព្ទ)* បានទទួលស្គាល់ថា៖ ការជំនុំជម្រះនោះ គឺថាឆ្លុះបញ្ចាំងអំពីគំនិតនៃយុត្តិធម៌អាចបញ្ជាក់ជាការសងសឹក។ ហើយគាត់បញ្ជាក់ថាគឺមិនស្របទៅនឹងគំនិតនៃយុត្តិធម៌អន្តរជាតិទេ។ ប៉ុន្តែគ្រាន់តែបញ្ជាក់ថា រដ្ឋដែលចាញ់ដែលចុះចាញ់ ដែលថាបុគ្គលរបស់ខ្លួនគេដែលត្រូវស្ថិតនៅក្រោមយុត្តាធិការតុលាការអន្តរជាតិចំពោះការដាក់ទោសពីបទឧក្រិដ្ឋសង្គ្រាម។ រដ្ឋដែលជោគជ័យក៏ដូចគ្នា ត្រូវតែបញ្ជូនយុត្តាធិការរបស់ខ្លួនទៅលើបុគ្គលអ្នកដែលបានបំពានទៅលើច្បាប់សង្គ្រាមនៅក្នុងលក្ខណៈឯករាជ្យ និងអព្យាក្រិត្យនៅក្នុងតុលាការអន្តរជាតិដែរ។ សូមបញ្ចប់សេចក្ដីដកស្រង់។

[១១:១៨:០៩]

អ្នកសង្កេតបានឆ្លុះបញ្ចាំងអំពីសាលាក្ដីតូក្យូនៅប៉ុន្មានឆ្នាំចុងក្រោយដែលស្រប ពិនិត្យមើលសាលាក្ដីមួយចំនួនអំពីនីតិវិធី ហើយនិងកង្វះខាតនីតិវិធីរចនាសម្ព័ន្ធ។ រីឆាត មីនែរ *(Richard Minear)* នៅក្នុងសៀវភៅរបស់គាត់ដែលថាយុត្តិធម៌សម្រាប់អ្នកឈ្នះនៅក្នុងសាលាក្ដីតូក្យូ បានរិះគន់សាលាក្ដីនោះដោយហេតុថា គាត់និយាយថា៖ “យុត្តិធម៌នៅក្នុងសាលាក្ដីតូក្យូហ្នឹង ក៏បានចេញមកពីអ្នកឈ្នះតែប៉ុណ្ណោះ”។ ចប់សេចក្ដីដកស្រង់។

មេធាវីការពារក្តីនៅទីនោះបានអះអាងថា "ដោយមិនគិតពីសុចរិតភាពទាំងស្រុងនៃបុគ្គលសមាជិកម្នាក់ៗនៃសាលាក្តីនេះ ពួកគេមិនអាចនៅក្នុងកាលៈទេសៈនៅក្នុងការតែងតាំង គឺមិនមានអព្យាក្រិត្យភាពទេ។ នៅក្នុងកាលៈទេសៈនោះ ការជំនុំជម្រះនៅក្នុងបច្ចុប្បន្ន ហើយនៅក្នុងប្រវត្តិគឺមិនអាចរួចផុតពីការសង្ស័យទាក់ទងទៅនឹងនីត្យានុកូលភាព ភាពយុត្តិធម៌ និងអព្យាក្រិត្យនោះទេ"។ ចប់សេចក្តីដកស្រង់។

រីឆាត មីនែរ នៅក្នុងសៀវភៅរបស់គាត់នោះ គាត់និយាយថា៖ "ការចាត់តាំងរបស់ចៅក្រម គឺគ្រាន់តែជាលក្ខណៈគួរឲ្យសោកស្តាយសម្រាប់តែអ្នកឈ្នះតែប៉ុណ្ណោះ។ ហើយជាពិសេស គឺចោទជាបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងសាលាក្តីនេះ ភាពមិនអព្យាក្រិត្យ។ ដូច្នេះការរិះគន់នេះ ក៏អនុវត្តចំពោះ អ.វ.ត.ក ផងដែរនៅពេលដែលករណីមួយចំនួនដែលស្ថិតនៅក្នុងការជំនុំជម្រះ។ ជាពិសេសដោយប្រជាជាតិដែលជាអ្នកឈ្នះទាំងស្រុង។ ភាពចម្រុះនៃអង្គជំនុំជម្រះផ្ទុះបញ្ចាំងពីភាគីអ្នកឈ្នះទាំងស្រុង។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏ក្លាយទៅជាមេដឹកនាំបក្សប្រជាជនកម្ពុជា ដែលមានឥទ្ធិពលទៅលើភាគីចៅក្រមមួយចំនួនដូចជាប្រជាជាតិមួយចំនួននៅសហរដ្ឋអាមេរិក បារាំង ហើយនិងអ្នកសម្ព័ន្ធមិត្តជិតស្និទ្ធនោះដែរ ហើយនិងអន្តរជាតិដទៃទៀត។

[១១:២០:១៣]

ដូចសាលាក្តី តូក្យូនោះដែរ គឺថាចៅក្រមបានកើតឡើង និងរៀនសូត្រនៅក្នុងសង្គមមូលធននិយម ហើយក៏ពិបាកនឹងអាចរក្សាសុចរិតភាព ភាពអព្យាក្រិត គ្មានល្អៀង ហើយធ្វើការវិនិច្ឆ័យអំពីនយោបាយសហភាវូបនីយកម្មកុម្មុយនីស្តបានដែរ។ ហើយបាននៅចាំថាសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការទទួលស្គាល់ប្រព័ន្ធសេដ្ឋកិច្ចសមូហភាវូបនីយកម្មនៅក្នុងរយៈកាលបង្កើតសហករណ៍នោះមិនអាចចាត់ទុកជាឧក្រិដ្ឋកម្មទេ គេនិយាយថាសមូហភាវូបនីយកម្មគឺជាឧក្រិដ្ឋ។ ប៉ុន្តែសហភាវូបនីយកម្មគឺថាមិនមែនជាគោលនយោបាយឧក្រិដ្ឋទេ។ ប៉ុន្តែសហព្រះរាជអាជ្ញាបាននិយាយថាតើសេដ្ឋកិច្ចសហករណ៍នោះតើជាឧក្រិដ្ឋដូចម្តេចបាន? ប៉ុន្តែគេមិនអាចពន្យល់។ បក្សកុម្មុយនីស្តកម្ពុជាអាចអនុវត្តគោលការណ៍សហករណ៍ដោយមិនប្រព្រឹត្តបទឧក្រិដ្ឋបាននោះទេ ប៉ុន្តែយើងឃើញគ្រប់ៗគ្នាថា ចៅក្រមដែលយល់ច្បាស់ពីសង្គមកុម្មុយនីស្តដែលមិនមានទីផ្សារជារឿងទូទៅ នៅពេលដែលសេដ្ឋកិច្ចនោះគឺមិនមានទេ។ បក្សកុម្មុយនីស្តកម្ពុជាជារដ្ឋមួយគឺជាមធ្យោបាយ ហើយគេអាចនឹងឆ្លើយបានតាមទិសដៅខុសគ្នាតាមចៅក្រមនៅក្នុងអង្គជំនុំជម្រះនៅថ្ងៃនេះ។

[១១:២១:៥១]

លោកប្រធាន ចំណុចហ្នឹងគឺថាមិនបដិសេធសុចរិតភាពរបស់អង្គជំនុំជម្រះនេះទេ ប៉ុន្តែជារឿងវាយប្រហារអំពីគោលការណ៍សីលធម៌។ ចំណុចនេះគឺយើងសួរថាតើមានភាពស្វាមីភក្តិទៅលើទស្សនៈជាមូលដ្ឋានដែរឬទេ ដែលថាអាចនឹងជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងគោលនយោបាយដែលត្រូវបានអនុម័តនៅក្នុងគោលបំណងនៃការនៃការអនុវត្តគម្រោងការនោះ។ យើងខ្ញុំសូមជម្រាបថា ចម្លើយរបស់នោះគឺថាលោកចៅក្រមមិនអាចធ្វើបែបនោះទេ។ លទ្ធភាពរបស់អង្គជំនុំជម្រះគឺត្រូវពិនិត្យមើលការបកស្រាយប្រវត្តិសាស្ត្រដែលថាខ្លួនជាអ្នកជំនាញនៅក្នុងការជំនុំជម្រះនេះ ដោយស្តាប់តែអ្នកជំនាញដែលពិនិត្យឃើញកម្ពុជាប្រជាធិបតេយ្យថា អ្វីដែលពួកគេធ្វើដូចដែលយើងធ្វើ អង្គជំនុំជម្រះគិតត្រូវតែធ្វើការវិភាគដូចជាការសំណេររបស់ពួកអង់គ្លេ -- បារាំងជាដើមនោះ ហើយនិងអាចនឹងអនុវត្ត។

[១១:២៣:០០]

លោក នួន ជា អាចបង្ហាញជូនអង្គជំនុំជម្រះថាគាត់មិនព្យាយាមដាក់ទៅជាទាសករ ឬក៏លុបបំបាត់នោះទេ តែក្នុងករណីដែលយើងធ្វើឲ្យអង្គជំនុំជម្រះយល់ថា វាជាអ្វីដែលគាត់បានព្យាយាមធ្វើ។ វាមិនទំនងថា អង្គជំនុំជម្រះអាចនឹងគ្រប់គ្រងនឹងបានទទួលព័ត៌មានពីមនុស្សមួយចំនួនដែលជាអរិភាពទៅនឹងគាត់គឺអ្នកដែលគិតថាសហភាពវូបនីយកម្មនោះគឺជាបទឧក្រិដ្ឋ។ មានតែអង្គជំនុំជម្រះដែលមានចេតនាចង់យកចំណាត់ការផ្សេង ឬក៏ទស្សនវិស័យទូលំទូលាយអាចនឹងផ្តល់ការជំនុំជម្រះដល់កូនក្តីរបស់ខ្ញុំដោយយុត្តិធម៌បាន។ មានតែអង្គជំនុំជម្រះដែលអាចពិនិត្យឃើញថា អំពើនៃអ្នកផ្សេងទៀតដែលច្រើនអាចនឹងយកមកឲ្យទទួលខុសត្រូវទើបអាចនឹងវាយតម្លៃអំពើរបស់លោក នួន ជា ដោយអព្យាក្រិត មិនមែនដោយគោលបំណងគ្រាន់តែឈ្នះសង្គ្រាមចិត្តសាស្ត្រ និងសង្គ្រាមនយោបាយប៉ុណ្ណោះទេ។ នេះហើយជាមូលដ្ឋានដ៏សំខាន់ដែលយើងពិនិត្យឃើញថាជាយុត្តិធម៌របស់អ្នកឈ្នះ។ គឺដោយមូលហេតុទាំងអស់នេះ ហើយដែលថាកូនក្តីរបស់យើងទាមទារជាបន្តបន្ទាប់ថា យុត្តាធិការនៃសាលាក្តីនេះគឺថា គ្របដណ្តប់លើវិសាលភាពដ៏ទូលំទូលាយ។

[១១:២៤:៣៨]

ការកម្រិតនៃយុត្តាធិការនេះ គឺតាមពិតនោះគឺថាត្រូវបានរំខានក្នុងការងាររបស់ខ្លួនរាវាំង និងកិច្ចប្រឹងប្រែងស្វែងរកការពិត។ ពាក្យដំបូងរបស់លោក នួន ជា ទៅសាលាដំបូងនោះគឺថា សូមដកស្រង់៖ “ខ្ញុំយល់ឃើញថា តុលាការនេះគឺមិនយុត្តិធម៌សម្រាប់ខ្ញុំទេ តាំងពីដំបូងមកពីព្រោះតែមានអង្គហេតុមួយចំនួនតូចដែលត្រូវបានពិចារណាដោយតុលាការ។ ខ្ញុំនិយាយថាមានតែខ្លួនក្រពើទេដែលត្រូវយកមកជម្រះ

ក្បាលនិងកន្ទុយដែលជាផ្នែកសំខាន់ប្រចាំថ្ងៃមិនត្រូវយកមកទេ។ នោះមានន័យថា មូលហេតុនិងផលវិបាកនៃអំពើនោះដែលកើតឡើងមុនឆ្នាំ១៩៧៥ ហើយនិងក្រោយឆ្នាំ១៩៧៩ មិនអើពើដោយតុលាការនេះទេ"។ សូមបញ្ចប់សេចក្ដីដកស្រង់។ មានតែក្បាលនិងកន្ទុយនៃក្រពើទេត្រូវបានយកមកពិចារណាដែលអង្គជំនុំជម្រះអាចយល់ថាតើមានភាពស្មោះត្រង់ប៉ុនណា? ដែលសហព្រះរាជអាជ្ញាលើកឡើងពីពីរបីថ្ងៃកន្លងមកនេះ។ មានតែអង្គជំនុំជម្រះមើលទិដ្ឋភាពទូទៅអំពីសេចក្ដីសម្រេចកូនក្ដីរបស់ខ្ញុំ ហើយនិងគោលនយោបាយដែលបក្សកុម្មុយនីស្តកម្ពុជាអនុម័ត ដែលយើងយល់ថាលោក នួន ជា មិនមានចេតនាបង្កើតរដ្ឋទាសករកម្ពុជាប្រជាធិបតេយ្យទេ។ ហើយគាត់មិនមែនជាឃាតករបោកបញ្ឆោតទេ ដូចដែលគាត់ធ្វើឱ្យគេជឿនោះទេ។ លោក លោកស្រីចៅក្រមដឹងហើយ គឺថាគប្បីតែបង្ហាញពីក្បាល និងកន្ទុយរបស់ក្រពើទើបបានដឹងច្បាស់។

ឥឡូវនេះខ្ញុំសូមឱ្យលោក សុន អរុណ ដើម្បីជម្រាបជូនអង្គជំនុំជម្រះពីបញ្ហានេះ។ សូមអរគុណ។

[១១:២៦:៥៧]

**លោក សុន អរុណ៖**

សូមអរគុណលោក វ៉ិចទ័រ កូប៉េ។ សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំបាទ សុន អរុណ ជាសហមេធាវីជាតិការពារលោក នួន ជា។

នៅក្នុងការបន្តធ្វើសេចក្ដីសន្និដ្ឋានពីសហភាតារបស់ខ្ញុំគឺលោក វ៉ិចទ័រ កូប៉េ សហមេធាវីអន្តរជាតិ, ជាបឋមខ្ញុំសូមលើជម្រាបជូនអង្គសវនាការអំពីសេចក្ដីសន្និដ្ឋានបញ្ចប់ក្នុងករណី00២/0១ របស់ខ្ញុំមានដូចតទៅ៖

ជាបឋមខ្ញុំសូមជូនសារណាអំពីចំណែកទី១របស់ខ្ញុំគឺ មូលហេតុដែលនាំឱ្យ នួន ជា តស៊ូចូលក្នុងបដិវត្តន៍។ ពីព្រោះអីថ្ងៃនេះខ្ញុំមានពីរចំណែក សារណាពីរចំណែក មួយចំណែកគឺមូលហេតុដែលនាំឱ្យ នួន ជា ចូលក្នុងបដិវត្តន៍ និងមួយចំណែកទៀតអំពីតួនាទីរបស់លោក នួន ជា។

កាលនៅជាក្មេងប្រុសម្នាក់លោក នួន ជា មានការខកខានយ៉ាងខ្លាំងដោយសារការគាបសង្កត់របស់បារាំងមកលើប្រជាជនសាមញ្ញខ្មែរ។ គាត់បានឃើញស្ថានភាពរបស់អ្នកក្រ ហើយគាត់មានការរន្ធត់។ បទពិសោធន៍ទាំងនេះបង្កើតគំនិតដ៏ជ្រាលជ្រៅមួយនៅក្នុងខ្លួន ដើម្បីរំដោះកម្ពុជា និងប្រជាជនកម្ពុជាពីការជិះជាន់កេងប្រវ័ញ្ចរបស់បរទេស និងបណ្ដាញគាបសង្កត់នៃអំណាច និងការគ្រប់គ្រង។

[១១:២៨:៤៧]

លោក នួន ជា ជឿជាក់ថា របបកុម្មុយនីស្តគឺជាថ្នាំបន្សាបរបស់កម្ពុជាសម្រាប់ជំងឺទាំងនេះ។ សម្រាប់លោក នួន ជា បញ្ហាសំខាន់ៗដូចជាអាណានិគមរបស់បារាំង ប្រវត្តិដ៏វែងរបស់ថៃ និងការឈ្លានពានរបស់វៀតណាម និងការបំផ្លាញដ៏ធ្ងន់ធ្ងរបង្កដោយចក្រពត្តិអាមេរិក គឺជាផ្នែកនៃក្បាលនិងកន្ទុយរបស់សត្វក្រពើ។ វាមិនមែនប្រធានបទបែបទ្រឹស្តីសម្រាប់ការពិភាក្សារៀនសូត្រនោះទេ ចំពោះលោក នួន ជា វាជាការពិតដែលបណ្តាលឲ្យមានភាពក្រីក្រដ៏រ៉ាំរ៉ៃរបស់កម្ពុជា ភាពក្រីក្រដែលបណ្តាលមកពីការគាបសង្កត់របស់វណ្ណៈ និងគាំទ្រជ្រៀតជ្រែកដ៏ហិង្សា និងឱកាសនិយមរបស់ពួកបរទេស។

ភាពឈឺចាប់របស់ប្រជាជនកម្ពុជានៅក្រោមការគ្រប់គ្រងរបស់ពួកអាណានិគម បានធ្វើឲ្យ នួន ជា រន្ធត់ចិត្ត និងយកមកពិចារណាថា ប្រជាជនខ្មែរគ្មានអំណាចអ្វីទាំងអស់ ពួកគេត្រូវបានកេងប្រវ័ញ្ចដោយពួកអាណានិគមបារាំង អាជ្ញាធរបារាំងទាមទារពន្ធដារពីកសិករក្រីក្រ ដោយគំរាមកំហែងជាហិង្សាស្របពេលនោះកាន់កាប់ផ្តាច់មុខនូវរាល់វត្ថុធាតុដើម ដែលជាកម្មសិទ្ធិដ៏ពេញច្បាប់របស់ប្រទេស -- ប្រជាជនកម្ពុជា។ ខណៈដែលបារាំងទាមទារក្នុងការត្រួតត្រាកម្ពុជាដើម្បីប្រយោជន៍របស់ប្រជាជនសាមញ្ញតាមការពិតនយោបាយរបស់ពួកគេធ្វើឲ្យប្រាកដថា “ប្រជាជនរណប”។ ហើយផលចំណេញរបស់បារាំងនៅតែមានសភាពខ្ពស់ ចំណែកប្រជាជនកម្ពុជាវិញមិនបានទទួលអ្វីទាល់តែសោះ។

[១១:៣១:០៣]

សេវាអប់រំ និងសុខាភិបាលមិនត្រូវបានយកចិត្តទុកដាក់ឡើយ ហើយអគ្គិសនី ហើយនិងទឹកប្រើប្រាស់មិនមាននោះទេនៅក្រៅទីក្រុងភ្នំពេញ។ រយៈពេលកន្លងទៅលោក នួន ជា បានយល់ថា “ភាពគ្មានសមភាពទាំងនេះមិនត្រូវបានកំណត់ត្រឹមរយៈពេលខ្លីនៃការគ្រប់គ្រងរបស់បារាំងនោះទេ”។ គាត់បានយល់ច្បាស់ថា អាណានិគមរបស់បារាំងបានត្រឹមតែបង្អាក់ការគ្រប់គ្រងដែលមានរាប់សតវត្សរ៍របស់ប្រទេសជិតខាងធំៗរបស់កម្ពុជាប៉ុណ្ណោះ។

អស់រយៈពេលរាប់រយឆ្នាំមកហើយ ពួកសៀម និងអាណាចក្រជាច្រើន ដែលបច្ចុប្បន្នជាវៀតណាមសម័យថ្មីបានវាយលុកដណ្តើមគ្រប់គ្រង និងកាន់កាប់ផ្នែកធំនៃរដ្ឋកម្ពុជាសម័យទំនើប។ ដោយមានករណីលើកលែងខ្លះៗ ដែលមេដឹកនាំកម្ពុជាបានសហការដោយឥតអៀនខ្មាស់ក្នុងវដ្តនៃការកេងប្រវ័ញ្ចទាំងនេះ។ ការខិតខំប្រឹងប្រែងរបស់សម្តេច សីហនុ បន្ទាប់ពីឆ្នាំ១៩៥៣ ដើម្បីបង្ហាញនូវរបបសង្គមនិយមថាជារដ្ឋាភិបាលកម្ពុជាយ៉ាងពិតប្រាកដ។ ដឹកនាំរដ្ឋរំដោះថ្មីមួយជាខ្លឹមសារគ្មានភាពខុសគ្នានោះទេ ជាមូលដ្ឋានរបបរបស់សម្តេច នរោត្តម សីហនុ មិនខ្វល់នឹងជីវិតនិងជីវភាពរបស់ប្រជាជនកម្ពុជាដ៏ច្រើន

លើសលប់ដូចដែលបារាំងបានធ្វើពីមុនដែរ។ នួន ជា ដឹងថាអ្វីមួយត្រូវតែផ្លាស់ប្តូរ ដំបូងគាត់ព្យាយាមកែប្រែប្រកបដោយប្រសិទ្ធភាពបែបនយោបាយនៅក្នុងប្រព័ន្ធនេះ ប៉ុន្តែគាត់ដឹងភ្លាមៗថា "អ្នកដែលព្យាយាមតទល់នឹងរដ្ឋាភិបាលត្រូវបានចាប់ដាក់គុក និងទទួលរងអំពើហិង្សា និងភាពឃោរឃៅ"។ គាត់បានយល់ថា"ក្រោមអំណាចគ្រប់គ្រងរបស់សម្តេច នរោត្តម សីហនុ (សូមទោស) ក្រោមអំណាចគ្រប់គ្រងរបស់សម្តេច សីហនុ, លន់ នល់ គាបសង្កត់ប្រជាជនកម្ពុជា និងកសិករតាមតែចិត្តចង់"។ ទីបំផុតបន្ទាប់ពីរយៈពេលជាច្រើនឆ្នាំនៃការបង្ក្រាបនៃសកម្មភាពអហិង្សារបស់អ្នកសង្គមនិយមបក្សកុម្មុយនីស្តកម្ពុជាជ្រើសយកការតស៊ូដោយអាវុធ។

[១១:៣៤:០២]

នៅឆ្នាំ១៩៦២ កម្មាភិបាលប្រដាប់ដោយដឹង និងកាំបិតក្នុងការការពារខ្លួន ប្រឆាំងនឹងហិង្សាបង្កដោយកងកម្លាំងរបស់លន់នល់ បន្ទាប់ពីការបះបោររបស់កសិករនៅសំឡូត ឆ្នាំ១៩៦៧, លន់ នល់ បញ្ជូនទ័ពរាប់ពាន់នាក់ដើម្បីបង្ក្រាបកសិករ។ ជនរងគ្រោះក្នុងអំពើហិង្សានេះ និងកូនរបស់កសិករដែលត្រូវបានសម្លាប់បានវ៉ៃតបតវិញ នៅព្រឹកថ្ងៃទី១៧ មករា ១៩៦៨ ក្រុមតូចនេះបានវាយលុកប៉ុស្តិ៍ប៉ូលិសនៅបាយដំរាំនៅខេត្តបាត់ដំបង និងបានលួចអាវុធប្រាំពីរដើមជាលទ្ធផលនៃព្រឹត្តិការណ៍នោះ។ ការតទល់ដោយអាវុធបានរីកសាយភាយពីកន្លែងមួយទៅកន្លែង ហើយបដិវត្តសង្គមនិយមនៃបក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមឡើង។ បញ្ហាក្នុងស្រុកទាំងនេះហើយដែលបានរួមចំណែកយ៉ាងធំក្នុងការជួយសង្គមនិយមរបស់កម្ពុជា។ ប៉ុន្តែវាជាការវាយរបស់វៀតណាម ដើម្បីឯករាជ្យភាព និងការចូលរួមប្រកបដោយមហន្តរាយរបស់អាមេរិកក្នុងសង្គ្រាមនេះ ដែលជំរុញចលនារំដោះដ៏វ័យក្មេងរបស់កម្ពុជាលេចធ្លោជាការតស៊ូរបស់សាកលលោករបស់ប្រជាជនដែលត្រូវបានគេគាបសង្កត់ប្រឆាំងនឹងការគ្រប់គ្រងពួកបរទេស។ អស់រយៈពេលជាងពីរទសវត្សរ៍ រដ្ឋាភិបាលអាមេរិកាំងបានប្រើហិង្សាបែបយោធា សេដ្ឋកិច្ច និងនយោបាយដ៏លើសលប់ប្រឆាំងនឹងក្រុមកុម្មុយនីស្តក្នុងប្រទេសជិតខាងវៀតណាម និងក្រោយមកជាមិត្តដ៏ជិតស្និទ្ធបំផុតរបស់កុម្មុយនីស្តកម្ពុជា។

[១១:៣៦:១៤]

ការប៉ះទង្គិចបានចូលមកដល់ទឹកដីកម្ពុជានៅឆ្នាំ១៩៦៥។ វាបានរីកធំឡើងនៅឆ្នាំ១៩៦៩ មុនពេលឈានដល់កម្រិតនៃការបំផ្លាញដែលមិនធ្លាប់មានពីមុនមក។ អស់រយៈពេលលើសពីប្រាំបីខែ ដោយគ្មានភាពស្រាកស្រាន្តនៅឆ្នាំ១៩៧៣។ សរុបទាំងអស់ អាមេរិកបានទម្លាក់គ្រាប់បែកចំនួន២.៧៥៦.៩៤១

តោនមកលើប្រទេសកម្ពុជា។ ដែលមានចំនួនច្រើនជាងសរុបជាងចំនួនសរុបប្រើប្រាស់ដោយកងកម្លាំងសម្ព័ន្ធមិត្តទាំងអស់ រួមបញ្ចូលគ្នា អំឡុងពេលសង្គ្រាមលោកលើកទី២ទាំងមូល រួមទាំងគ្រាប់បែកបរិម៉ាណូ ដែលបានទម្លាក់នៅហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី។ បក្សកុម្មុយនីស្តកម្ពុជាតែម្នាក់ឯង បានបាត់បង់បុរស និងស្ត្រី ប្រមាណ១៦.០០០នាក់។

លោក នួន ជា បានរៀនពីទសវត្សរ៍នៃបទពិសោធន៍ដែលជនណាមួយ ស្វះស្វែងដើម្បីលើកតម្កើងឋានៈរបស់ជនក្រក្រី នឹងត្រូវបានគេសងសឹកដោយឆាប់រហ័ស និងប្រកបដោយហិង្សា។ គាត់បានយល់ថា រដ្ឋបរទេសគ្មានថ្ងៃគិតពីផលប្រយោជន៍របស់ប្រទេសកម្ពុជានោះទេ។ លោក នួន ជា និងសមមិត្តរបស់គាត់សម្រេចថា ផ្លូវទៅកាន់យុត្តិធម៌ និងភាពរុងរឿងតែមួយគត់ មាននៅក្នុងរដ្ឋឯករាជ្យ និងត្រឹមត្រូវរបស់កម្ពុជា។ លោក នួន ជា ជឿជាក់យ៉ាងពិតប្រាកដថា របបកុម្មុយនីស្ត គឺជាផ្លូវទៅកាន់សេរីភាព។ គាត់ជឿថាតាមរយៈរបបកុម្មុយនីស្ត រដ្ឋទំនើប និងឯករាជ្យរបស់កម្ពុជាដែលមានសមត្ថភាពក្នុងការផ្តល់ជូនប្រជាជនរបស់ខ្លួន និងអាចត្រូវបានសម្រេច។ គំនិតនេះមិនមែនគួរឲ្យជឿ និងគ្មានហេតុផលនោះទេ។ នៅពេលដែល នួន ជា ចូលរួមក្នុងបក្សកុម្មុយនីស្តថៃ នៅឆ្នាំ១៩៥១ យ៉ាងហោចណាស់ រដ្ឋចំនួន១២ តំណាងជិតមួយភាគបីនៃប្រជាជនពិភពលោក បានកំណត់យកទម្រង់ខ្លះនៃរដ្ឋាភិបាលសង្គមនិយម។

[១១:៣៨:៥៦]

នៅអាស៊ី មហាអំណាចទាំងពីររបស់ទ្វីបនេះ រុស្ស៊ី និងចិន បានកំណត់យករួចមកហើយនូវរដ្ឋាភិបាលទម្រង់ជាសង្គមនិយម។ ប្រទេសជិតខាងទាំងពីររបស់ប្រទេសកម្ពុជា មានចលនាកុម្មុយនីស្តដ៏សកម្ម។ បដិវត្តន៍កុម្មុយនីស្តរបស់វៀតណាមខាងជើង និងសង្គ្រាមរំដោះរបស់គេ គឺជាប្រភេទមួយ និងជាប្រភេទដូចគ្នា ដោយនាំយករបបកុម្មុយនីស្តមកឲ្យប្រជាជនកម្ពុជា បក្សកុម្មុយនីស្តកម្ពុជាសង្ឃឹមថានឹងលុបបំបាត់ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចដែលមិនយុត្តិធម៌។ ពួកគេមិនដែលចង់ធ្វើបាបប្រជាជនសាមញ្ញទេ។ ពួកគេស្វះស្វែងដើម្បីបង្កើតសង្គមប្រាកដដោយសមភាព មិនលះបង់អ្នកមានសម្រាប់អ្នកក្រនោះទេ។ ពួកគេចង់ធ្វើឲ្យកម្ពុជារឹងមាំ និងឯករាជ្យ មិនមែនមានភាពឯកា និងមិនចងសម្ព័ន្ធមិត្តជាមួយប្រទេសណានោះទេ។ បក្សកុម្មុយនីស្តកម្ពុជាសង្ឃឹមថានឹងរំដោះប្រជាជនកម្ពុជាពីកម្លាំងនៃអាណានិគមនិយម ចក្រពត្តិនិយម និងសក្តិភូមិនិយម។ ទាំងទ្រឹស្តី និងការអនុវត្តនៃបដិវត្តសង្គមនិយមរបស់កម្ពុជា បានផ្ទុះបញ្ចាំងពីយុទ្ធសាស្ត្រនោះ។

ក្នុងការកំណត់គោលបំណងនៅពីក្រោយនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាតម្រូវឲ្យមានការយល់ដឹងពីភាសាបដិវត្តន៍ដែលប្រើប្រាស់ដោយបក្សកុម្មុយនីស្តកម្ពុជាដែលជាភាសាប្រើប្រាស់សាមញ្ញ។ លោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ និយាយត្រឹមត្រូវថា បក្សកុម្មុយនីស្តកម្ពុជា បានកំណត់យកទម្រង់ភាសាថ្មីមួយដែលមិនមែនជាបែបផែនធម្មតាសម្រាប់ខ្មែរសម័យមុនបដិវត្តន៍។ ភាសានោះ មានលក្ខណៈពិសេសយ៉ាងជាក់លាក់ក្នុងការប្រើភាសាជាបែបសង្គ្រាម ដើម្បីពណ៌នាការងារសាមញ្ញបំផុត។

[១១:៤១:២០]

កម្មាភិបាលត្រូវបានជំរុញឲ្យធ្វើការវាយលុកយ៉ាងខ្លាំង វាយប្រហារ និងធ្វើឲ្យរស់រវើកនូវមាគ៌ាប្រយុទ្ធប្រមូលផលស្រូវ និងរដូវសាបព្រោះ។ គណៈកម្មការមជ្ឈិមប្រើប្រាស់ភាសាស្រដៀងគ្នា សូម្បីតែនៅក្នុងការពិភាក្សាផ្ទៃក្នុងរបស់គេ ភាសាដូចគ្នា ត្រូវបានប្រើប្រាស់ដើម្បីពណ៌នាការខំប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីផ្សព្វផ្សាយការប្រកាន់ខ្ជាប់នឹងគោលដៅនយោបាយរបស់គេ។ ក្នុងទស្សនៈនៃការប្រើប្រាស់ភាសាហិង្សារបស់បក្សកុម្មុយនីស្តកម្ពុជា ឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាណែនាំកម្មាភិបាលអោយវាយប្រហារ ឬកម្ទេចមូលធននិយម សក្តិភូមិនិយម និង ចក្រពត្តិនិយមអាចត្រឹមតែត្រូវបានបកប្រែក្នុងន័យដូចគ្នាប៉ុណ្ណោះ។ ឯកសារទាំងនេះ តែងតែពិពណ៌នាពីសារៈសំខាន់នៃការកម្ទេចរចនាសម្ព័ន្ធរបស់មូលធននិយម និងសក្តិភូមិនិយម។

ការចង្អុលបង្ហាញមួយនៃការផ្តោតសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា គឺលើប្រព័ន្ធជាជាងប្រជាជនអាចត្រូវបានមើលឃើញក្នុងការខិតខំប្រឹងប្រែងរបស់សហព្រះរាជអាជ្ញា ដើម្បីចង្អុលពីចរិតលក្ខណៈរបស់ឯកសារដោយមិនត្រឹមត្រូវ ដែលមិនបាននិយាយអំពីអ្វីសោះដែលមានការពាក់ព័ន្ធនឹងសត្រូវ។ សហព្រះរាជអាជ្ញាបានអានសម្រង់ឯកសារមួយពាក់ព័ន្ធនឹងការខិតខំប្រឹងប្រែង ដើម្បីកម្ទេច "វណ្ណៈរបបនិងមនោគមន៍វិជ្ជា" ហើយបន្ទាប់មក សង្ខេបឯកសារថាជាការណែនាំអោយកម្ទេច "មនុស្សទាំងនេះ និងវណ្ណៈពួកគេ និងរបបពួកគេ និងមនោគមន៍វិជ្ជាពួកគេ"។ ប្រសិនបើភស្តុតាងពិតនៃគោលបំណងរបស់គណៈមជ្ឈិម ក្នុងការឲ្យកម្ទេចប្រជាជនមានមែន សហព្រះរាជអាជ្ញាត្រូវផ្តល់ជូននូវឯកសារទាំងនោះ ជាជាងប្រើប្រាស់ពាក្យដែលមិនមាននៅក្នុងឯកសារដែលពួកគេបានបង្ហាញ។

[១១:៤៣:៥២]

បក្សកុម្មុយនីស្តកម្ពុជាមិនដែលមានបំណងកសាងសង្គមនិយមតាមរយៈការប្រើហិង្សានោះទេ។ ទស្សនាវដ្តីទង់បដិវត្តចុះទី១០ -- ខែតុលា ឆ្នាំ១៩៧៥ បង្ហាញដូចនេះ "បក្សកុម្មុយនីស្តកម្ពុជាណែនាំឲ្យ

កម្មាភិបាលបន្តការប្រយុទ្ធនឹងវណ្ណៈប្រឆាំង និងសក្តិភូមិនិយម និងមូលធននិយមនៅក្នុងជួរកម្មករនៅក្នុងសហករណ៍ និងជាពិសេសនិយាយថា “ការតស៊ូវណ្ណៈនៅក្នុងសម័យកាលបដិវត្តន៍ថ្មីនេះ មិនមែនក្នុងទម្រង់ជាហិង្សាប្រដាប់អាវុធ សង្គ្រាមបដិវត្តន៍ ឬ ការប្រយុទ្ធបង្ហូរឈាមនោះទេ”។ សម្រាប់ នួន ជា និងបក្សកុម្មុយនីស្តកម្ពុជា ការពារបដិវត្តន៍សង្គមនិយមក្រោយការរំដោះ មានសមាសធាតុពីរសំខាន់គឺការអប់រំ និងការបំបែកបណ្តាញនៃអំណាចនៃវណ្ណៈជិះជាន់គាបសង្កត់។ ហិង្សាមិនមែនជាសមាសធាតុនោះទេ។ ទស្សនាវដ្តីទង់បដិវត្តចុះខែធ្នូ ឆ្នាំ១៩៧២ ពន្យល់ថា៖ “ឥរិយាបថរបស់ពួកគហបតីនៅក្នុងបក្សគួរតែកម្ចាត់ចោលតាមរយៈដំណើរការនៃកម្មកររូបនីយកម្ម សម្រាប់បក្សតាមរយៈគោលជំហរចិត្តសាស្ត្ររបស់ពួកគេ។ ទស្សនាវដ្តីទង់បដិវត្ត ចុះខែកញ្ញា ឆ្នាំ១៩៧៤ ណែនាំកម្មាភិបាលឲ្យអប់រំយុវជនឲ្យមើលឃើញការគាបសង្កត់របស់វណ្ណៈម្ចាស់ដី និងស្វែងរកឲ្យរំដោះខ្លួនពីមនោគមន៍វិជ្ជារបស់ចក្រពត្តិនិយម។ ទស្សនាវដ្តីទង់បដិវត្ត ចុះខែសីហា ឆ្នាំ១៩៧៥ ពន្យល់ថា ការប្រុងប្រយ័ត្នចំពោះសត្រូវទាមទារឲ្យមានវត្តមានយោធាដ៏ខ្លាំងក្លាមួយនៅតាមព្រំដែន រួមផ្សំនិងការអប់រំនយោបាយ និងគោលជំហរប៉ូលីជីពមួយ។

[១១:៤៦:១៥]

លោក ហ្វីលីព ស៊ុសត និយាយត្រូវនៅក្នុងការសរុបសេចក្តីរបស់គាត់ថា សង្គមនិយមរបស់កម្ពុជាមានលក្ខណៈពិសេសក្នុងជំនឿរបស់វា ដែលថា សេចក្តីភ្ញាក់រឭកខាងវណ្ណៈ មិនមាន មិនចេះប្រែប្រួលនោះទេ និងអាចស្ថាបនាឡើងតាមរយៈការអប់រំ និងជីវិតរបស់គេបែបប៉ូលីជីព។ ការជម្រុះចោលនូវបណ្តាញនៃអំណាច ខ្លឹមសារនៃការប្រយុទ្ធនិងប្រព័ន្ធ និងមិនមែនប្រជាជនគឺច្បាស់លាស់។

ទស្សនាវដ្តីទង់បដិវត្តចុះខែតុលា ឆ្នាំ១៩៧៦ ពន្យល់ថា ការបិទផ្សារឆ្នាំ១៩៧២ មិនមែនជាបញ្ហាតូចតាចនោះទេ វាជាចលនាបដិវត្តដ៏ខ្លាំងដែលជាប់គាំងនៅចំហ្រឹងមូលដ្ឋានសេដ្ឋកិច្ចនៃពួកមូលធននិយម និងសក្តិភូមិនិយម។ យើងមិនបានប្រើកម្លាំងយោធាដើម្បីសម្លាប់ពួកគេទេ យើងគ្រប់គ្រងផលិតផលសំខាន់ៗដូចជាអង្ករប្រេង អំបិល សម្លៀកបំពាក់ និងថ្នាំពេទ្យ។ នៅពេលយើងអាចគ្រប់គ្រងផលិតយុទ្ធសាស្ត្រយើងទទួលបានការគ្រប់គ្រងលើសេដ្ឋកិច្ចទាំងមូល។ ដូច្នេះ នៅពេលដែលសង្គមនិយមដំណើរការល្អជាប្រព័ន្ធសេដ្ឋកិច្ចនិងនយោបាយការប្រឆាំងនឹងមនោគមន៍វិជ្ជា និងមិនត្រូវការ ឬចង់បានទៀតនោះទេ។

[១១:៤៨:០០]

នៅក្នុងបរិបទនៃការតស៊ូសង្គមនិយមដ៏ជាក់ច្បាស់នេះ នួន ជា ដឹងថាខ្លួនគាត់ត្រូវបានធ្វើឱ្យច្របូកច្របល់គំនិតដោយសារការខិតខំដ៏ស្វិតស្វាញរបស់សហព្រះរាជអាជ្ញាដើម្បីបញ្ជាក់ថាបក្សកុម្មុយនីស្តកម្ពុជាធ្វើការតស៊ូវណ្ណៈ។ នួន ជា មានចម្ងល់ថាតើ នៅក្នុងការតស៊ូប្រភេទណាផ្សេងទៀត ដែលកម្មកររបស់ពិភពលោករំពឹងថានឹងរួបរួមគ្នា? ការខំប្រឹងប្រែងទាំងនេះ បញ្ជាក់ពីការសង្ស័យដ៏ជ្រាលជ្រៅរបស់លោក នួន ជា ដែលគាត់មិនត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្ម ប៉ុន្តែកាត់ទោសលើរបបកុម្មុយនីស្ត ជំនឿ និងមិនមែនការប្រព្រឹត្ត។ សំណួរតែមួយគាត់នៃការពាក់ព័ន្ធដ៏មានសក្តានុពលសម្រាប់អង្គជំនុំជម្រះនេះ គឺថាតើ ទស្សនវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ពឹងផ្អែកមួយផ្នែកលើទ្រឹស្តីវណ្ណៈ? សំណួរតែមួយគត់នៃភាពពាក់ព័ន្ធគឺថា តើបក្សកុម្មុយនីស្តកម្ពុជា មានបំណងធ្វើបាបក្រុមដែលអាចស្គាល់ដោយច្បាប់ដែរឬទេ។ ចម្លើយគឺថា “ទេ”។

[១១:៤៩:២៨]

ដូចដែល នួន ជា បានពន្យល់ពីមុននៅចំពោះមុខអង្គជំនុំជម្រះថា បក្សកុម្មុយនីស្តកម្ពុជាមិនដែលជឿជាក់ថា កសិករ កម្មករ មានទំនាស់ជាមួយនឹងវណ្ណៈផ្សេងៗទៀតនោះដែរ។ សូម្បីតែក្រុមនៅកំពូលនៃវណ្ណៈសក្តិភូមិ ដូចជាគ្រួសាររាជវង្ស រួមទាំងអ្នកស្នេហាជាតិ ដែលគាំទ្រប្រជាជន និងបដិវត្តន៍។ ប្រាកដណាស់ វាមិនត្រឹមត្រូវនោះទេ ដែលអ្នកដែលនៅក្នុងរបបសក្តិភូមិ “រួមទាំងមន្ត្រីតូចតាច មេឃុំសង្កាត់ និងស្មៀនមានជំទាស់ជាមួយនឹងកសិករ។ លើកលែងតែពួកចក្រពត្តិនិយម បក្សកុម្មុយនីស្តកម្ពុជាមិនចាត់ទុកក្រុមណាជាសត្រូវឡើយ”។ ការសន្និដ្ឋាននេះ បានមកពីការវិភាគនៃវណ្ណៈរបស់បក្សកុម្មុយនីស្តកម្ពុជា និងភាពចាំបាច់របស់បដិវត្តន៍ ដែលត្រូវបន្ថយសត្រូវ បង្កើនមិត្ត។

ការសង្ខេបលើគោលជំហររបស់បក្សកុម្មុយនីស្តកម្ពុជា លោក នួន ជា បានពន្យល់ថា “លើកលែងតែមនុស្សដែលមានឆន្ទៈចង់បង្ហាញប្រទេសជាតិ -- ចង់បំផ្លាញប្រទេសជាតិ (សូមទោស) មនុស្សដែលជាអ្នកដើរតាមជនបរទេស ឬអ្នកមានជំនឿលើពួកចក្រពត្តិនិយម មនុស្សទាំងនោះជាមនុស្សល្អ។ យ៉ាងណាមិញជនគហបតីតូចតាច បញ្ញវន្ត និងនិស្សិតមិនមែនជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ហើយពួកគេត្រូវបានចាត់ទុកដោយបក្សកុម្មុយនីស្តកម្ពុជាថា ជាមិត្តនៃវណ្ណៈកម្មករ ដែលស្រឡាញ់ចូលចិត្តបដិវត្តន៍។ បក្សកុម្មុយនីស្តកម្ពុជាជឿថា ពួកមូលធននិយមថ្នាក់ជាតិ គឺជាកម្លាំងគាំទ្រផ្នែកយុទ្ធសាស្ត្រនៃបដិវត្តន៍ជាតិប្រជាធិបតេយ្យ។ វណ្ណៈទាំងនេះត្រូវបានចាត់ទុកថាជាការម្លាំងរួបរួម ព្រោះក្នុងនាមជាប្រជាជនកម្ពុជា ពួកគេរស់នៅក្រោមការគំរាមកំហែងរបស់ពួកអាណានិគមនិយម និងពួក

ចក្រពត្តិនិយម។ វណ្ណៈណាក៏ដោយដែលនៅក្នុងបរិបទនៃប្រទេសដែលជាទាសករគេ និងប្រទេសដែលជាពាក់កណ្តាលទាសករគេ គឺដឹងថាអត្តសញ្ញាណជាតិត្រូវបានបំផ្លាញទោះតិច ឬច្រើនក្តី។

[១១:៥២:០៩]

លោក អ៊ុក ប៊ុនឈឿន ប្រាប់លោក ស្ទីវ ហេដឌ័រ ថាគោលនយោបាយរបស់ ប៉ុល ពត គឺបញ្ជាក់លើឥរិយាបថ ដែលកសិករថ្នាក់កណ្តាល កសិករថ្នាក់ខ្ពស់ពួកគេ -- ពួកគហបតីតូចតាច ព្រះសង្ឃ បញ្ញវន្ត គឺត្រូវទទួលការគាបសង្កត់ពីសង្គមចាស់។

បើនិយាយជាទូទៅ បក្សកុម្មុយនីស្តកម្ពុជាមិនមានគំនុំជាមួយអ្នករស់នៅទីក្រុង ឬអ្នករស់នៅភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ នោះទេ។ ការផ្សព្វផ្សាយរបស់លោក ខៀវ សំផន នៅក្នុងខែមុនការរំដោះ ជំរុញឲ្យបងប្អូនជនរួមជាតិនៅក្រុងភ្នំពេញដើម្បីងើបឡើងប្រឆាំងនឹងអ្នកដែលគាបសង្កត់ពួកគេ។ ការចេញផ្សាយនៃទស្សនាវដ្តីយុវជនបដិវត្ត ខែតុលា ឆ្នាំ១៩៧៥ បានពិពណ៌នាការខិតខំប្រឹងប្រែងរបស់សហករណ៍ ក្នុងការចិញ្ចឹម និងឧបត្ថម្ភដល់ប្រជាជនជាង២លាននាក់ ដែលទើបបានត្រូវបានបដិវត្តន៍រំដោះពីការគ្រប់គ្រងរបស់ជនក្បត់ដ៏គួរឲ្យស្អប់ខ្ពើមនោះ។

បើប្រជាជននៅក្នុងក្រុងភ្នំពេញត្រូវចាត់ទុកជាសត្រូវមែននោះ វាមិនសមហេតុផលទេក្នុងការប្រើពាក្យថា "រំដោះ រំដោះពួកគេនោះ"។ មានសាក្សីជាច្រើនដែលបានផ្តល់សក្ខីកម្មថា៖ "គ្មានការបែងចែករវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីនោះទេ"។ នន់ សួន មន្ត្រីជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ ស្ទីវ ហេដឌ័រ ថា៖ គាត់ត្រូវបានគេណែនាំនៅក្នុងផ្នែកគាត់ថា ឲ្យរៀបចំម្ហូបអាហារ និងទីស្នាក់ការសម្រាប់ប្រជាជនជម្លៀស។ ឲ្យគាត់កាប់សិត -- កាប់សាច់ (សូមទោស) និងស្រូវរបស់សហករណ៍សម្រាប់ផ្តល់ជាអាហារដល់ពួកគេ"។

[១១:៥៤:៣១]

នួន ជា ក៏ប្រាប់ ថេត សម្បត្តិ ស្រដៀងគ្នានេះដែរថា៖ "យើងតែងតែប្រាប់ និងទូន្មានដល់កម្មាភិបាលរបស់យើងឲ្យមើលថែប្រជាជនថ្មី និងឲ្យពួកគេមានសិទ្ធិស្មើៗគ្នា ទោះជាពួកគេជាប្រជាជន១៧ មេសា ក៏ដោយ ពួកគេមានសិទ្ធិធ្វើការនៅក្នុងសហករណ៍ដែរ"។

ជាចលនាសង្គមនិយម បក្សកុម្មុយនីស្តកម្ពុជាពិតណាស់ មានបំណងក្នុងការបំបាត់ជំហរ នៃការផ្តល់សិទ្ធិពិសេសរបស់សក្តិភូមិ និងមូលធននិយម ប៉ុន្តែគោលនយោបាយនោះមិនមែនជាការរើសអើងទេ វាគ្រាន់តែទាមទារឲ្យប្រជាជនកម្ពុជាទាំងអស់អាចមានសិទ្ធិនិងមានកាតព្វកិច្ចដូចៗគ្នា ដោយមិន

គិតពីវណ្ណៈអ្វីទាំងអស់ ដូច្នេះឥទ្ធិពលនៃអយុត្តិធម៌របស់ម្ចាស់ដីសក្តិភូមិ ត្រូវបានកាត់បន្ថយ ដោយបង្រួមវាលស្រែរបស់ពួកគេឲ្យកាន់តែតូច ដែលដូចនឹងអ្វីដែលកម្មករកសិករដទៃទៀតមាន។ ពួកគេត្រូវបានគេធ្វើដាក់ដូចជាមនុស្សដទៃទៀត។

ការវិភាគលើប្រវត្តិសាស្ត្រនៃកម្ពុជាទាក់ទិននឹងអាណានិគមនិយម សក្តិភូមិនិយម និងចក្រពត្តិនិយមរបស់បក្សកុម្មុយនីស្តកម្ពុជា បានបង្ហាញពីខ្សែរយៈយ៉ាងច្បាស់រវាងការគ្រប់គ្រងនយោបាយរដ្ឋដោយបរទេស និងស្ថានភាពសេដ្ឋកិច្ចរបស់ជនក្រីក្រ។ សារណាថ្នាក់បណ្ឌិតរបស់លោក ខៀវ សំផន បានគាំទ្រការផ្គត់ផ្គង់ដោយខ្លួនឯង ដែលជាសសរទ្រូងនៃផែនការក្នុងការធ្វើឲ្យជីវិតរបស់កម្មករ កសិករឲ្យកាន់តែប្រសើរឡើង។

[១១:៥៦:៣៥]

លោក នួន ជា បានរំឭកផងដែរថា ក្នុងនាមជានិស្សិតនៅបាងកកនៅក្នុងចុងទសវត្សរ៍ឆ្នាំ១៩៤០ គាត់បានសង្កេតឃើញថា ប្រទេសថៃមិនមែនជាប្រទេសឯករាជ្យពិតប្រាកដទេ ព្រោះសេដ្ឋកិច្ចគេត្រូវបានគ្របសង្កត់ដោយផលប្រយោជន៍បរទេស ហើយជនក្រីក្រត្រូវបានគាបសង្កត់ដោយអ្នកមាន។ លោក នួន ជា បានបញ្ជាក់ថា គំនិតរបស់គាត់នេះក្នុងពេលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងភាសាដែលបក្សកុម្មុយនីស្តកម្ពុជាជាច្រើនឆ្នាំមកហើយ -- ជាច្រើនឆ្នាំក្រោយមក កំណត់ដើម្បីបង្ហាញថា ធាតុពិតរបស់សង្គមកម្ពុជាគឺសង្គមពាក់កណ្តាលអាណានិគម និងពាក់កណ្តាលសក្តិភូមិ។ ដូច្នេះ ភារកិច្ចបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យគឺដើម្បីបំបាត់ភាពពាក់កណ្តាលអាណានិគម និងពាក់កណ្តាលសក្តិភូមិ និងដើម្បីប្រឆាំង និងទប់ទល់នឹងពួកពាក់កណ្តាលមូលធននិយម។ វាមានន័យថា ដើម្បីរំដោះប្រទេសជាតិ និងប្រជាជន។ ដើម្បីរំដោះជាតិមានន័យថា ដើម្បីបំបាត់ធាតុដែលនៅសេសសល់ពីអាណានិគមនិយម នៅពេលនោះ និងបំបាត់ភាពសក្តិភូមិបន្តិចម្តងៗ។

[១១:៥៨:០៩]

នៅចុងបញ្ចប់នៃការប៉ះទង្គិចយោធានៅក្នុងឆ្នាំ១៩៧៥ ទោះបីជាបក្សកុម្មុយនីស្តកម្ពុជាអាចនឹងរំពឹងថា នឹងបានដឹងហើយថា ការប៉ះទង្គិចពិតជាត្រូវបានបញ្ចប់ មិនមានន័យថា ការគំរាមកំហែងពីការមកចូលជ្រៀតជ្រែករបស់បរទេសមិនអាចកើតមានទៀតទេ។ បក្សកុម្មុយនីស្តកម្ពុជាពិតជាបានដឹងយ៉ាងមុតមាំពីសមត្ថភាពនៃរដ្ឋមហាអំណាចក្នុងការបម្រើមធ្យោបាយមិនមែនយោធា។ រួមបញ្ចូលទាំងនយោបាយការទូត និងជំនួយបរទេស ដើម្បីបំពេញឆន្ទៈរបស់ពួកគេលើរដ្ឋដែលទន់ខ្សោយ។

ទោះបីជាបក្សកុម្មុយនីស្តកម្ពុជាមានការប្រុងប្រយ័ត្នពីការលូកដៃចូលរបស់បរទេស ការមិនទុកចិត្តមិនបណ្តាលឲ្យប្រទេសកម្ពុជាក្លាយជា ស្ទើរតែឯកាទាំងស្រុងពីពិភពលោកទាំងមូលនោះទេ ហើយវាក៏មិនមែន និងដើមហេតុនៅក្នុងមនោគមន៍វិជ្ជាខ្លួនទីពឹងខ្លួននោះដែរ។ ជំនួយបរទេស ឧទាហរណ៍គឺអាចទទួលបានដោយគ្មានមន្ទិលពេលដែលជំនួយនោះមិនត្រូវឡើងក្នុងបំណងជាឧបករណ៍សម្រាប់ជះឥទ្ធិពលលើគោលនយោបាយក្នុងស្រុករបស់ប្រទេសកម្ពុជា។

[១១:៥៩:៤៦]

លោក នួន ជា បានពន្យល់ថាជំនួយពីចិន គឺជាជំនួយដែលគ្មានលក្ខខណ្ឌ ជំនួយពីរដ្ឋជាមិត្តផ្សេងទៀតគឺត្រូវទទួលយកជាញឹកញាប់ផងដែរ។ មានតែជំនួយដែលមានលក្ខខណ្ឌប៉ុណ្ណោះដែលត្រូវបានបដិសេធ។ បក្សកុម្មុយនីស្តកម្ពុជាមិនដែលបដិសេធជំនួយបរទេសទាំងអស់នោះទេ។ ចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាបានចោទប្រកាន់ដោយបង្ហាញឯកសារជាច្រើនក្នុងចំណោមឯកសារទាំងនោះ រួមមានអត្ថបទកាសែតចំនួនបី ដែលមានលក្ខណៈស្រពេចស្រពិល ជាសេចក្តីថ្លែងការណ៍មិនមានលក្ខណៈចង្អុលភស្តុតាងដែលចេះតែថា បក្សកុម្មុយនីស្តកម្ពុជាព្យាយាមមិនទទួលជំនួយបរទេស។ ហើយក៏មិនអាចគាំទ្របានចំពោះសម្តីទាំងនេះឲ្យបានជាក់លាក់ទេ។ ឯកសារមួយទៀតចាត់ទុកថាការបដិសេធរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះការផ្តល់ឲ្យដោយស្ថានទូតបារាំងនូវគ្រូម្នាក់ និងទាហានពេទ្យពីរ ឬបីនាក់ ដល់រដ្ឋាភិបាលថ្មី ថាជាការបដិសេធជំនួយបរទេស។

[១២:០០:៥៩]

ឯកសារផ្សេងទៀត បង្ហាញថាបញ្ហាដែលជំនួយបរទេសត្រូវបានទទួលយក ឬក៏អត់នោះ គឺមិនមានភាពច្បាស់លាស់ទេ ស្របពេលដែលឯកសារពីរដទៃទៀតមិនមាននិយាយ ហើយថាគាត់ត្រូវបាន-- (សូមទោស) ស្របពេលដែលឯកសារពីរដទៃទៀត មិនមាននិយាយពីរឿងនេះទាល់តែសោះ។ ឯកសារដទៃបានលើកឡើងពីគោលការណ៍នៃការផ្គត់ផ្គង់ខ្លួនឯងរបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែគ្មានឯកសារណាអាចយកមកនិយាយថា មានការបដិសេធជំនួយខាងក្រៅនោះដែរ។

លោកប្រធាន ខ្ញុំឃើញដល់ម៉ោង ហើយអាចខ្ញុំបន្ត ឬក៏ថាខ្ញុំនៅសល់ៗពេលខ្លីទេ ខ្ញុំនៅសល់ប្រហែលជាប្រាំសន្លឹក -- ប្រាំទំព័រ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាស

សម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សូមភាគី និងសាធារណជន ព្រមទាំងមន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការរបស់អង្គជំនុំជម្រះជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យខ្លួនគាត់ត្រឡប់មកចូលរួមនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិននាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣០នាទី)*

[១៣:៣០:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

ជាដំបូងទូលបង្គំសូមថ្វាយព្រះសង្ឃដែលបានចូលរួមក្នុងសវនាការ។ ពេលនេះ សូមគោរពអង្គសវនាការ និងលោកប្រធានសាជាថ្មី។ បន្ទាប់ពីនេះខ្ញុំសូមបន្តសារណារបស់ខ្ញុំតទៅទៀត។

ខ្ញុំសូមលើកឡើងពីការបកស្រាយខុសរបស់សហព្រះរាជអាជ្ញា។ នៅក្នុងសវនាការនេះសហព្រះរាជអាជ្ញាបានបង្ហាញថាលោក នួន ជា ជាមនុស្សសាហាវ។ ដែលគោលបំណងរបស់គាត់ គឺដើម្បីបង្កើតរដ្ឋទាសករក្នុងប្រទេសកម្ពុជា។ ជាការពិតណាស់គាត់ស្រលាញ់ប្រទេសរបស់គាត់ និងប្រជាជនរបស់គាត់ ហើយគាត់បានលះបង់ខ្លួនដើម្បីការអភិវឌ្ឍប្រទេស។ ចំពោះលោក នួន ជា ការចោទប្រកាន់ទាំងនេះ ពិតជាមិនគួរឲ្យនឹកស្មានដល់មែន។ ហើយបានបង្ហាញពីការយល់ខុសស្រឡះពីថាលោក នួន ជា ជាមនុស្សបែបណា។

ដូចដែលលោក នួន ជា បាននិយាយដោយខ្លួនឯងហើយថា "ខ្ញុំបានលះបង់ខ្លួនខ្ញុំដើម្បីបម្រើប្រទេសជាតិ។ ខ្ញុំបានទុករឿងគ្រួសាររបស់ខ្ញុំចោល ព្រោះតែខ្ញុំស្រលាញ់ប្រទេសជាតិខ្ញុំ"។ យើងចាំបាច់ត្រូវក្រឡេកមើលជីវិតរបស់គាត់វិញដើម្បីឱ្យដឹងពីការពិត។ លោក នួន ជា មិនដែលមានការស្មោក់ស្មើរពីគោលដៅរបស់គាត់ទេ។ គាត់មិនចង់ក្លាយជាអ្នកមាន។ គាត់មិនដែលធ្វើរឿងឆ្លៀតឱកាស ដើម្បីយកបុណ្យស័ក្តិ ឬឲ្យមានសិទ្ធិពិសេសសម្រាប់ខ្លួនគាត់ ឬគ្រួសារគាត់នោះទេ។ គាត់បានរស់នៅខ្វះមុខខ្វះក្រោយនៅក្នុងព្រៃអស់រយៈពេលជិត៣០ឆ្នាំ ដើម្បីបម្រើគោលការណ៍ដែលគាត់ជឿជាក់។ គាត់ធ្វើការដោយសម្ងាត់ និងស្ថិតក្នុងភាពគ្រោះថ្នាក់ជាប្រចាំក្នុងទីក្រុងភ្នំពេញអស់កាលជាង២០ឆ្នាំ។

[១៣:៣៣:៤៦]

ការយល់ច្រឡំអំពីបំណងរបស់ នួន ជា និងតួនាទីរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា អាចមើលឃើញតាមវិធីផ្សេងទៀត។ ឧទាហរណ៍ លោក នួន ជា មិនត្រូវបានស្គាល់ថាជាបងទី២នោះទេនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងនៅមុនឆ្នាំ១៩៧៥។ ចំពោះ នួន ជា ដើមកំណើតនៃការហៅនេះគឺស្ថិតក្នុងអាថ៌កំបាំង។ នួន ជា កត់សម្គាល់ថា សាក្សីមួយចំនួនដែលបានបង្ហាញខ្លួននៅក្នុងអង្គសវនាការនេះអះអាងថា គាត់មានរហស្សនាមនេះដើម្បីពណ៌នាពីគាត់។ ដូចគ្នានឹងអ្នកជំនាញ ដែលមិនស្គាល់សូម្បីតែឈ្មោះរបស់ នួន ជា សាក្សីទាំងនេះក៏មានការយល់ច្រឡំដែរ។ សក្ខីកម្មរបស់ពួកគេបានបង្ហាញពីភាពភ័ន្តច្រឡំរបស់ការចងចាំ និងរបស់មនុស្ស ពិសេសនិន្នាការដែលបង្កើតឲ្យមានការចងចាំខុស ដែលវាដូចគ្នានឹងការភ័ន្តច្រឡំដ៏ទូលំទូលាយផងដែរ។

លោក នួន ជា បានសង្កេតឃើញថា ជាធម្មតាគាត់ត្រូវបានគេពណ៌នានៅក្នុងប្រព័ន្ធផ្សព្វផ្សាយថាជាមេមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា។ សម្រាប់បុរសដែលមិនដែលទាំងសរសេរអក្សរមួយតួ សម្រាប់ទស្សនវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា មុខងារនេះគឺវាគ្មានន័យទាល់តែសោះ។ តួនាទីសំខាន់របស់ នួន ជា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺការអប់រំនយោបាយ។ គាត់បានផ្សព្វផ្សាយគោលនយោបាយនិងយុទ្ធសាស្ត្រដល់កម្មាភិបាលក្នុងបក្ស។ គាត់ក៏បានចូលរួមកន្លងមកជាមួយការអភិវឌ្ឍរបស់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់របស់បក្ស។ ប៉ុន្តែ នួន ជា មិនមែនជាបញ្ញវន្តទេ ដូចដែលគាត់បានជម្រាបអង្គជំនុំជម្រះរួចហើយ ថាគាត់ត្រូវបានណែនាំដោយ ប៉ុល ពត មិនឲ្យជាប់ទាក់ទិននឹងបញ្ញវន្តដទៃនៅក្នុងបក្ស។ ហើយមិនដែលមានតួនាទីជាអ្នកកំណត់គោលនយោបាយរបស់បក្សដែរ។

[១៣:៣៦:៣០]

ការយល់ឃើញជាទូទៅក៏មានការបកស្រាយខុសពីឥទ្ធិពលសំខាន់មកលើជីវិតបដិវត្តន៍ដំបូងរបស់ នួន ជា ដែរ។ ទោះបីជា នួន ជា ត្រូវបានទទួលឥទ្ធិពលពីស្នាដៃសរសេររបស់ ម៉ៅ សេទុង ក៏ដោយ ក៏ទស្សនវិជ្ជារបស់គាត់មិនមានលក្ខណៈម៉ៅនិយមនោះទេ។ ជាក់ស្តែងគាត់មិនបានទុកចិត្ត "ជើងកាងទាំងបួន" ដែលជាពួកម៉ៅជ្រុលនិយម ដែលគាត់សង្ស័យថា ពួកនេះស្រលាញ់តែអំណាចប៉ុណ្ណោះ។

ការបំពាក់បំប៉នសិក្សាកុម្មុយនីស្តជាផ្លូវការដែល នួន ជា បានរៀនគឺធ្វើនៅវៀតណាមខាងជើង ដែលបន្ទាប់មកទៀត គាត់ក៏ចាប់យកនូវគំនិត ម៉ាក្ស-លេនីនវិញ។ គាត់ចាត់ទុក ទ្រឿង ជិញ ដែលជាលេខាធិការទី១របស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និងជាជនទី២បន្ទាប់ពីហូជីមិញនៅក្នុងឋានានុក្រមរបស់កុម្មុយនីស្តវៀតណាមពីឆ្នាំ១៩៤១ ដល់ ១៩៥៧ ដែលជាមនុស្សមានឥទ្ធិពលកំពូលមកលើគាត់។

[១៣:៣៧:៥៥]

រឿងដូចគ្នានេះគឺទាក់ទិននឹងការយល់ខុសថា ប៉ុល ពត និង នួន ជា ជាអមនុស្សដែលប្រកាន់យកគោលជំហរដោយខ្លួនឯងដែលបង្ហាញពីការបែកចេញពីគ្នារវាងគាត់ទាំងពីរ ទៅនឹងកម្មាភិបាលនៅភូមិភាគបូព៌ាដែលទទួលឥទ្ធិពលពីកុម្មុយនិស្តវៀតណាម។ ដូចដែលលោក នួន ជា បានប្រាប់ ថេត សម្បត្តិ ហើយ មិត្តភក្តិជិតស្និទ្ធនិងគួរឲ្យទុកចិត្តរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺ សោ ភឹម។ ដើមកំណើតនៃមិត្តភាពពួកគេគឺ នៅពេលពួកគេ ទាំងពីរនាក់រៀនសូត្រនយោបាយនៅវៀតណាមក្នុងឆ្នាំ១៩៥៤។ ថេត សម្បត្តិ បានសង្ខេប ពីចរិតលក្ខណៈនិងប្រវត្តិមិត្តភាពពួកគេយ៉ាងត្រឹមត្រូវដូចខាងក្រោម៖

នួន ជា បានបង្កើតភូមិភាគបូព៌ាជាមួយ សោ ភឹម ដែលជាអ្នកទទួលខុសត្រូវភូមិភាគមួយនេះបន្ទាប់ពីជ័យជម្នះឆ្នាំ១៩៧៥។ អ្នកទាំងពីរបានស្គាល់គ្នាយូរជាងពេលដែលលោក នួន ជា ស្គាល់ ប៉ុល ពត។ ដោយសារតែធ្លាប់កម្សត់កម្រជាមួយគ្នាជាយូរមកហើយ អ្នកទាំងពីរមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ ពេលដែល សោ ភឹម មកភ្នំពេញ គាត់បានស្នាក់នៅផ្ទះរបស់ នួន ជា នៅក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់អំណាច។ ដូចនេះ សោ ភឹម ប្រៀបដូចជាបងប្អូនរបស់ នួន ជា អ៊ីចឹង។ លោក នួន ជា បាននិយាយថា៖ "យើងមើលថែគ្នាទៅវិញទៅមក។ ខ្ញុំស្រឡាញ់គាត់ ហើយគាត់ក៏ស្រឡាញ់ខ្ញុំ។ ខ្ញុំមានទំនាក់ទំនងជិតស្និទ្ធជាមួយគាត់ ព្រោះយើងធ្លាប់តស៊ូជាមួយគ្នា ហើយយើងថែរក្សាគ្នាទៅវិញទៅមក។ គាត់ធ្លាប់ការពារខ្ញុំ"។

[១៣:៤០:០៧]

លោក នួន ជា មានទំនុកចិត្តលើសមត្ថភាពរបស់ សោ ភឹម ក្នុងភាពជាអ្នកដឹកនាំមួយក្នុងចលនាកុម្មុយនិស្តកម្ពុជា។ ដូចនេះៗហើយលោក នួន ជា មិនមានការភ្ញាក់ផ្អើលអ្វីទាល់តែសោះចំពោះការរកឃើញរបស់អ្នកស្រាវជ្រាវ ដូចជាលោកសាស្ត្រាចារ្យ ឃៀរនិន ដែលថាភូមិភាគបូព៌ាមានភាពបត់បែនជាង និងការប្រព្រឹត្តរបស់កម្មាភិបាលក្នុងភូមិភាគនេះមានវិន័យជាងភូមិភាគផ្សេងៗទៀត។ សោ ភឹម ជាបុគ្គលដែលទទួលការអប់រំលទ្ធិកុម្មុយនិស្ត ដែលយល់ និងព្យាយាមបន្តអំពីគោលបំណងស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា ការបង្កើនទិន្នផលស្រូវ និងបង្កើនជីវភាពរស់នៅរបស់ប្រជាជន។

[១៣:៤១:០២]

ដូចដែលលោក ស្ទីវហ្វិន ហេដឌ័រ *(Stephen Heder)* បានផ្តល់សក្ខីកម្មយ៉ាងត្រឹមត្រូវថា គោលនយោបាយរបស់ភូមិភាគបូព៌ាគឺត្រឹមត្រូវតាមបំណងរបស់មជ្ឈិមបក្សជាងភូមិភាគដទៃទៀត ជាពិសេសភូមិភាគពាយ័ព្យ។ យើងក៏ត្រូវកត់សម្គាល់ផងដែរថា ជំនឿដែលថា លោក នួន ជា បានចងសម្ព័ន្ធមិត្តជាមួយមេដឹកនាំភូមិភាគខ្លះ ប្រឆាំងមេដឹកនាំភូមិភាគដទៃទៀតនោះ គឺមិនត្រឹមត្រូវនោះទេ។ តែផ្ទុយទៅវិញលោក នួន ជា បានទទួលកិត្តិស័ព្ទក្នុងគណៈអចិន្ត្រៃយថា ជាបុគ្គលអ្នកសម្របសម្រួលផ្សះផ្សា និងអ្នកបង្កើតសន្តិភាពរវាងបុគ្គលដែលមានទំនាស់ជាមួយគ្នា។ ភាពល្អក់កករចុងក្រោយរវាង សោ ភឹម ជាមួយ ប៉ុល ពត គឺមិនមែនដោយសារតែមនោគមន៍វិជ្ជាខុសគ្នានោះទេ តែវាបណ្តាលមកភាពស្មុគស្មាញ និងការផ្លាស់ប្តូរទំនាក់ទំនងជាមួយប្រទេសវៀតណាម។ នៅពេលនោះ សោ ភឹម ត្រូវបានគេចោទប្រកាន់ថាក្បត់ដោយលក់ស្រូវទៅឲ្យប្រទេសវៀតណាមនៅឆ្នាំ១៩៧៦ លោក នួន ជា មានការប៉ះទង្គិចយ៉ាងជ្រាលជ្រៅ។ គាត់ជាមួយ ប៉ុល ពត បានព្យាយាមបញ្ចុះបញ្ចូល សោ ភឹម កុំឲ្យគាំទ្រប្រទេសវៀតណាម ដើម្បីប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជា។ លោក នួន ជា មិនយល់ស្របនឹងសេចក្តីសម្រេចរបស់ ប៉ុល ពត ក្នុងការបញ្ជូនទ័ពទៅភូមិភាគបូព៌ា ក៏ប៉ុន្តែគាត់គ្មានអំណាចក្នុងការបញ្ឈប់រឿងនេះទេ។ ចំពោះទំនាក់ទំនងរបស់ នួន ជា ជាមួយវៀតណាម អ្នកស្រាវជ្រាវដូចជា ហ្វីលីព ស្សូត ទទួលបានព័ត៌មានមិនត្រឹមត្រូវ ក្នុងការសន្និដ្ឋានពីមូលដ្ឋានគ្រឹះមនោគមន៍វិជ្ជា ឬការបែកចេញរបស់មេដឹកនាំបក្សជាមួយប្រទេសវៀតណាម។ បើទោះគោលនយោបាយខ្លះរបស់បក្សខុសប្លែកពីគោលនយោបាយរបស់វៀតណាម ដែលការខុសប្លែកគ្នាគឺបណ្តាលមកពីបរិបទរបស់ប្រទេសដែលតូច និងខ្សោយជាងក៏ប្រទេសកម្ពុជាត្រូវបានបង្ខំចិត្តឲ្យបន្តទៅមុខយ៉ាងលឿនដើម្បីការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់

ខ្លួន។ លោក នួន ជា បានឲ្យតម្លៃ និងកោតសរសើរលើពីបទពិសោធន៍របស់ខ្លួនដែលបានរៀនសូត្រមកពីកុម្មុយនីស្តវៀតណាម។ លោកមិនដែលមានការអាក់អន់ចិត្តចំពោះវៀតណាមក្នុងការផ្តល់ឲ្យគាត់នូវភារកិច្ចតូចតាចក្នុងអំឡុងពេលដែលគាត់រៀនសូត្រនៅប្រទេសវៀតណាម ដូចដែលអ្នកនិពន្ធមួយចំនួនសរសេរអំពី ប៉ុល ពត អ៊ីចឹងដែរ។ ក៏ប៉ុន្តែផ្ទុយទៅវិញគាត់ "ស្វាគមន៍ការចូលរួមរបស់វៀតណាម" និងបានមើលឃើញថាវៀតណាមជាសម្ព័ន្ធមិត្ត និងសមមិត្តរួមអាវុធ ដោយសារតែវៀតណាមបានកំពុងប្រយុទ្ធក្នុងសមរភូមិតែមួយ និងវាយសត្រូវដូចគ្នា ប្រកបដោយភាពជោគជ័យ។ លោក នួន ជា កោតសរសើរភាពក្លាហាន និងសមត្ថភាពរបស់វៀតណាម។

[១៣:៤៤:៣៩]

លោក នួន ជា ក៏មានហេតុផលត្រឹមត្រូវក្នុងការប្រយ័ត្នប្រយែងអំពីចេតនា និងការប៉ុនប៉ងរបស់វៀតណាមក្នុងការគ្រប់គ្រងលើទឹកដីកម្ពុជា។ បក្សកុម្មុយនីស្តវៀតណាមបាននិយាយដោយចំហ អំពី "សហព័ន្ធឥណ្ឌូចិន" និងអ្វីដែលជា "ទំនាក់ទំនងពិសេស" ជាមួយប្រទេសកម្ពុជា។ ព្រះមហាក្សត្រព្រះបាទ នរោត្តម សីហនុ ធ្លាប់មានព្រះបន្ទូលរំឭកអំពីគំនិតរបស់វៀតណាមមកលើប្រទេសកម្ពុជា ដោយព្រះអង្គលើកឡើងថា នៅពេលដែលសង្គ្រាមចប់ ការរួបរួមរបស់វៀតណាម នឹងនាំឲ្យមានកម្លាំងក្នុងការគ្រប់គ្រងប្រទេសតូចនៅជិតខាង។ រហូតដល់នៅពេល -- នៅថ្ងៃ -- នៅក្រោយថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ វៀតណាមនៅតែបន្តអះអាងថា ខ្លួនគ្រប់គ្រងលើចលនាកម្ពុជាកុម្មុយនីស្ត និងទឹកដីកម្ពុជា។

ការជ្រៀតជ្រែករបស់វៀតណាមក្នុងដំណើរសង្គមនិយមកម្ពុជា បានធ្វើហួសពីគោលដែលធ្វើដោយមិនច្បាស់លាស់។ នៅមុនឆ្នាំ១៩៧០ វៀតណាមខាងជើងបានតស៊ូជាមួយបក្សកុម្មុយនីស្តកម្ពុជាក្នុងគោលបំណងដូចគ្នាក្នុងការរំដោះពីអាមេរិក ដូចដែលខ្លួនកំពុងធ្វើដើម្បីរួបរួមវៀតណាមទាំងពីរ។ នៅពេលដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាប្រាប់វៀតណាមខាងជើងថា បក្សកុម្មុយនីស្តកម្ពុជាមានបំណងដើរតាមមាគ៌ារបស់ខ្លួន មេដឹកនាំវៀតណាមបែរជាស្រឡាំងកាំងនឹងការបង្ហាញពីឯករាជ្យភាពនេះ និងចាប់ផ្តើមខឹង។

[១៣:៤៦:២៦]

បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ វៀតណាមបានរាយទ័ពគ្រប់អង្គភាពក្នុងទឹកដីកម្ពុជា ដោយគ្រប់គ្រងយោធា មន្ត្រីស៊ីវិល ហើយបានបញ្ជូនអាវុធដែលរឹបអូសបានពីទ័ពសាធារណរដ្ឋទៅប្រទេសវៀត-

ណាម។ បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៧៣ ដែលតម្រូវឲ្យដកទ័ពវៀតណាមចេញពីទឹកដីកម្ពុជា ក៏វៀតណាមនៅតែបន្តមាននៅក្នុងទឹកដីកម្ពុជាដោយមិនមានការអនុញ្ញាតពីបក្សកុម្មុយនីស្តកម្ពុជាឡើយ។

ទោះជាយ៉ាងណាក៏ដោយ ក៏ប្រតិកម្មរបស់លោក នួន ជា អំពីភាពតានតឹង និងមិនខ្លាំងក្លា និងមិនក្រេវក្រោធដែរ។ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល លោក នួន ជា បានដើរតួនាទីជាអ្នកសម្របសម្រួលជាមួយវៀតណាមក្នុងការដោះស្រាយទំនាស់អំពីព្រំដែន និងការបញ្ជាទ័ព។ គាត់មានតួនាទីដូចគ្នាក្នុងទំនាក់ទំនងរវាងវៀតណាម និងបក្សកុម្មុយនីស្តកម្ពុជា ដូចដែលគាត់ដើរតួក្នុងបក្ស ក្នុងការសម្របសម្រួលភាពតានតឹងរវាងភាគីដែលមានទំនាស់។ ក៏ប៉ុន្តែនៅរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការគំរាមកំហែងរបស់វៀតណាមកាន់តែធ្ងន់ធ្ងរឡើង។ ដូចដែលអង្គជំនុំជម្រះនេះបានដឹងហើយថាវៀតណាមនិងកម្ពុជាបានមានសង្គ្រាមនឹងគ្នាចាប់តាំងពីបក្សកុម្មុយនីស្តកម្ពុជារំដោះទីក្រុងភ្នំពេញមកម្ល៉េះ។ កម្មាភិបាលភូមិភាគបូព៌ាចាប់ផ្តើមគម្រោងបះបោរនៅប៉ុន្មានសប្តាហ៍ក្រោយពីថ្ងៃរំដោះឆ្នាំ១៩៧៥។

[១៣:៤៨:២៩]

ឡឹក សៅ ជានីរសារយោធាក្នុងភូមិភាគបូព៌ាបានផ្តល់សក្ខីកម្មថា៖ “លោក ចក្រី ជាមេបញ្ជាការកងពលទី៤ របស់ភូមិភាគបូព៌ាមានគម្រោងធ្វើការក្បត់ ដើម្បីយកអំណាចពី ប៉ុល ពត វិញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៦ នៅឯសន្និបាតក្នុងទីក្រុងភ្នំពេញនៅខែឧសភា ឆ្នាំ១៩៧៥”។

លោក នួន ជា មានហេតុផលជឿជាក់ថា រស់ ញឹម និង សោ ភឹម ដែលជាមេរបស់ ចក្រី បានពិភាក្សាគ្នាអំពីសម្ព័ន្ធភាពដើម្បីប្រឆាំងនឹងមជ្ឈិមបក្សនៅក្នុងកិច្ចប្រជុំដូចគ្នានេះ។ អនុប្រធានរបស់ ចក្រី គឺលោក ហេង សំរិន ទទួលស្គាល់ថា មានគម្រោងក្បត់ប្រឆាំងនឹង ប៉ុល ពត នៅឆ្នាំ១៩៧៨។ លោក ហេង សំរិន ពិតណាស់បានធ្វើតាមគម្រោងការណ៍នេះ។ ភាពភ័យខ្លាចរបស់បក្សកុម្មុយនីស្តកម្ពុជា អំពីចេតនារបស់វៀតណាម គឺមិនមែនគ្មានមូលដ្ឋាន និងប្រឌិតនោះទេ។ ភស្តុតាងពិតប្រាកដត្រូវឃើញយ៉ាងពិតប្រាកដដោយសារតែរឿងរ៉ាវកើតមានឡើង។ លោក នួន ជា មិនពេញចិត្តអំពីកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ខែមីនា ឆ្នាំ១៩៧៦ ដែលនិយាយអំពីការព្រមានរបស់គាត់គឺ ប្រយ័ត្នប្រយែងនឹងក្រុមដែលរត់ទៅវៀតណាម ហើយមិនត្រឡប់មកវិញ និងឃោសនាឲ្យមានការបះបោរ។ បើទោះជាមានកិច្ចខិតខំប្រឹងប្រែងពីវៀតណាមក្នុងការនិយាយដោះសាអំពីការឈ្លានពាន និងការគ្រប់គ្រងកម្ពុជាដោយយកលេសពីអំពើព្រៃផ្សៃរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏មានការសង្ស័យតិចតួចណាស់ទៅ

លើចេតនាពិតប្រាកដលើការគ្រប់គ្រង លេបទឹកដីរបស់វៀតណាមមកលើប្រទេសកម្ពុជា។ ពួកកុម្មុយនីស្តនៅហាណូយបានចូលទៅដល់ចំណុចដ៏អន្តរាយមួយនៅក្នុងប្រវត្តិសាស្ត្រដែលបុព្វបុរសរបស់គេបានព្យាយាមជាច្រើនសតវត្សរ៍មកហើយក្នុងការគ្រប់គ្រងទន្លេមេគង្គ។

[១៣:៥១:០១]

លោក នួន ជា ជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់បង្ហាញពីការជ្រៀតជ្រែករបស់វៀតណាមក្នុងការងារផ្ទៃក្នុងរបស់ប្រទេសកម្ពុជា -- ក្នុងរបស់ប្រទេសប្រជាធិបតេយ្យ។ វៀតណាមមានការចូលដោយសេរីក្នុងបណ្ណសារដ្ឋានរបស់ប្រទេសកម្ពុជាក្នុងរយៈពេល១០ឆ្នាំ។ នៅមុនពេលមានការខិតខំប្រឹងប្រែងក្នុងការប្រមូល និងរៀបចំបណ្ណសារដ្ឋាននោះឡើងវិញលោក ដេវីដ ឆេនល័រ បានកត់សម្គាល់ក្នុងការផ្តល់សក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះថា ឯកសារសំខាន់ៗត្រូវបានរកឃើញរួមទាំងចម្លើយសារភាពរបស់ ណៃ សារ៉ាន់ ហៅ យ៉ា។ លោក ដេវីដ ឆេនល័រ បានសន្និដ្ឋានថា៖ “របបសាធារណរដ្ឋកម្ពុជាបានប្រមូលយកឯកសារដែលបង្ហាញពីចេតនាគ្រប់គ្រងមកលើប្រទេសកម្ពុជារបស់វៀតណាម”។ អ៊ុង ចុងហឿង ធ្លាប់ធ្វើការនៅសារមន្ទីរអំពីប្រល័យពូជសាសន៍របស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជានៅរដូវក្តៅឆ្នាំ១៩៧៩ បានអះអាងថា៖ “មានឯកសារមួយចំនួនតាមពិតត្រូវបានបាត់បង់”។ រដ្ឋាភិបាលវៀតណាមបានខកខាតក្នុងការឆ្លើយតបទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតដែលបន្ទាប់ពីទទួលបានសំណើរបស់មេធាវីការពារក្តីរបស់លោក នួន ជា ដែលបានស្នើឲ្យបញ្ជូនឯកសារដែលពាក់ព័ន្ធដែលខ្លួនកំពុងកាន់កាប់មកឲ្យតុលាការនេះវិញ។

ក្នុងអត្ថបទទាំងប៉ុន្មាននេះ ខ្ញុំសូមបញ្ចប់ត្រឹមណេះ ហើយខ្ញុំនឹងបន្តទៅអត្ថបទមួយទៀតដែលនឹងនិយាយអំពីតួនាទីរបស់លោក នួន ជា។

[១៣:៥៣:២៤]

នេះជាអត្ថបទស្តីអំពីតួនាទីរបស់លោក នួន ជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ -- បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ។ ដូចដែលលោកស្រីចៅក្រមបានកត់សម្គាល់រួចហើយ សហព្រះរាជអាជ្ញាបានប្រើប្រាស់ពេលវេលា និងថាមពលយ៉ាងច្រើនដើម្បីចោទប្រកាន់អំពីតួនាទីរបស់លោក នួន ជា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ការចោទប្រកាន់ជាច្រើនគឺផ្តោតទៅលើតួនាទីជាន់ខ្ពស់របស់លោក នួន ជា។ សហព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ថាលោក នួន ជា ជាអនុលេខាបក្ស ហើយគាត់បានចូលរួមនៅក្នុងការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា។ តែលោក នួន ជា ខ្លួនឯង

បានបញ្ជាក់ច្រើនលើកច្រើនសារួចមកហើយ កាលពីអតីតកាលថា៖ "ការចោទប្រកាន់នេះគឺត្រឹមត្រូវ"។ តើហេតុអ្វីបានជាសហព្រះរាជអាជ្ញាចំណាយពេលដ៏ច្រើនបែបនេះ ដើម្បីបង្ហាញការចោទប្រកាន់មួយ ដែលលោក នួន ជា បានជម្រាបអង្គជំនុំជម្រះនេះរួចមកហើយថា "ត្រឹមត្រូវនេះ"។ ប្រហែលដោយសារ សហព្រះរាជអាជ្ញាដឹងថា ពុំមានអ្វីផ្សេងទៀតដែលពួកគេអាចបង្ហាញបានទាក់ទងនឹងតួនាទីរបស់លោក នួន ជា។ ការចោទប្រកាន់ខ្លះទៀត អំពីតួនាទីរបស់លោក នួន ជា គឺមិនត្រឹមត្រូវទេ។ សហព្រះរាជអាជ្ញា សង្ឃឹមថាគាត់អាចបញ្ចុះបញ្ចូលឲ្យលោក លោកស្រីចៅក្រម និងសាធារណជនជឿលើការចោទប្រកាន់ នោះ។ តាមរយៈភាសាបង្កាច់ភូតភរ ចចាមអារាម ពុំមានអ្វីជាការពិតជាក់លាក់មកលើលោក នួន ជា ទាល់តែសោះ។ ពីព្រោះលោក នួន ជា មានតួនាទីសំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយថាគាត់ មានធ្វើកិច្ចការដោយផ្ទាល់លើគ្រប់វិស័យទាំងអស់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ សហព្រះ រាជអាជ្ញាហាក់ដូចជាគិតថាតួនាទីរបស់លោក នួន ជា តែប៉ុណ្ណឹង ជាភស្តុតាងគ្រប់គ្រាន់លើសពីវិមតិ សង្ស័យដែលថាលោក នួន ជា បានគ្រប់គ្រងលើកម្មាភិបាលគ្រប់ជាន់ថ្នាក់នៅក្នុងឋានានុក្រមរបស់បក្ស កុម្មុយនីស្តកម្ពុជា។

[១៣:៥៦:០០]

ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាកំពុងតែភ័ន្តច្រឡំលើរចនាសម្ព័ន្ធជាផ្លូវការក្នុងបក្សកុម្មុយនីស្ត កម្ពុជាជាមួយនឹងការអនុវត្ត និងតួនាទីជាក់ស្តែងរបស់លោក នួន ជា នៅក្នុងមុខតំណែងរបស់គាត់។ ការពិតគឺថា ចំណុចជាច្រើនដែលសហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា មានការទទួលខុសត្រូវ តាមពិត គឺនៅក្រៅវិសាលភាពនៃករណីយកិច្ចរបស់គាត់ជាអនុលេខាបក្ស។ ស្រដៀងគ្នានេះដែរ លោក នួន ជា មានលទ្ធភាពដើម្បីអនុវត្តការពិនិត្យលើកម្មាភិបាលនៅថ្នាក់ក្រោមនៃឋានានុក្រមរបស់បក្សកុម្មុយ នីស្តកម្ពុជាក្នុងកម្រិតរបស់ខ្លួនតែប៉ុណ្ណោះ។ ដើម្បីបង្ហាញឲ្យច្បាស់ជាងនេះ ខ្ញុំនឹងពិនិត្យឡើងវិញនូវ កំហុសជាច្រើនដែលបង្ហាញដោយសហព្រះរាជអាជ្ញាទាក់ទងនឹងតួនាទីរបស់លោក នួន ជា នៅក្នុង បក្សកុម្មុយនីស្តកម្ពុជា។

<u>ការតែងតាំង:</u> ចំណុចនេះ សហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា។ ខ្ញុំសូមដកស្រង់៖ "នួន ជា បុគ្គលដំបូងគេដែលទទួលខុសត្រូវចំពោះការតែងតាំង ដំឡើងតួនាទី ដាក់វិន័យ កែប្រែ ដាក់ទណ្ឌកម្ម និងដកហូតកម្មាភិបាលរបស់បក្ស"។ បិទការដកស្រង់។

ការអះអាងបែបនេះមាននៅក្នុងកថាខណ្ឌ៤៣៧ នៃសេចក្តីសន្និដ្ឋានបញ្ចប់ក្តីរបស់សហព្រះរាជ

អាជ្ញា។ ប៉ុន្តែភស្តុតាងដែលសំអាងដោយសហព្រះរាជអាជ្ញាមិនបានផ្តល់ភស្តុតាងគាំទ្រដល់ការអះអាងនេះ សូម្បីតែបន្តិចឡើយ។ ផ្ទុយមកវិញ ភស្តុតាងដែលសំអាងដោយសហព្រះរាជអាជ្ញាគឺជាសក្ខីកម្មនៅសវនាការ ដែលផ្តល់ដោយសាក្សី ដែលមិនអាចផ្តល់នូវភស្តុតាងពិតប្រាកដជាក់លាក់ទាក់ទងនឹងតួនាទីរបស់លោក នួន ជា ឡើយ។

[១៣:៥៨:០៧]

ផ្ទុយមកវិញ សាក្សីទាំងនោះសារភាពដដែលនៅចំពោះមុខអង្គជំនុំជម្រះនេះថា ពួកគេមិនបានដឹងអ្វីទាំងអស់អំពីតួនាទីជាន់ខ្ពស់របស់មេដឹកនាំ ក្នុងអំឡុងពេលនេះរបបនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សីទាំងនោះ រួមមានឈ្មោះ ឌុច, មានឈ្មោះ នង សុផង់ និង សាឡុត ស -- និង សាឡុត បាន (សូមទោស) ឌុច, នង សុផង់ និង សាឡុត បាន។ ការដឹងដ៏កម្រិតរបស់ ឌុច ត្រូវពិពណ៌លម្អិតនៅកថាខណ្ឌ១២០នៃសារណារបស់យើងខ្ញុំ។ នៅកថាខណ្ឌនោះ យើងខ្ញុំបានបង្កើតជាបញ្ជីនូវការសារភាពជាច្រើនរបស់ ឌុច ដែលថាគាត់មិនដឹងអំពីគណៈអចិន្ត្រៃយ៍ ឬតួនាទីសំខាន់របស់លោក នួន ជា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ហើយការអះអាងរបស់គាត់គឺថានៅឆ្នាំក្រោយៗមកទៀត គាត់បានតាមដានយ៉ាងយកចិត្តទុកដាក់នូវនីតិវិធី និងបានសិក្សាឯកសារបឋមជាច្រើនអំពីកម្ពុជាប្រជាធិបតេយ្យ។

វាច្បាស់ណាស់ថា សក្ខីកម្មរបស់គាត់មិនបានឆ្លុះបញ្ចាំងការដឹងពិតប្រាកដនោះទេ។ ដូច្នេះហើយសក្ខីកម្មរបស់ ឌុច ពិតជាមិនជាប់ពាក់ទ័ន្ធជាមួយតួនាទីរបស់លោក នួន ជា នោះទាល់តែសោះ។ ចំពោះ នង សុផង់ បានផ្តល់សក្ខីកម្មស្រដៀងគ្នានេះដែរ គាត់បានចង្អុលបង្ហាញថា គាត់មិនបានដឹងអំពីតួនាទីរបស់គណៈអចិន្ត្រៃយ៍ ឬសមាជិកនីមួយៗនៃគណៈកម្មការនេះទេ។ ការយោងដែលពាក់ព័ន្ធ ទាក់ទងនឹងចំណុចនេះគឺនៅក្នុងសារណារបស់យើងខ្ញុំ គឺនៅជើងទំព័រលេខ៤៩។ សាក្សីទី៣ សាឡុត បាន បានផ្តល់សក្ខីកម្មស្រដៀងគ្នានេះដែរ។ បន្ទាប់មក សហព្រះរាជអាជ្ញាបានសំអាងពីការសម្ភាសមួយដែលផ្តល់ដោយ អៀង សារី។ នៅក្នុងការសម្ភាសនោះ អៀង សារី បានធ្វើការអះអាងតិចបំផុតអំពីតួនាទីរបស់លោក នួន ជា នៅក្នុងការតែងតាំង។ លោក អៀង សារី និយាយថាលោក នួន ជា និង ប៉ុល ពត បានសម្រេចលើការតែងតាំងទូត និងកម្មាភិបាលជាន់ខ្ពស់នៅក្រសួងការបរទេស។ ការសម្ភាសដែលសំអាងដោយសហព្រះរាជអាជ្ញា លោក នួន ជា បានបដិសេធចំពោះការអះអាងរបស់លោក អៀង សារី ថាលោក នួន ជា ទទួលខុសត្រូវចំពោះការតែងតាំងទាំងនោះ។ ជាផ្នែកនៃកិច្ចប្រឹងប្រែងរបស់

លោក អៀង សារី ដើម្បីបន្ធូរការទទួលខុសត្រូវរបស់ខ្លួនគាត់ផ្ទាល់។ គាត់បានធ្វើការអះអាងនោះនៅក្នុងការឆ្លើយតបទៅនឹងសំណួរពីលោក ស្ទីវហ្វិន ហេដឌ័រ អំពីតួនាទីរបស់គាត់ផ្ទាល់នៅក្នុងការតែងតាំងទាំងនេះ។ ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើការអះអាងរបស់ អៀង សារី អាចឲ្យជឿជាក់បាននោះថា ពាក់ព័ន្ធតែការតែងតាំងនៅក្នុងក្រសួងការនានា នោះក៏វាមិនមែនជាការពិតដូច្នេះដែរ។ វាមិនបានលើកឡើងអ្វីទាំងអស់អំពីការតែងតាំងនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ជាតិដែលស្ថិតនៅក្រោមការគ្រប់គ្រង និងតម្រូវការប្រតិបត្តិ ការសហប្រតិបត្តិការពីលេខាភូមិភាគ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាពុំបានផ្តល់ឯកសារណាមួយនៅចំពោះមុខតុលាការដែលបញ្ជាក់ថាលោក នួន ជា បានចុះហត្ថលេខាលើការតែងតាំង ដំឡើងឋានៈ និងដកហូតមន្ត្រីណាម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។ ប៉ុន្តែបើលោក នួន ជា មានអំណាចនេះមែន ឯកសារនៃការតែងតាំងពិតជានៅសល់ជាភស្តុតាងជាមិនខាន។

[១៤:០២:៤៥]

ជាចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងពីការសម្ភាសពីរលើកជាមួយលោក នួន ជា។ នៅក្នុងការសម្ភាសមួយនៃការសម្ភាសទាំងពីរលើកនោះ, ឯកសារលេខ E3/26, លោក នួន ជា មិនបាននិយាយអ្វីទាំងអស់អំពីតួនាទីរបស់គាត់នៅក្នុងការតែងតាំងនោះទេ។ ផ្ទុយមកវិញ គាត់គ្រាន់តែចង្អុលបង្ហាញបទល្មើសត្រូវបានដាក់ទណ្ឌកម្ម។ ក្នុងការសម្ភាសលើកទី២, ឯកសារ E3/108, ការថ្លែងរបស់លោក នួន ជា ស៊ីសង្វាក់គ្នាជាមួយនឹងសក្ខីកម្មទាំងអស់ដទៃទៀតរបស់គាត់។ វាចង្អុលបង្ហាញថា គាត់បានចាត់វិធានការតាមទម្ងន់នៃលទ្ធភាពរបស់គាត់ដែលអាចធ្វើបានប្រឆាំងនឹងកម្មាភិបាលទាំងឡាយដែលងាកចេញពីមាគ៌ារបស់បក្ស។ តែបើតាមការថ្លែងលទ្ធភាពរបស់គាត់មានកម្រិត។

លោក នួន ជា និយាយថា -- ខ្ញុំសូមដកស្រង់ៗ៖ “គាត់មិនអាចគ្រប់គ្រងកម្មាភិបាលថ្នាក់ក្រោមបានទេ”។ បិទការដកស្រង់។ ការលើកឡើងនេះគឺពិតជាត្រឹមត្រូវនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ជាតិ។ ដូចដែលគាត់បានលើកឡើងច្រើនដងជាមួយនឹងអ្នកសម្ភាសន៍ និងនៅចំពោះមុខអង្គជំនុំជម្រះនេះ មជ្ឈិមបក្សខកខានមិនបានគ្រប់គ្រងឲ្យបានគ្រប់គ្រាន់លើការប្រព្រឹត្តរបស់កម្មាភិបាលថ្នាក់ក្រោមទេ។ មូលហេតុមួយក្នុងចំណោមមូលហេតុដទៃទៀតជំរុញឲ្យលោក នួន ជា ជឿជាក់ថា គាត់មានការទទួលខុសត្រូវខាងសីលធម៌ចំពោះព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៤:០៤:៤៨]

ជាបន្ទាប់សហព្រះរាជអាជ្ញាបានអះអាងថា លោក នួន ជា-- ខ្ញុំសូមដកស្រង់៖ “គ្រប់គ្រង” លើ

ក្រសួងនានា អប់រំ និងសង្គមកិច្ច ទាក់ទងនឹងការឃោសនានិងអប់រំ ការអះអាងនោះត្រូវមួយផ្នែក។ ក៏ប៉ុន្តែទាក់ទងនឹងសង្គមកិច្ចវិញការអះអាងនេះគឺមិនត្រូវទាំងស្រុងនោះទេ។ លោក នួន ជា បានយល់ស្របថា គាត់បានធ្វើសេចក្តីសម្រេចជាច្រើនអំពីខ្លឹមសារនៃឯកសារអប់រំនយោបាយដែលផលិតដោយបក្សកុម្មុយនីស្តកម្ពុជានៅក្នុងក្រសួងនានានិងអប់រំ។ ស្រដៀងគ្នានេះដែរ គាត់បានយល់ស្របថាគាត់មានវត្តមានម្តងម្កាលនៅក្រសួងនេះ និងបានធ្វើអន្តរកម្មជាមួយកម្មាភិបាលនានាដែលធ្វើការនៅទីនោះ។ លោក នួន ជា បំភ្លឺយ៉ាងច្បាស់ថា គាត់មិនដែលធ្វើជារដ្ឋមន្ត្រីក្រសួងឃោសនាការឡើយ តំណែងនោះត្រូវបានកាន់កាប់ដោយ យុន យ៉ាត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តាំងពីដើមរហូតដល់ចប់។ ទាក់ទងនឹងសង្គមកិច្ច សហព្រះរាជអាជ្ញាគ្រាន់តែផ្អែកលើសក្ខីកម្មរបស់សាក្សីបីនាក់ដែលមិនជឿជាក់--ដែលមិនអាចជឿជាក់បានដែលជាការប៉ុនប៉ងដើម្បីគាំទ្រដល់ការអះអាងរបស់សហព្រះរាជអាជ្ញា ដែលថាលោក នួន ជា បានគ្រប់គ្រងលើក្រសួងនេះមិនគួរឲ្យភ្ញាក់ផ្អើលទេ។ វាមិនមានសក្ខីកម្មណាដែលបញ្ជាក់ឲ្យហួសពីវិមតិសង្ស័យថាលោក នួន ជា មានតួនាទី ឬសមត្ថកិច្ចនៅក្នុងវិស័យសង្គមកិច្ចឡើយ។

[១៤:០៦:៤២]

សាក្សីទី១ ដែលសំអាងដោយសហព្រះរាជអាជ្ញាគឺ ឌុច ដែលពុំមានការដឹងពាក់ព័ន្ធនឹងមូលហេតុដែលខ្ញុំទើបតែបានពិភាក្សារួចមកហើយនេះទេ។ សាក្សីទី២ គឺ អៀង ធីរិទ្ធ ដែលធ្លាប់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅខែកុម្ភៈ ឆ្នាំ២០០៩ ថាលោក នួន ជា បានបញ្ជាឲ្យគេចាប់និស្សិតដែលធ្វើការងារនៅក្រសួងសង្គមកិច្ច។ សក្ខីកម្មនេះ ត្រូវបានផ្តល់ក្នុងពេលយ៉ាងវែងបន្ទាប់ពីសតិស្មារតីរបស់ អៀង សារី *(ស៊ីក)* មានបញ្ហា និងនៅមិនយូរប៉ុន្មាននៅមុខអង្គជំនុំជម្រះនេះកំណត់ថា គាត់មិនមាននិតិសម្បទាក្នុងការចូលរួមការជំនុំជម្រះ។ សរុបមកសក្ខីកម្មរបស់ អៀង ធីរិទ្ធ នៅក្រោមសតិស្មារតី មិនល្អបែបនេះ មិនអាចចាត់ទុកជាតម្លៃដែលអាចបញ្ជាក់ជាភស្តុតាងបានឡើយ។

[១៤:០៧:៤៣]

សាក្សីទី៣ ឈ្មោះ ខាំ ផាន់ បានផ្តល់សក្ខីកម្មថា គាត់បានដឹក អៀង ធីរិទ្ធ ទៅចូលរួមការប្រជុំនៅក-៣ ពីរឬបីដងក្នុងមួយខែ។ ថ្វីបើគាត់អះអាងថា អៀង ធីរិទ្ធ បានជួបលោក នួន ជា នៅឯកិច្ចប្រជុំនោះ តែគាត់បានផ្តល់សក្ខីកម្មថា គាត់បានរង់ចាំ អៀង ធីរិទ្ធ នៅក្នុងឡានខាងក្រៅបន្ទប់ប្រជុំ ហើយក៏មិនដែលឈានជើងចូលអគារប្រជុំដែរ។ គាត់សង្កត់ធ្ងន់ថា អៀង ធីរិទ្ធ មិនបានប្រាប់គាត់ថា អៀងធីរិទ្ធ បានជួបអ្នកណានៅក-៣ទេ។ សក្ខីកម្មរបស់គាត់ដែលថា អៀង ធីរិទ្ធ បានជួបលោក នួន ជា

នោះគឺផ្អែកទាំងស្រុងទៅលើការស្មានតែប៉ុណ្ណោះ។ សូមអង្គជំនុំជម្រះគប្បីបដិសេធសក្ខីកម្មនេះចោល។

[១៤:០៨:៤២]

វារិតតែសំខាន់ថែមទៀត ដើម្បីកត់សម្គាល់ថាក្រៅពីសាក្សី បីនាក់ដែលមិនអាចជឿទុកចិត្តបាននោះ សហព្រះរាជអាជ្ញាមិនបានចង្អុលភស្តុតាងផ្សេងដែលមានការជាប់ពាក់ព័ន្ធទៅនឹងលោក នួន ជា ឡើយ។ សារទូរលេខ ដែលសំអាងដោយសហព្រះរាជអាជ្ញាមិនបានបង្ហាញថាលោក នួន ជា មានតួនាទីណាមួយនៅក្នុងកិច្ចការសង្គមកិច្ចទេ។ នៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលបានសំអាងដោយសហព្រះរាជអាជ្ញាក៏មិនបានបង្ហាញថា ពាក់ព័ន្ធរបស់លោក នួន ជា លើបញ្ហាទាក់ទងនឹងសង្គមកិច្ចផងដែរ។ សហព្រះរាជអាជ្ញាក៏មិនបានពន្យល់អង្គជំនុំជម្រះនេះថា តើលោក នួន ជា បានធ្វើអ្វីខ្លះទាក់ទងនឹងក្រសួងសង្គមកិច្ចនោះ ក៏ទេដែរ។ នៅក្នុងសភាតំណាងប្រជាជន ជាបន្ទាប់សហព្រះរាជអាជ្ញាបានធ្វើសេចក្ដីសន្និដ្ឋានផ្សេងៗអំពីតួនាទីរបស់លោក នួន ជា ថាប្រធានសភាតំណាងប្រជាជន។ ខ្ញុំសូមធ្វើសេចក្ដីអត្ថាធិប្បាយដោយសង្ខេបលើការសន្និដ្ឋានទាំងនេះ។ ការអត្ថាធិប្បាយនោះ ទាក់ទងនឹងកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦។ សហព្រះរាជអាជ្ញាបានផ្អែកលើអត្ថបទជាភាសាអង់គ្លេសនៃឯកសារនេះ។ សហព្រះរាជអាជ្ញាសំអាងលើកំណត់ហេតុនៃកិច្ចប្រជុំនេះនៅក្នុងសវនាការបង្ហាញឯកសារ និងជាថ្មីម្ដងទៀត នៅក្នុងអំណះអំណាងបញ្ចប់ការដេញដោលរបស់សហព្រះរាជអាជ្ញា។

[១៤:១០:៣៥]

ផ្អែកលើអត្ថបទភាសាអង់គ្លេសនៃកំណត់ហេតុនៃកិច្ចប្រជុំនោះ សហព្រះរាជអាជ្ញាអះអាងថាគណៈអចិន្ត្រៃយ៍បានពិពណ៌នាអំពីសភាតំណាងរាស្ត្រ -- សភាតំណាងប្រជាជនថា ខ្ញុំសូម -- ខ្ញុំសូមដកស្រង់៖ “គ្មានតម្លៃ” បិទការ -- សូមទោស -- គណៈអចិន្ត្រៃយ៍បានពិពណ៌នាអំពីសភាតំណាងប្រជាជនថា ខ្ញុំសូមដកស្រង់ “គ្មានតម្លៃ” ខ្ញុំសូមបិទការដកស្រង់។ នៅក្នុងអត្ថបទបកប្រែភាសាអង់គ្លេស គឺមិនត្រឹមត្រូវទេ។ តាមពិតន័យត្រឹមត្រូវជាភាសាខ្មែរនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនោះមានន័យផ្សេង។ ខ្ញុំសូមដកស្រង់នូវខ្លឹមសារជាដើម៖ “ការឃោនាអប់រំ បើមានគេសួរយើងត្រូវពន្យល់ -- (ឃ្លាទាំងនេះនិយាយអំពីការឃោសនាអប់រំ) បើមានគេសួរយើងត្រូវពន្យល់ យើងកុំច្រងេងច្រងាងកុំឱ្យឃើញថាយើងចង់បង្ក្រាប។ ទន្ទឹមនឹងនេះក៏កុំនិយាយលេងពីសភានៅចំពោះមុខប្រជាជនឱ្យគេឃើញថា យើងបន្លឹមបន្លំ ហើយសភាយើងគ្មានតម្លៃអី”។

[១៤:១២:០០]

សូមមើលឯកសារយោងដែលមានលេខ E3/232 ដែលមាន ERN 00017118 ជាភាសាខ្មែរ ហើយនិង ERN 00001826 រហូតដល់ 00082630 ជាភាសាអង់គ្លេស។ ក្នុងន័យនេះកិច្ចប្រជុំនោះមិនបាននិយាយថា សភាគ្មានតម្លៃនោះទេ។

សហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា ធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្ដីទីនៃរបបកម្ពុជាប្រជាធិបតេយ្យរយៈពេលមួយឆ្នាំ គឺនៅឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧។ អង្គជំនុំជម្រះហាក់ដូចជាដឹងអំពីជំហររបស់លោក នួន ជា ក្នុងករណីនេះ។ លោក នួន ជា បានបដិសេធជាប់ជានិច្ចចំពោះមុខតំណែងនេះ។ ប៉ុន្តែសំខាន់បំផុតនោះបញ្ហានេះ វាមិនសំខាន់ចំពោះករណីនេះទេ។ នៅកថាខណ្ឌ៤៤៩ នៃសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាលើកឡើងពីតួនាទីរបស់លោក នួន ជា ថាជានាយករដ្ឋមន្ត្រីស្ដីទី គឺជាការស្មានតែប៉ុណ្ណោះ។ ខ្ញុំសូមដកស្រង់៖ “បញ្ជាក់តួនាទី និងអំណាចរបស់គាត់ជាសមាជិកខ្ពស់បំផុតទី២ នៃបក្សកុម្មុយនីស្ដកម្ពុជា” ខ្ញុំសូមបិទការដកស្រង់។ ចំណុចនេះ លោក នួន ជា មិនបានជំទាស់ទេ ប្រសិនបើលោក នួន ជា ពិតជានាយករដ្ឋមន្ត្រីស្ដីទីមែននោះ ម្ល៉ោះលោក នួន ជា បានទទួលស្គាល់តួនាទីនេះរួចមកហើយ។ ដូចដែលគាត់បានទទួលស្គាល់ទាក់ទងនឹងមុខតំណែងរបស់គាត់ជាអនុលេខាបក្ស។ វាគ្មានអ្វីដែលត្រូវបាត់បង់ចំពោះការសារភាពបែបនេះទេ តែចំណុចសំខាន់នោះគឺថាលោក នួន ជា មិនដែលធ្វើជានាយករដ្ឋមន្ត្រីស្ដីទី ហើយលោក នួន ជា បានបដិសេធជាប់ជានិច្ចគាត់មិនមែនជានាយករដ្ឋមន្ត្រីស្ដីទីតាំងពីដំបូងមកម្ល៉េះ។

[១៤:១៤:៣៩]

សហព្រះរាជអាជ្ញាបានលើកយកឯកសារពីរមកធ្វើជាភស្ដុតាង ដែលឯកសារទាំងពីរនេះ គឺដកស្រង់ចេញពីការផ្សាយព័ត៌មានរបស់វិទ្យុភ្នំពេញ។ នៅវេលាម៉ោងបួនល្ងាច នាថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧ ដែលអះអាងថា លោក នួន ជា បានថ្លែងសុន្ទរកថានៅក្នុងពិធីខួបលើកទី៩ នៃកងទ័ពបដិវត្តន៍កម្ពុជាកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ ក្នុងនាមជានាយករដ្ឋមន្ត្រីស្ដីទី”។ ទោះជាយ៉ាងនេះក្ដីឯកសារទាំងពីរនេះមានលក្ខណៈផ្ទុយគ្នា ខ្លឹមសារ និងទម្រង់របស់វា។ ដើម្បីជាសក្ខីភាពនៃការអះអាងនេះខ្ញុំសូមដកស្រង់ និងប្រៀបធៀបឯកសារទាំងនេះ --ទាំងពីរនេះដែលចេញផ្សាយចេញពីវិទ្យុភ្នំពេញនេះ។

ខ្ញុំសូមដកស្រង់, ឯកសារទី១ គឺ E3/191 ដែលមាន ERN ជាភាសាខ្មែរ 00669940 នៅក្នុងទំព័រទី១ កថាខណ្ឌទី២ ដែលបញ្ជាក់ថា “ស្ថិតនៅក្នុងឱកាស និងស្ថានភាពនាពេលបច្ចុប្បន្ននេះខ្ញុំសូម

លើកឡើងនូវចំណុចសំខាន់ៗពីរចំណុច។ ទី១ ខ្ញុំចង់បញ្ជាក់ថាពិធីគំរប់ខួបប្រាំបួនឆ្នាំនៃការបង្កើតកងទ័ពរបស់យើង នៅពេលនេះធ្វើឲ្យយើងនឹងឃើញដល់ស្មារតីវីរភាពដ៏ខ្ពង់ខ្ពស់របស់កងទ័ពបដិវត្តន៍យើង"។

ឯកសារទី២ គឺ E3/147 ដែលមាន ERN ជាភាសាខ្មែរ 00779793។ នៅក្នុងទំព័រទី១២ កថាខណ្ឌទី២ ដែលបញ្ជាក់ថា "ចំណុចទី១ គឺខួបនៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា ធ្វើឲ្យយើងមើលឃើញនូវស្មារតីវីរភាពដ៏អស្ចារ្យ"។

ផ្អែកលើការដកស្រង់ទាំងពីរនេះផ្ទុះបញ្ជាំងឲ្យឃើញថា ឯកសារទាំងពីរនេះផ្សាយចេញពីវិទ្យុតែមួយ ក្នុងពេលតែមួយ ដែលជាមានខ្លឹមសារផ្ទុយគ្នា ដែលមិនអាចឲ្យជឿបានថាលោក នួន ជា បានចូលរួមធ្វើសុន្ទរកថានៅថ្ងៃនោះទេ។ ប្រសិនបើលោក នួន ជា ពិតជាបានចូលរួមនៅក្នុងពិធីនោះមែន ការដកស្រង់អត្ថបទសុន្ទរកថារបស់គាត់ ពិតជាមិនមានភាពខុសគ្នាបែបនេះទេ។ ចំណុចទាំងអស់នេះបង្កើតឲ្យមានសង្ស័យលើឯកសារទាំងពីរនេះ ដែលជាហេតុផលមិនបានប្រើប្រាស់តាមផ្លូវច្បាប់ទេ។

[១៤:១៧:៣៨]

<u>យោធា និងសន្តិសុខ:</u> បន្ទាប់មកសហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា ទទួលខុសត្រូវកិច្ចការយោធា និងសន្តិសុខ។ តាមពិតសហព្រះរាជអាជ្ញាបានអះអាងយ៉ាងវែងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលថាការទទួលខុសត្រូវរបស់លោក នួន ជា ក្នុងកិច្ចយោធា និងសន្តិសុខ គឺត្រូវបានគាំទ្រយ៉ាងច្បាស់ដោយភស្តុតាង។ តែវាពិតជាគ្មានភស្តុតាងអ្វីទាំងអស់ នេះជាចេតនាបំផ្លើសខុសពីការពិត និងការខំប្រឹងប្រែងដោយឥតលាក់លៀម ដើម្បីឲ្យយល់ខុសចំពោះភស្តុតាង។ តាមពិតវាពុំមានភស្តុតាងទាល់តែសោះដែលថាលោក នួន ជា មានតួនាទីនៅក្នុងកិច្ចការយោធា។

ចំពោះភស្តុតាងដែលថាគាត់មានតួនាទីនៅក្នុងកិច្ចសន្តិសុខ គឺមិនស៊ីសង្វាក់ និងមានភាពផ្ទុយគ្នា។ ទាក់ទងនឹងតួនាទីរបស់លោក នួន ជា នៅក្នុងកិច្ចការយោធា សហព្រះរាជអាជ្ញាអះអាងថា សក្ខីកម្មរបស់អ្នកជំនាញនៅចំពោះមុខអង្គជំនុំជម្រះបញ្ជាក់ឲ្យឃើញថា លោក នួន ជា មានតួនាទីនៅក្នុងកិច្ចយោធា និងសន្តិសុខ ហើយថាគាត់ជាសមាជិកនៃគណៈកម្មការយោធា។ ការអះអាងនេះ គឺមិនពិត។ លោក ហ្វីលីព ស្បូត និយាយត្រង់ៗថា ខ្ញុំសូមដកស្រង់៖ "ទេខ្ញុំមិនបានគិតថា នួន ជា មានតួនាទីយោធាទេ"។ ការថ្លែងនេះអាចរកបាននៅក្នុងប្រតិចារឹកសវនាការថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ នៅទំព័រ៨១។ បន្ទាប់មកគាត់និយាយថា ខ្ញុំសូមដកស្រង់៖ "នួន ជា មិនមែនជាផ្នែកមួយរបស់គណៈកម្មាធិការយោធាទេ"។ ការថ្លែងនេះអាចរកបាននៅទំព័រ៨៣ នៃប្រតិចារឹកសវនាការថ្ងៃ០៦ ឧសភា ដដែល។ លោក

ហ្វីលីព ស្ហត បន្ថែមថាគាត់គិត -- ខ្ញុំសូមដកស្រង់៖ "វាពិតដោយគ្មានមន្ទិលសង្ស័យទេថា នួន ជា មិនមែនជាសមាជិកនៃគណៈកម្មាធិការយោធា"។

[១៤:២០:១៤]

សាស្ត្រាចារ្យ ដេវីដ ឆេនល័រ ផ្ដល់សក្ខីកម្មថា គាត់អាចផ្ដល់តែ -- ខ្ញុំសូមដកស្រង់៖ "ការស្មានចំពោះថា តើ នួន ជា មានតួនាទីនៅក្នុងកិច្ចយោធាដែរឬអត់នោះ?" ហើយខ្ញុំចង់បន្ថែមថា ប្រសិនបើអង្គជំនុំជម្រះយោងកថាខណ្ឌ៤៥៧ នៃសារណារបស់សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាអះអាងថា សាស្ត្រាចារ្យ ឆេនល័រ បានផ្ដល់សក្ខីកម្មថា៖ "វាពិបាកណាស់ វាពិបាកជឿណាស់ដែលថា នួន ជា ពុំមានតួនាទីនៅក្នុងកិច្ចការយោធានោះ"។ នេះមិនមែនជាសក្ខីកម្មត្រឹមត្រូវទេ។ ហើយខ្ញុំនឹងសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលសេចក្ដីដកស្រង់ដែលក្នុងនោះសាស្ត្រាចារ្យ ឆេនល័រ មិនបាននិយាយបែបហ្នឹងទេ។ ទី២ សហព្រះរាជអាជ្ញាអះអាងថា៖ "សមាជិកផ្សេងទៀតរបស់បក្សបានដឹងថាពួកគេត្រូវទាក់ទងលោក នួន ជា អំពីបញ្ហាយោធា និងសន្តិសុខ ហើយថាវាឆ្លុះបញ្ចាំងនៅក្នុងសារទូរលេខលើប្រធានបទនេះដែលលោក នួន ជា បានទទួល"។ នេះគឺមិនពិតទេ តាមពិតក្នុងអំឡុងពេលទាំងមូលនៃរបបកម្ពុជាប្រជាធិបតេយ្យជិតបួនឆ្នាំ សហព្រះរាជអាជ្ញាអាចរកបានសារទូរលេខទាក់ទងនឹងកិច្ចការយោធា និងសន្តិសុខតែប្រាំមួយប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនមកចំឈ្មោះលោក នួន ជា។ សហព្រះរាជអាជ្ញាបានយោងដដែលទៅលើសារទូរលេខទាំងនោះលើកទី១ នៅក្នុងសវនាការបង្ហាញឯកសារ ហើយពេលនេះយោងម្ដងទៀតនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការសាកសួរដេញដោលរបស់ពួកគាត់។

[១៤:២២:១៤]

សហព្រះរាជអាជ្ញាបានលើកឡើងដដែលថា៖ "សារទូរលេខទាំងនេះមានសារៈសំខាន់ ពីព្រោះវាបង្ហាញថា សមាជិកដទៃទៀតរបស់បក្សដឹងពីការទាក់ទងលោក នួន ជា អំពីកិច្ចការយោធា"។ តាមពិតសារទូរលេខទាំងនេះសំខាន់ ដោយសារវាជាសារទូរលេខដែលអាចបង្ហាញរាល់ការឆ្លងឆ្លើយគ្នាទាំងអស់លើបញ្ហានានាដែលត្រូវតែបានបញ្ជូនតាមរយៈគាត់ ប្រសិនបើលោក នួន ជា ពិតជាទទួលខុសត្រូវក្នុងកិច្ចយោធា និងសន្តិសុខមែន។ ក្រៅពីមានសារទូរលេខរាប់រយនៅក្នុងភស្តុតាងដែលជាប់ទាក់ទងនឹងកិច្ចយោធា និងសន្តិសុខ វាស្ទើរតែគ្មានសារទូរលេខណាមួយបានបញ្ជូនផ្ទាល់មកលោក នួន ជា ទេ។ សារទូរលេខចំនួនប្រាំមួយនេះ បញ្ជូនពីកម្មាភិបាលយោធាតែមួយ គឺកម្មាភិបាលឈ្មោះ ឌឹម ពីកងពលធំលេខ ១៦៤។ សារទូរលេខចំនួនប្រាំមួយទៀត នេះត្រូវបានផ្ញើមកក្នុងពេលជាប់ៗគ្នាក្នុងខែតុលា ឆ្នាំ១៩៧៦

ហើយសារទូរលេខទាំងនេះពាក់ព័ន្ធនឹងកម្មវត្ថុទូទៅដូចគ្នា។ សារទូរលេខទាំងនេះបង្ហាញថាមានអ្នកណាម្នាក់នៅក្នុងបក្សជឿថា បញ្ហាជាក់លាក់មួយត្រូវតែរាយការណ៍ឲ្យលោក នួន ជា ដឹង។ លោក នួន ជា មិនចាំសារទូរលេខទាំងនេះទេ ហើយក៏មិនបានដឹងថាគេបញ្ជូនសារទូរលេខទាំងនេះមកគាត់ដែរ។ បើទោះជាសារទូរលេខទាំងនេះពិតជាបញ្ជូនមកគាត់ក៏ដោយ។ ប៉ុន្តែវាពិតណាស់ថា សារទូរលេខទាំងនេះមិនពាក់ព័ន្ធនឹងការទទួលខុសត្រូវទូទៅរបស់ នួន ជា ឡើយ។ ហើយសហព្រះរាជអាជ្ញាបន្តពឹងផ្អែកលើសារទូរលេខតែមួយមុខប៉ុណ្ណោះដែលពុំបានបង្ហាញពីភស្តុតាងផ្សេង និងជាក់លាក់អំពីតួនាទីរបស់លោក នួន ជា នៅក្នុងគណៈកម្មាធិការនោះឡើយ។

[១៤:២៤:២៥]

តុលាការជាទីគោរព! ខ្ញុំនឹងធ្វើការអត្ថាធិប្បាយចុងក្រោយមួយ អំពីសារទូរលេខនៅក្នុងភស្តុតាង។ ខ្ញុំនឹងចង្អុលបង្ហាញថា មានសារទូរលេខដ៏ច្រើននៅក្នុងភស្តុតាងដែលត្រូវបានគេបញ្ជូនមកមេដឹកនាំដទៃទៀតរបស់បក្ស ប៉ុន្តែសារទូរលេខទាំងនោះមិនត្រូវបានគេបញ្ជូនទៅលោក នួន ជា ទេ។ ខ្ញុំនឹងផ្តល់លេខឯកសារមួយចំនួន ឯកសារទាំងនេះ រួមមាន: E3/1016, IS216, E3/1176, E3/1186, IS21.2, E3/1076, IS219, E3/1066 និង E3/250។ សារទូរលេខទាំងនេះត្រូវបានបញ្ជូនទៅ អៀង សារី, វន វេត, អៀង ធីរិទ្ធ និងអ្នកដទៃទៀត។ តែមិនបានបញ្ជូនមកលោក នួន ជា។ ហេតុដូច្នេះ សារទូរលេខទាំងនេះខុសពីការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា លោក នួន ជា មានតួនាទីនៅក្នុងកិច្ចយោធា។ សារទូរលេខទាំងនេះ បង្ហាញថាកម្មាភិបាលនៅជុំវិញបក្ស ដឹងថាពួកគេមិនតម្រូវឲ្យទាក់ទងនឹងលោក នួន ជា អំពីកិច្ចការយោធានិងសន្តិសុខឡើយ។ តែពួកគេតម្រូវឲ្យទាក់ទងជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀត ដែលមានមុខងារពាក់ព័ន្ធជាចាំបាច់។

[១៤:២៦:៣៣]

បន្ទាប់មកទៀត សហព្រះរាជអាជ្ញាលើកឡើងពីកិច្ចប្រជុំតែមួយគត់របស់គណៈអចិន្ត្រៃយ៍ដែលលោក នួន ជា ត្រូវបានគេកត់ត្រាថា បានបញ្ចេញមតិទាក់ទងនឹងកិច្ចការយោធា។ កិច្ចប្រជុំនោះ គឺជាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៦។ តែប្រសិនបើអង្គជំនុំជម្រះពិនិត្យឯកសារឡើងវិញដោយប្រុងប្រយ័ត្ននោះ នឹងឃើញយ៉ាងច្បាស់ថា វាពិតជាបង្ហាញថាលោក នួន ជា ពុំមានតួនាទីនៅក្នុងកិច្ចយោធាឡើយ។ ដូចដែលសហព្រះរាជអាជ្ញាចង្អុលបង្ហាញមូលហេតុតែមួយគត់ ដែលលោក នួន ជា បានបញ្ចេញមតិលើបញ្ហាអ្វីមួយនៅកិច្ចប្រជុំនេះ គឺដោយសារតែអវត្តមានរបស់ ប៉ុល

ពត។ នៅពេល ប៉ុល ពត អវត្តមាន ការណែនាំសំខាន់របស់ នួន ជា -- ខ្ញុំសូមដកស្រង់៖ "បន្តការអនុវត្តកិច្ចប្រជុំ"។ ការណែនាំមិនច្បាស់នេះ ត្រូវបានលើកឡើងដោយ ប៉ុល ពត នៅកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍កាលពីពីរសប្តាហ៍មុន។ ដូច្នេះ ជំនួសឲ្យការចេញសេចក្តីណែនាំដោយខ្លួនឯង លោក នួន ជា គ្រាន់តែធ្វើការណែនាំរបស់ ប៉ុល ពត។ និយាយម្យ៉ាងទៀត គឺថា នួន ជា គ្រាន់តែនិយាយឡើងថា "នៅការណែនាំកន្លងមករបស់ ប៉ុល ពល"។ ចំណុចនេះ វាផ្ទុះបញ្ចាំងពីកម្រិតនៃតួនាទីរបស់លោក នួន ជា ក្នុងកិច្ចយោធា។ ពុំមានភស្តុតាងផ្សេងពីនេះទៀតឡើយ។

[១៤:២៨:១៤]

ជាបន្ទាប់ សហព្រះរាជអាជ្ញាចង្អុលថា លោក នួន ជា -- ខ្ញុំសូមដកស្រង់ "ធ្វើជាអធិបតីនៅកិច្ចប្រជុំនាខែកក្កដា ឆ្នាំ១៩៧៥ ទាក់ទងនឹងការកែប្រែឡើងវិញនូវរចនាសម្ព័ន្ធកងទ័ពបដិវត្តន៍កម្ពុជា"។ ពិតណាស់ អង្គជំនុំជម្រះប្រហែលជាដឹងពីកិច្ចប្រជុំនេះ ដូចដែលអង្គជំនុំជម្រះបានជម្រាបហើយ នេះគឺជាការវិវត្តន៍សំខាន់ ដ៏សំខាន់នៃបក្សកុម្មុយនីស្តកម្ពុជា។ គួរឲ្យកត់សម្គាល់ណាស់ គួរឲ្យកត់សម្គាល់ថាជាលើកទី១ ដែលកងទ័ពឯកភាពយោធាមួយ ត្រូវបានដាក់ឲ្យនៅក្រោមការបញ្ជារបស់មជ្ឈិមបក្ស។ កម្មាភិបាលរាប់ពាន់នាក់មានវត្តមាននៅក្នុងពិធីនោះ។

លោក នួន ជា ជាសមាជិកលំដាប់ទី២របស់បក្ស ហើយជាសមាជិកនៃគណៈអចិន្ត្រៃយ៍ និងសមាជិកជាច្រើននៃគណៈមជ្ឈិមក៏ស្ថិតនៅក្នុងពិធីនោះដែរ។ វត្តមានរបស់គាត់ គឺគ្រាន់តែជាការចូលរួមក្នុងពិធីដើម្បីគ្រប់កិច្ចប៉ុណ្ណោះ។ ការចូលរួមនេះ ទាក់ទងនឹងតួនាទីរបស់លោក នួន ជា នៅក្នុងបក្ស។

[១៤:២៩:២៧]

ឥឡូវ ខ្ញុំនិយាយបន្តលើប្រធានបទនៃកិច្ចប្រជុំយោធា។ សក្ខីកម្មដែលពាក់ព័ន្ធបំផុត គឺត្រូវបានផ្តល់សាក្សីដែលបញ្ជាក់ថា លោក នួន ជា មិនមានតួនាទី និងការទទួលខុសត្រូវក្នុងយោធាឡើយ។ សាក្សីទាំងនេះនិយាយថា លោក នួន ជា មិនចូលរួមកិច្ចប្រជុំយោធាឡើយ។ ពួកគេនិយាយថា លោក នួន ជា មិនចូលរួមក្នុងកិច្ចយោធា ដោយសារតែគាត់ពុំមានកិច្ចការអ្វីត្រូវទាក់ទងជាមួយយោធា។ សាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងនោះគឺឈ្មោះ អឿន តាន់ ,អង្គរក្សរបស់ ប៉ុល ពត, បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះថា ការប្រជុំនានារបស់យោធានៅទីក្រុងភ្នំពេញត្រូវបានដឹកនាំដោយ ប៉ុល ពត និងសុន សេន។ អឿន តាន់ បានពន្យល់ជាក់លាក់ថា នួន ជា មិនចូលរួមកិច្ចប្រជុំទាំងនោះទេ។ ពីព្រោះតែគាត់-- ខ្ញុំសូមដកស្រង់៖ "ជាប់ជាមួយផ្នែកផ្សេង" ហើយសក្ខីកម្មនោះគឺផ្តល់នូវថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២

នៅទំព័រ១៦ និង៤១ នៃប្រតិចារឹកសវនាការនៃថ្ងៃនោះ។ សាក្សីម្នាក់ទៀតឈ្មោះ មាស វឿន ដែលអាចជាមន្ត្រីយោធាជាន់ខ្ពស់បំផុតដែលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ នៅចុងបញ្ចប់នៃកម្ពុជាប្រជាធិបតេយ្យ គាត់ជាមេបញ្ជាការរងកងពលធំ និងដើរតួជាលេខានៃតំបន់១០៣។ គាត់បាននិយាយថាលោក នួន ជា មិនចូលរួមកិច្ចប្រជុំយោធាភូមិភាគទេ។ តាមពិតគាត់បាននិយាយដដែលលើចំណុចនេះ។ ក្នុងការនិយាយបែបនេះ គាត់បាននិយាយដោយផ្ទាល់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ជាមួយចៅក្រមស៊ើបអង្កេតដែលបង្ហាញច្បាស់លាស់ថា លោក នួន ជា ជាប់ពាក់ព័ន្ធជាមួយកិច្ចការយោធាគឺពិតជាមិនត្រឹមត្រូវទេ។ សក្ខីកម្មនេះផ្តល់នូវថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ រវាងទំព័រ៤៦ និង៥៤។

[១៤:៣១:៥២]

ដោយសារ ហើយជាថ្មីម្តងទៀតនៅថ្ងៃសវនាការបន្ទាប់ គឺថ្ងៃ០៨ ខែតុលា ឆ្នាំ២០១២ រវាងទំព័រ ៩២ និង៩៨។ ជាបន្ទាប់សហព្រះរាជអាជ្ញាយោងឯកសារមួយពីអ្នកនាំសារវៀតណាម ពីឆ្នាំ១៩៧២ ដែលពិពណ៌នាពីតួនាទីរបស់លោក នួន ជា។ ខ្ញុំសូមសូមដកស្រង់៖ "ជាប្រមុខនៃមេដឹកនាំនយោបាយរបស់កងទ័ព។ ចំណារលើឯកសាររបស់អ្នកនាំសារវៀតណាមនេះមិនត្រឹមត្រូវទេ ដោយសារមុខតំណែងនេះមិនមាននៅក្នុងរចនាសម្ព័ន្ធជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាទេ។ ប្រការដែលអាចឲ្យកើតមានឡើងបែបនេះ គឺប្រហែលជាមានការភាន់ច្រឡំដោយសារអ្នកនាំសារវៀតណាមមិនបានដឹងច្បាស់ពីតួនាទី និងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា។ ពីព្រោះលោក នួន ជា បានធ្វើការអប់រំនយោបាយដល់កងទ័ពមិនខុសពីអ្វីដែលគាត់បានអប់រំកម្មាភិបាលជាច្រើនទៀតអំពីគោលដៅនយោបាយរបស់បក្សនោះទេ។

នៅក្នុងឯកសារនោះក៏បានបង្ហាញយ៉ាងច្បាស់ថា សុន សេន -- ខ្ញុំសូមដកស្រង់៖ "ជាសេនាធិការជានាយសេនាធិការ"។ វាបង្ហាញយ៉ាងច្បាស់ដែលថា ប៉ុល ពត ខ្ញុំសូមដកស្រង់ "ទទួលបន្ទុកកិច្ចការកងទ័ព"។

ខ្ញុំសូមចូលដល់ -- លោកប្រធាន ដល់ម៉ោងសម្រាក ដូចនេះខ្ញុំអាចបន្តបានទៅទៀត។ ខ្ញុំនៅសល់ប្រហែលជាពាក់កណ្តាល។ សល់២០ទំព័រទៀត។

**ប្រធានអង្គជំនុំ៖**

បន្តទៀតរហូតដល់ម៉ោងបី ខ្វះម្ភៃនាទីទើបសម្រាក។ សល់ប្រាំនាទីទៀត។

បើកក្បាលមីក្រូ លោកមេធាវី!

[១៤:៣៤:០៧]

**លោក សុន អរុណ៖**

ខ្ញុំសូមនិយាយពី ស-២១។ ក្រៅពីកិច្ចប្រឹងប្រែងគ្មានផ្អែផ្កា ដើម្បីបង្ហាញពីតួនាទីរបស់លោក នួនជា នៅក្នុងកិច្ចការសន្តិសុខ សហព្រះរាជអាជ្ញាបានប្រឹងប្រែងចោទប្រកាន់បន្ថែមយ៉ាងច្រើន ដោយសន្មតថាលោក នួន ជា មានតួនាទីនៅមន្ទីរស-២១។ ការប្រកាន់ទាំងអស់នេះ គឺមិនមែនជាការពិត ហើយគ្រាន់តែជាភស្តុតាងដែលមានការ -- មានភាពផ្ទុយគ្នា និងមិនអាចឲ្យជឿជាក់បាន។ ជាការពិតភស្តុតាងតែមួយដែលថាលោក នួន ជា មានតួនាទីនៅស-២១ គឺបានមកពី កាំង ហ្កេកអ៊ាវ ហៅ ឌុច តែប៉ុណ្ណោះ។ ទាក់ទងនឹងករណីនេះ ឌុច មានមូលដ្ឋានសមរម្យដើម្បីធ្វើឲ្យអង្គជំនុំជម្រះភ័ន្តច្រឡំ។ ក្រៅពីនេះ សហព្រះរាជអាជ្ញាពុំមានភស្តុតាងណាបញ្ជាក់ផ្សេងឡើយ។ ដូចនេះអង្គជំនុំជម្រះគប្បីបដិសេធសក្ខីកម្មទាំងនេះចោល។

[១៤:៣៥:១៨]

ជាបញ្ហាបឋម ដោយសារផលវិបាកនៃការកម្រិតវិសាលភាព នៃការជំនុំជម្រះនេះយើងខ្ញុំសូមបញ្ជាក់ជំហររបស់ខ្ញុំឡើងវិញថា អង្គជំនុំជម្រះនេះមិនអាចមានសមត្ថភាពក្នុងការស្វែងរកអង្គហេតុទាក់ទងនឹងមន្ទីរស-២១ឡើយ ប៉ុន្តែស-២១ ត្រូវបានដកចេញពីការជំនុំជម្រះនេះដោយអង្គជំនុំជម្រះ។ ទោះបីជាមានសំណើដដែលៗដោយសហព្រះរាជអាជ្ញាសុំដាក់បញ្ចូលទៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះ។

យើងទទួលស្គាល់កថាខណ្ឌខ្លីចំនួនបីនៃដីកាដំណោះស្រាយ រួមបញ្ចូលនូវវិសាលភាពនៃការជំនុំជម្រះនេះបានចោទប្រកាន់ជាទូទៅមួយចំនួនតូចអំពីតួនាទីរបស់លោក នួន ជា នៅមន្ទីរស-២១។ ប៉ុន្តែអង្គហេតុមួយចំនួនផ្សេងទៀតនៃការពាក់ព័ន្ធសំខាន់ចំពោះ តួនាទីរបស់លោក នួន ជា ត្រូវបានបង្ហាញមិនច្បាស់លាស់។ អង្គហេតុនេះរួមមាន ២៦ជាកថាខណ្ឌ នៃដីកាដំណោះស្រាយចាប់ពីកថាខណ្ឌ ៨៤៩ ដល់កថាខណ្ឌ ៨៧៤ដែលពាក់ព័ន្ធនឹងតួនាទីដោយ សន្មតរបស់លោក នួន ជា នៅមន្ទីរស-២១។ តែអង្គហេតុទាំងអស់នេះត្រូវបានដកចេញពីវិសាលភាពនៃការជំនុំជម្រះនេះ។ ដូចដែលយើងនឹងឃើញឆាប់ៗនេះ អង្គហេតុនៃការពាក់ព័ន្ធដ៏សំខាន់ជាច្រើន ទាក់ទងទៅនឹងបញ្ហានៃការជាប់ទាក់ទងរបស់លោក នួន ជា គឺស្ថិតនៅក្នុងចំណោមអង្គហេតុដែលត្រូវបានបដិសេធចោល។ បើមន្ទីរស-២១ នឹងត្រូវដាក់បញ្ចូលទៅក្នុងវិសាលភាពនៃការជំនុំជម្រះបច្ចុប្បន្ន ក៏ភស្តុតាងដ៏កម្រិតនេះមិនអាចបង្ហាញថាលោក នួន ជា មានតួនាទីនៅស-២១ ដែរ។

[១៤:៣៧:២៥]

ជាបឋម សហព្រះរាជអាជ្ញាព្យាយាមធ្វើការ ធ្វើឲ្យអង្គជំនុំជម្រះនេះជឿថា តួនាទីរបស់លោក នួន ជា នៅមន្ទីរស-២១ ត្រូវបានបង្ហាញដោយអង្គហេតុដែលថា លោក នួនជា បានទទួលចម្លើយសារភាពនៃមន្ទីរស-២១ ពីឌុច។ តែអនុលោមតាមភស្តុតាងរបស់សហព្រះរាជអាជ្ញាលោក នួន ជា ត្រូវបានសន្មតថា បានឃើញចម្លើយសារភាពចំនួន២៥។ សំណួររបស់យើងគឺថា តើចម្លើយសារភាពចំនួន២៥ គឺជាអ្វី? តើចម្លើយសារភាពចំនួន២៥ គឺជាចម្លើយសារភាពចំនួនច្រើនឬទេ? តើចម្លើយសារភាពចំនួន ២៥ នៃចម្លើយសារភាពចំនួនប៉ុន្មានដែលគេបានធ្វើនៅមន្ទីរស-២១? តើមានចម្លើយសារភាពចំនួនប៉ុន្មាននៅក្នុងសំណុំរឿងនេះ? តើមានចម្លើយសារភាពចំនួនប៉ុន្មានត្រូវបានគេរកឃើញនៅមន្ទីរស-២១? តើមានចម្លើយសារភាពចំនួនប៉ុន្មានត្រូវបានគេរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឌី.ស៊ី.ខេម?

[១៤:៣៨:៣៩]

តុលាការជាទីគោរព! អនុលោមតាមកំណត់ត្រានៅក្នុងសំណុំរឿងចម្លើយសារភាពសរុបដែលអាចរកបានគឺមានចំនួន៤១៨៩។ ឥឡូវនេះយើងខ្ញុំដឹងថា នៅពេលចាប់ផ្តើមការស៊ើបសួរពីព្រឹត្តិការណ៍នានា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យចម្លើយសារភាពនៅមន្ទីរស-២១ គឺជាប្រភពដ៏សំខាន់បំផុតនៃភស្តុតាងប្រវត្តិសាស្ត្រ។ ចាប់ពីពេលវៀតណាមចូលកាន់កាប់ប្រទេសកម្ពុជាភ្លាម សាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះមន្ទីរស-២១។ អង្គជំនុំជម្រះនេះបានស្តាប់សក្ខីកម្មរបស់បុគ្គលិកដែលធ្វើនៅមន្ទីរស-២១ បានពិនិត្យមើលឯកសារនៅទីនោះចាប់តាំងពីរដូវក្តៅឆ្នាំ១៩៧៩មកម្ល៉េះ។ អ្នកប្រវត្តិវិទូឈានមុខជាច្រើនដែលក្រោយមកមានតួនាទីដ៏សំខាន់នៅក្នុងការបង្កើតអង្គហេតុចោទប្រកាន់នៅតុលាការនេះ បានចំណាយពេលជាច្រើនឆ្នាំក្នុងការពិនិត្យ និងវិភាគឯកសារទាំងនេះ។ អ្នកប្រវត្តិវិទូទាំងនោះសរសេរសៀវភៅដ៏វែងអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ពួកគេមួយចំនួនត្រូវបានផ្តល់លក្ខណៈសម្បត្តិជាអ្នកជំនាញដោយតុលាការនេះ។ បន្ទាប់ពីបានធ្វើកិច្ចការដ៏ច្រើនបែបនេះ បែរជាអ្នកជំនាញទាំងនោះបានរកឃើញតែចម្លើយសារភាពត្រឹមតែ២៥ប៉ុណ្ណោះ។

ប្រសិនបើលោក-លោកស្រីចៅក្រម អនុញ្ញាតខ្ញុំនឹងដកស្រង់ប្រយោគមួយគឺដីកាដំណោះស្រាយ។

[១៤:៤០:២៥]

អនុលោមតាមដីកាដំណោះស្រាយ តួនាទីដ៏សំខាន់របស់មន្ទីរស-២១ គឺយកចម្លើយសារភាពពីអ្នកទោស។ ចំណុចនេះ គឺមាននៅកថាខណ្ឌ៤៥៥ ឥឡូវនេះ ប្រសិនតួនាទីដ៏សំខាន់របស់មន្ទីរស-២១ គឺយកចម្លើយសារភាពមែន។ តើអ្នកគ្រប់គ្រងផ្ទាល់លើប្រធានមន្ទីរត្រូវតែបានឃើញចម្លើយសារភាពទាំង

អស់នោះ,មន្ទីរស-២១, ដោយទៀងទាត់ដែរឬទេ ហើយបន្ទាប់ពីបានពិនិត្យភស្តុតាងបីទសវត្សរ៍កន្លងមក? តើមានភស្តុតាងជាដុំកំភួនអ្វីខ្លះដើម្បីបង្ហាញថាលោក នួន ជា បានឃើញចម្លើយសារភាពទាំងនោះដែរឬទេ? តើលោកទាំងបី -- តើលោក -- សូមទោស តែបើទោះបីយើងទទួលស្គាល់ថារាល់អង្គហេតុទាំងអស់ដែលសហព្រះរាជអាជ្ញាអះអាងថាវាពិតទៅចុះ! យើងនឹងអាចសន្និដ្ឋានថាលោក នួន ជា ទទួលបានចម្លើយសារភាពតិចជាងពាក់កណ្តាលនៃភាគរយនៃចម្លើយសារភាពដែលមាន។ ភស្តុតាងជាសាក្សី -- ជាសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺច្បាស់ណាស់ថាលោក នួន ជា ទទួលបានចម្លើយសារភាពមួយចំនួនតូចនៃចម្លើយសារភាពនៅស-២១តែប៉ុណ្ណោះ។ ដូចដែលសហព្រះរាជអាជ្ញាបានអង្កេតយ៉ាងត្រឹមត្រូវ សាក្សីម្នាក់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះថាគាត់បានយកស្រោមសំបុត្រពី ឌុច និងបានបញ្ជូនស្រោមសំបុត្រទាំងនោះមកលោក នួន ជា តែសហព្រះរាជអាជ្ញាបំបាត់ចោលព័ត៌មានលម្អិត។

[១៤:៤២:២២]

សហព្រះរាជអាជ្ញាបំបិទចោលអង្គហេតុដែលថា សាក្សី សាត ទឿង បានផ្តល់សក្ខីកម្មថា បានប្រគល់ឲ្យលោក នួន ជា នៅឯកសារពី ឌុច ចំនួនប្រាំលើក។ ឥឡូវនេះ សហព្រះរាជអាជ្ញាអង្កេតថា អនុលោមតាម ឌុច មានតែនីរសារពីរនាក់ទេដែលទទួលខុសត្រូវប្រគល់ចម្លើយសារភាពមកឲ្យលោក នួន ជា។ ឌុច បានកំណត់អត្តសញ្ញាណនីរសារទាំងពីរនាក់នេះដោយហៅចំឈ្មោះ នីរសារម្នាក់ឈ្មោះ សាត ទឿង -- សូត្រ ទឿង។ ឈ្មោះ សូត្រ ទឿង នេះបានផ្តល់សក្ខីកម្មថា ខ្លួនបានប្រគល់ឲ្យលោក នួន ជា នូវឯកសារពី ឌុច ចំនួនប្រាំលើកគត់។

លោក លោកស្រីចៅក្រម តាមទស្សនៈរបស់យើងខ្ញុំបង្ហាញទាំងអស់នេះនាំឲ្យលេចចេញនូវសំណួរដ៏សំខាន់មួយ។ សំណួរ គឺថាហេតុអ្វីបានជាឯកសារក្នុងចំនួនតិចតួចនេះត្រូវបានបញ្ជូនមក នួន ជា? សហព្រះរាជអាជ្ញានិយាយថា ឯកសារទាំងនេះត្រូវបានបញ្ជូនមកលោក នួន ជា ដោយសារតែឯកសារនេះមកពីមន្ទីរស-២១ ហើយលោក នួន ជា ទទួលបន្ទុកលើមន្ទីរស-២១។ ប្រសិនបើការលើកឡើងនេះ ជាការពិត ចម្លើយសារភាពជាច្រើនគួរតែត្រូវបានបញ្ជូនមកលោក នួន ជា។

**ប្រធានអង្គជំនុំ៖**

លោក បាន១ មេធាវីដល់ពេលសមល្មមសម្រាកហើយ ឥឡូវដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសឡើងបន្តធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានសាជាថ្មី។ ខ្ញុំនឹងបន្តសារណារបស់ខ្ញុំក្នុងរយៈពេលប្រហែលមួយម៉ោងទៀត។

លោក លោកស្រីចៅក្រមជាទីគោរព! លោក នួន ជា សួរថាអង្គជំនុំជម្រះនេះនៅចាំបានទេថា លោក នួន ជា គឺអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ ប្រសិនបើលោក នួន ជា មានអំណាចដូចនោះមែន កម្មាភិបាលពីអង្គភាពជាច្រើនគួរបញ្ជូនឯកសារមកឱ្យគាត់មើល។ លោក នួន ជា មិនដែលស្នើឱ្យគេបញ្ជូនឯកសារទាំងនេះមកខ្លួនឡើយ។ ជានិច្ចកាលលោក នួន ជា ក៏មិនឃើញឯកសារទាំងនេះដែរ។ លោក នួន ជា ប្រាកដជាមិនទទួលបន្ទុកដោយផ្ទាល់លើអង្គភាពដែលបញ្ជូនឯកសារទាំងនេះឱ្យមកខ្លួនដែរ។ តើអនុប្រធានប្រធានាធិបតីសហរដ្ឋអាមេរិក ដែលទទួលបន្ទុកនាយកដ្ឋានទាំងអស់របស់រដ្ឋាភិបាល ត្រូវតែគេបញ្ជូនអនុស្សរណៈមកគាត់ដែរឬទេ?

សក្ខីកម្មរបស់ ឌុច និង សួគ្រ ឡើង តែប៉ុណ្ណឹងមិនអាចបង្ហាញអ្វីទាំងអស់។ យើងខ្ញុំស្នើសូមអង្គជំនុំជម្រះកត់សម្គាល់ថា ក្នុងករណីលើកលែងចម្លើយសារភាពស្ទើរតែទាំងអស់ ដែលបង្ហាញដោយសហព្រះរាជអាជ្ញាមានព័ត៌មានដែលអាចប្រើបាន ឬអាចកំណត់អត្តសញ្ញាណបានក្រៅតែពីអង្គហេតុដែលថា សំណៅនៃចម្លើយសារភាពមួយត្រូវបានបញ្ជូនមក “បងនួន”។

[១៥:០៤:៣៩]

សំណួរសំខាន់ៗទាំងអស់មិនមានចម្លើយទាល់តែសោះ ថាតើហេតុអ្វីបានជាសំណៅនោះត្រូវបញ្ជូនមកលោក នួន ជា? តើនរណាជាអ្នកសម្រេចឱ្យបញ្ជូនសំណៅនេះមកលោក នួន ជា? តើបុគ្គល

ដែលសម្រេចបញ្ជូនសំណៅនេះមកលោក នួន ជា គឺត្រឹមត្រូវទេ ថាតើលោក នួន ជា ចង់បាន ឬត្រូវមើលសំណៅនេះដែរឬទេ? តើលោក នួន ជា ធ្លាប់បានទទួលវាឬទេ? លោក លោកស្រីចៅក្រម លោក នួន ជា បានផ្តល់ចម្លើយរួចមកហើយចំពោះសំណួរមួយចំនួនខាងលើ។ ដូចដែលលោក នួន ជា បានពន្យល់លើសេចក្តីថ្លែងការណ៍នៅក្នុងខ្សែវីដេអូ ក្នុងសំណុំរឿងលោក នួន ជា បានប្រើចម្លើយសារភាពតិចតួចសម្រាប់គោលបំណងអប់រំ។

៣៥ឆ្នាំក្រោយមកលោក នួន ជា មិនចាំពិតប្រាកដថា លោក នួន ជា បានប្រើចម្លើយសារភាពមួយណាទេ។ ចំណុចនេះវាពន្យល់ពីមូលដ្ឋានដែលចម្លើយសារភាពមួយចំនួនតូចអាចត្រូវបានបញ្ជូនមកឲ្យលោក នួន ជា។ ការពន្យល់នេះមានភាពស្របគ្នាជាមួយឯកសារភាស្តុតាងច្រើនជាង ការអះអាងដ៏ចម្លែករបស់សហព្រះរាជអាជ្ញាដែលថាលោក នួន ជា ជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយស-២១។

[១៥:០៦:២០]

សហព្រះរាជអាជ្ញាក៏បានអង្កេតឃើញពីមុនមកថា ចម្លើយសារភាព១៣នៃចម្លើយសារភាព២៥ដែលត្រូវចោទប្រកាន់ថាបានបញ្ជូនមកលោក នួន ជា ហាក់ដូចជាជាប់ពាក់ព័ន្ធអង្គភាពយោធាតែមួយគត់។ វាអាចថាចម្លើយសារភាពទាំងនេះត្រូវបានបញ្ជូនមកលោក នួន ជា មិនមែនដោយសារតែមន្ទីរស-២១ មានភារកិច្ចត្រូវបញ្ជូនឯកសារនោះមកឲ្យលោក នួន ជា ជាផ្លូវការទេ។ ប៉ុន្តែដោយសារចម្លើយសារភាពទាំងនេះជាប់ពាក់ព័ន្ធនឹងកងអង្គភាពយោធាមួយដែលលោក នួន ជា មានផលប្រយោជន៍មួយចំនួនក្នុងហេតុផលណាមួយនោះ លោក នួន ជា បានភ្លេចយូរណាស់មកហើយ។ តាមពិតសហព្រះរាជអាជ្ញាបានប្រកាន់យកជំហរបែបនេះកាលពីលើកមុន។ សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា "មូលហេតុដែលចម្លើយសារភាពទាំងនេះត្រូវបានគេបញ្ជូនមកលោក នួន ជា គឺដោយសារលោក នួន ជា មានតួនាទីទាក់ទងនឹងយោធា និងការបោសសម្អាតនៅក្នុងអង្គភាពនេះ"។ នេះគឺជាសម្រង់នៅទំព័រ៥៩ នៃប្រតិចារិកនៃថ្ងៃសវនាការទី២៧ ខែមិថុនា។

[១៥:០៧:៥៤]

ពេលនេះ លោក លោកស្រីចៅក្រមពិតជាយល់យ៉ាងច្បាស់ថា លោក នួន ជា មិនយល់ស្របចំពោះតួនាទីរបស់គាត់ក្នុងការបោសសម្អាតនៅអង្គភាពយោធាមួយរបស់ភូមិភាគកណ្តាលឡើយ។ សហព្រះរាជអាជ្ញាមិនអាចពន្យល់ឲ្យបានច្បាស់លាស់ទាក់ទងនឹងតួនាទីរបស់លោក នួន ជា នៅមន្ទីរស-២១ ឡើយ។

យើងខ្ញុំសូមសួរថា ដោយសារតែឯកសារទាំងនេះត្រូវបានបញ្ជូនពីមន្ទីរស-២១មកលោក នួន ជា ទើបសហព្រះរាជអាជ្ញាគិតថា លោក នួន ជា មានតួនាទីនៅមន្ទីរស-២១ តែម្តងឬ? តើឯកសារទាំងនេះត្រូវបានបញ្ជូនមកលោក នួនជា ដោយសារវាជាប់ពាក់ព័ន្ធជាមួយអង្គភាពយោធាមួយនៅភូមិភាគបស្ចិម? ហើយលោក នួន ជា ជាប់ពាក់ព័ន្ធជាមួយអង្គភាពយោធានោះដែរឬទេ? ឬមួយក៏ឯកសារទាំងនេះត្រូវបានបញ្ជូនមកលោក នួន ជា ដោយមូលហេតុផ្សេងវិញ? ឯកសារទាំងនេះមិនបាននិយាយលើចំណុចទាំងនោះទេ។ សហព្រះរាជអាជ្ញាក៏មិនបានដឹង ហើយអង្គជំនុំជម្រះនេះក៏មិនអាចសម្រេចបានដែរ។

[១៥:០៩:២៦]

បន្ទាប់មកសហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា បានប្រាប់ ថេត សម្បត្តិ -- ខ្ញុំសូមដកស្រង់៖ "ថាគាត់បានទទួលចម្លើយសារភាពជាច្រើន គាត់មិនអាចអានចម្លើយសារភាពទាំងអស់ទេ"។ សូមបិទការដកស្រង់។ នោះគឺមិនមែនជាការពិត អ្វីដែលលោក នួន ជា បានប្រាប់ ថេត សម្បត្តិ នោះគឺពិតជាមិនអាចអានចម្លើយសារភាពទាំងអស់បានទេ ពីព្រោះវាច្រើន។ លោក នួន ជា មិនដែលសារភាពថាបានទទួលចម្លើយសារភាពទាំងអស់នោះទេ។ ហើយដូចដែលភស្តុតាងបង្ហាញស្រាប់។ លោក នួន ជា មិនដែលទទួលចម្លើយសារភាពទាំងអស់នោះទេ។ ដូច្នេះ ការអះអាងរបស់សហព្រះរាជអាជ្ញាត្រង់ចំណុចនេះវាផ្ទុយពីភស្តុតាងដែលបានបង្ហាញរួចមកហើយថាលោក នួន ជា មិនបានទទួលចម្លើយសារភាពទាំងអស់នោះទេ។ ដោយមិនអាចបង្ហាញភស្តុតាងជាដុំកំភួនថា លោក នួន ជា បានទទួលចម្លើយសារភាពនៅមន្ទីរស-២១ សហព្រះរាជអាជ្ញាអះអាងថាតួនាទីរបស់លោក នួន ជា នៅស-២១ គាំទ្រដោយចំណារដែលត្រូវបានសន្មតថាលោក នួន ជា សរសេរលើចម្លើយសារភាពទាំងនោះ។ សហព្រះរាជអាជ្ញាអះអាងថាចម្លើយសារភាពចំនួនប្រាំមួយមានចំណារដែលសរសេរដោយដៃលោក នួន ជា។

[១៥:១១:០៨]

អនុញ្ញាតឲ្យខ្ញុំចាប់ផ្តើមដោយការពិនិត្យលើតម្លៃនៃការអះអាងនោះ។ ចូលយើងសន្មតថា លោក នួន ជាបានធ្វើចំណារលើចម្លើយនៅមន្ទីរស-២១ ចំនួនប្រាំមួយ។ តើចំណារនោះនឹងបានបង្ហាញអ្វីខ្លះអំពីតួនាទីរបស់លោក នួន ជា នៅមន្ទីរស-២១នោះ។ នោះវាគ្រាន់តែបង្ហាញថាលោក នួន ជា មិនមានតួនាទីអ្វីទាំងអស់។ វាគ្រាន់តែបង្ហាញថាលោក នួន ជា មិនបានធ្វើចំណារលើចម្លើយសារភាពចំនួន៤១៨៣ ក្នុងចំណោមចម្លើយសារភាពចំនួន៤១៨៩ នៅក្នុងកំណត់ត្រា។ តើវាឥរិយាបថរបស់បុរសម្នាក់ដែលជាអ្នកគ្រប់គ្រងពីលើខុច ផ្ទាល់និងជាប្រធានតាមស្ថានការរបស់មន្ទីរស-២១។ ច្បាស់ណាស់វាមិនដូច្នេះទេ។

បើទោះជាមានការចោទប្រកាន់ថា នួន ជា បានធ្វើចំណារលើចម្លើយសារភាពទាំងប្រាំមួយ ក៏វាមិនបានគាំទ្រដោយភស្តុតាងណាមួយដែរ។ តាមពិតភស្តុតាងដែលថាលោក នួន ជា បានធ្វើចំណារលើចម្លើយសារភាពចំនួនប្រាំមួយ គឺមិនសមហេតុផល។ ហើយការបន្តពឹងផ្អែកលើភស្តុតាងនេះដោយសហព្រះរាជអាជ្ញា គឺកំពុងធ្វើឱ្យគេភ័ន្តច្រឡំ ហើយកំពុងតែបង្ហាញពីគុណភាពរបស់ភស្តុតាងប្រឆាំងនឹងលោក នួន ជា។

[១៥:១២:៥៣]

សហព្រះរាជអាជ្ញាអះអាងដដែលៗថា ឌុច បានកំណត់អត្តសញ្ញាណ អក្សរសរសេរដោយដៃរបស់លោក នួន ជា នៅលើចម្លើយសារភាព និងមន្ទីរស-២១។ តើការអះអាងនេះពិតឬទេ? តើអ្វីទៅជាសក្ខីកម្មពិតប្រាកដរបស់ ឌុច អំពីចំណារទាំងនោះ? សក្ខីកម្មពិតប្រាកដរបស់ ឌុច គឺថាក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ចម្លើយសារភាពដែល ឌុច បញ្ជូនទៅថ្នាក់លើរបស់ខ្លួនមិនដែលបញ្ជូនត្រឡប់មកមន្ទីរស-២១វិញទេ។ ឌុច បានឃើញចំណារនៅលើចម្លើយសារភាពនៅមន្ទីរស-២១ លើកដំបូងគឺនៅខែមេសា ឆ្នាំ១៩៩៩ នៅពេល នេត ថាយ័រ បង្ហាញ ឌុច។ សក្ខីកម្មរបស់ ឌុច ទាក់ទងនឹងបង្ហាញនេះ គឺច្បាស់លាស់ណាស់។

អនុញ្ញាតឱ្យខ្ញុំអានសេចក្ដីដកស្រង់យ៉ាងខ្លីពីសក្ខីកម្មរបស់ ឌុច នៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២។ “សំណួរ៖ គ្រាន់តែឱ្យប្រាកដពីកាលបរិច្ឆេទ តើអ្នកបានឃើញជាលើកដំបូងនូវចម្លើយសារភាពដែលចំណារដោយមេរបស់អ្នកនៅពេលណា? ចម្លើយ គឺខែមេសា ឆ្នាំ១៩៩៩”។ សម្រង់នេះនៅទំព័រ៨២ នៃប្រតិចារឹកថ្ងៃសវនាការទី០៤ ខែមេសា។ ដូច្នោះ ឌុច បានសារភាពថាគាត់មិនដឹងពីចំណារណាមួយនៅលើចំណារសារភាពនៅមន្ទីរស-២១ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យឡើយ។ តាមពិត គាត់បានប្រាប់យើងយ៉ាងច្បាស់ទៅសហចៅក្រមស៊ើបអង្កេតថា គាត់មិនអាចកំណត់អត្តសញ្ញាណអក្សរសរសេរដៃរបស់លោក នួន ជា បានទេ។ នៅពេលសហចៅក្រមស៊ើបអង្កេតបង្ហាញ ឌុច នូវចំណារមួយក្នុងចំណោមចំណារទាំងប្រាំមួយ ដែលសហព្រះរាជអាជ្ញាអះអាងថាជាចំណាររបស់ នួន ជា នោះ ឌុច ថ្លែងដូចខាងក្រោម៖

[១៥:១៥:៥១]

ខ្ញុំសូមដកស្រង់៖ “ខ្ញុំមិនដឹងអ្នកណាសរសេរវាទេ ប៉ុន្តែក៏មិនមែនជារបស់ ប៉ុលពត ដែរ។ អក្សរសរសេរដៃនេះ ស្រដៀងអក្សរសរសេរដៃរបស់ខ្ញុំ។ ដូចអក្សរសរសេរដៃរបស់ សុន សេន និង វន វេត។

ប្រហែលជា នួន ជា សរសេរវា ប៉ុន្តែនេះជាការសន្មតរបស់ខ្ញុំទេ ពីព្រោះខ្ញុំមិនដែលបានឃើញអក្សរសរសេរដៃរបស់គាត់ញឹកញាប់ទេ” បញ្ចប់ការដកស្រង់។ នេះគឺជាការស្តាប់ចម្លើយ ឌុច ដោយចៅក្រមស៊ើបអង្កេត។ វាជាឯកសារលេខ E3/355។ ទោះបីជានេះ គឺជាភស្តុតាងយ៉ាងច្បាស់លាស់បញ្ជាក់ថាលោក នួន ជា មិនមានតួនាទីនៅស-២១ ក៏សហព្រះរាជអាជ្ញានៅតែអះអាងថាលោក នួន ជា បានសារភាពអំពីតួនាទីប្រាប់ ថេត សម្បត្តិ។ ការអះអាងនោះគឺមិនពិត ខ្សែអាត់ថតសម្លេង និងវីដេអូរាប់ពាន់ម៉ោងអំពីលោក នួន ជា មិនបង្ហាញពីការដែលលោក នួន ជា បានសារភាពបែបនេះទេ។ លោក នួន ជា ជួបសន្ទនាជាមួយ ថេត សម្បត្តិ ជាច្រើនឆ្នាំ។ ពួកគេពិភាក្សាយ៉ាងទូលំទូលាយអំពីបញ្ហាសត្រូវ។ ពួកគេបានពិភាក្សាអំពីចម្លើយសារភាពនៅមន្ទីរស-២១។ លោក នួន ជា មិនដែលនិយាយ ព្រលយពាក្យសម្តី ឬលើកឡើងថាគាត់ជាមេរបស់ ឌុច នៅមន្ទីរស-២១ ឡើយ។ នេះជាភស្តុតាងច្រានចោលពីទំនាក់ទំនងបែបនេះ។

[១៥:១៧:៥៣]

សហព្រះរាជអាជ្ញាអះអាងថា កថាខណ្ឌតែមួយគត់ពីសៀវភៅរបស់លោក ថេត សម្បត្តិ, “នៅពីក្រោយវាលពិឃាត–*ប៊ីហាញ ឌឺ ឃៀលីង ហ្វៀល*” បង្កើតបានជាការសារភាពដែលថាលោក នួន ជា គ្រប់គ្រងមន្ទីរស-២១។ តែនៅក្នុងកថាខណ្ឌដែលសហព្រះរាជអាជ្ញាសំអាងបាត់ចំណុចដ៏សំខាន់មួយសេចក្តីថ្លែងការណ៍ជាក់ស្តែងរបស់លោក នួន ជា អ្វីដែលមាននៅក្នុងកថាខណ្ឌនោះ គឺជាមតិយោបល់របស់អ្នកនិពន្ធតែប៉ុណ្ណោះ។ សៀវភៅរបស់លោក ថេត សម្បត្តិ មានសម្រង់សម្តីផ្ទាល់របស់លោក នួន ជា។ សម្រង់សម្តីផ្ទាល់បែបនេះមានយ៉ាងច្រើនអាចមានរាប់រយឯណោះ។ តែនៅក្នុងកថាខណ្ឌដែលសហព្រះរាជអាជ្ញានិយាយថា បានបង្កើតជាការសារភាពរបស់លោក នួន ជា អំពីតួនាទីរបស់គាត់នៅស-២១ នោះ គឺពុំមានស្រង់សម្តីផ្ទាល់ពីលោក នួន ជា សូម្បីតែមួយម៉ាត់ក៏គ្មានដែរ។ ខ្ញុំស្នើសុំអង្គជំនុំជម្រះពិចារណាដូចខាងក្រោម៖

[១៥:១៩:១៥]

ប្រសិនបើលោក នួន ជា បានសារភាពប្រាប់ ថេត សម្បត្តិ ថា គាត់មានតួនាទីនៅស-២១, ដែលជាទីតាំងឧក្រិដ្ឋកម្មដ៏ល្បីបំផុតនៅកម្ពុជាប្រជាធិបតេយ្យ, ហេតុអ្វីបានជា ថេត សម្បត្តិ មិនបាននិយាយអំពីរឿងនេះឲ្យបានច្បាស់លាស់ទៅ? ប្រសិនបើលោក នួន ជា បានប្រាប់ ថេត សម្បត្តិ ថាគាត់មានតួនាទីនៅមន្ទីរស-២១ ហេតុអ្វីបានជាការសារភាពនេះមិនអាចឃើញនៅក្នុងភាពយន្តឯកសារដែលមានចំណង

ដើងថា "សត្រូវរបស់ប្រជាជន"ផង? ប្រសិនបើលោក នួន ជា មានបានសារភាពមែននោះ ការសារភាពនោះពិតជាមាននៅក្នុងភាពយន្តនេះហើយ។ តែជាក់ច្បាស់ណាស់ គឺលោក នួន ជា មិនបានសារភាពទេ ហេតុអ្វី? ដោយសារតែគាត់មិនដែលបានគ្រប់គ្រងលើមន្ទីរស-២១ នេះទាល់តែសោះ។ ប្រសិនបើអង្គជំនុំជម្រះពិនិត្យប្រភពដែលផ្អែកនៅក្នុងសៀវភៅរបស់ ថេត សម្បត្តិ ប្រភពនោះស្រដៀងនឹងប្រភពដែលអង្គជំនុំជម្រះបានដឹងរួចមកហើយ។ ប្រភពដែលសំអាងនៅក្នុងសៀវភៅនេះ គឺជាសក្ខីកម្មរបស់ ឌុច នៅក្នុងករណី០០១។ ពិតណាស់សក្ខីកម្មនោះ គឺស្ថិតនៅក្នុងភស្តុតាង យើងខ្ញុំនឹងពិភាក្សាតម្លៃដែលអាចបញ្ជាក់បានរបស់ភស្តុតាងនេះនៅពេលឆាប់ៗនេះ។ ប៉ុន្តែសេចក្ដីដកស្រង់ដែលសំអាងនៅក្នុងសៀវភៅរបស់ ថេត សម្បត្តិ មិនមានអ្វីប្លែកក្រៅតែពីការកែច្នៃឡើងវិញនៃសក្ខីកម្មនោះទេ។ ហេតុដូច្នេះវាពុំមានភាពពាក់ព័ន្ធរឿង ឬមានភាពច្បាស់លាស់ទាស់តែសោះ។

[១៥:២១:២០]

ដោយមិនអាចរកបានឯកសារភស្តុតាង ឬវត្ថុតាងនៃសេចក្ដី -- នៃតួនាទីរបស់លោក នួន ជា មន្ទីរស-២១ សហព្រះរាជអាជ្ញាបានព្យាយាមបង្ហាញដោយមិនផ្ទាល់តាមកាលៈទេសៈពីតួនាទីនេះ។

សហព្រះរាជអាជ្ញាលើកអំណះអំណាងថា សុន សេន ដែលធ្លាប់គ្រប់គ្រងលើមន្ទីរស-២១ ត្រូវបានបញ្ជូនទៅភូមិភាគបូព៌ានាខែសីហា ឆ្នាំ១៩៧៧ ដើម្បីដោះស្រាយជម្លោះប្រដាប់អាវុធជាមួយវៀត-ណាម។ សហព្រះរាជអាជ្ញាលើកឡើងថា ដោយសារតែ សុន សេន មិននៅទីក្រុងភ្នំពេញទើប សុន សេន មិនអាចបន្តត្រួតត្រាលើ ឌុច បានទេ។ តែសហព្រះរាជអាជ្ញាមិនបានលើកឡើងទេថា អតីតកងការពារជាច្រើននៅមន្ទីរស-២១,ដែលបានធ្វើការនៅមន្ទីរស-២១, ជារៀងរាល់ថ្ងៃបានប្រាប់សហចៅក្រមស៊ើបអង្កេតថា ពួកគេបានឃើញ សុន សេន មកមន្ទីរស-២១ ដោយផ្ទាល់ភ្នែករហូតដល់ថ្ងៃកងទ័ពវៀតណាមចូលទីក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩។

មិនមានសាក្សីណាម្នាក់ក្នុងចំណោមពួកគេបានផ្ដល់សក្ខីកម្មនៅក្នុងករណី០០២/០១ទេ ពីព្រោះមន្ទីរស-២១ គឺមិនមែនជាផ្នែកមួយនៃសវនាការនេះឡើយ។ នេះជាឧទាហរណ៍ល្អមួយជាហេតុដែលអង្គជំនុំជម្រះមិនបានរកឃើញថា ពួក -- សូមទោស លោក នួន ជា មានតួនាទីនៅមន្ទីរស-២១ ក្នុងសំណុំរឿង ០០២/០១។ វត្តមានរបស់ សុន សេន នៅមន្ទីរស-២១ នៅក្រោយខែសីហា ឆ្នាំ១៩៧៧ គឺជាសំណួរដ៏សំខាន់មួយទាក់ទងនឹងការទទួលខុសត្រូវរបស់លោក នួន ជា។ ការច្រានចោលភស្តុតាងនេះពីការជំនុំជម្រះនេះ គឺជាការដាក់កំហិតដោយខ្លួនឯង ដោយអង្គជំនុំជម្រះនេះ។ ដោយសម្រេចមិនស្ដាប់

ភស្តុតាងដោះបន្ទុកដ៏សំខាន់មួយនេះ ពេលនេះអង្គជំនុំជម្រះមិនអាចរកឃើញឲ្យហួសពីវិមតិសង្ស័យថា លោក នួន ជា ទទួលខុសត្រូវនៅមន្ទីរស-២១ ឡើយ។

[១៥:២៤:០៦]

ហើយខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះថា កាលពីលើកមុនយើងខ្ញុំបានលើកអំណះអំណាងថា អង្គហេតុជាក់លាក់ដែលថា តើ សុន សេន មានវត្តមាននៅមន្ទីរស-២១ ពេញឆ្នាំ១៩៧៨ គឺជាមូលហេតុមួយដែលអង្គជំនុំជម្រះនេះមិនអាចស្វែងរកអង្គហេតុទាក់ទងនឹងមន្ទីរស-២១ នៅក្នុងជំនុំជម្រះនេះ។ យើងខ្ញុំផ្តល់ទឡ្ហីករណ៍នៅក្នុងឯកសារ E284/4/4/1 ភស្តុតាងតែមួយគត់ដែលបង្ហាញថា លោក នួន ជា មានតួនាទីនៅមន្ទីរស-២១ គឺការអះអាងមិនស៊ីសង្វាក់គ្នារបស់ ឌុច ថាគាត់បានរាយការណ៍ទៅលោក នួន ជា។

មានមូលហេតុជាច្រើនថា ហេតុអ្វីបានជាសក្ខីកម្មនេះមិនអាចជឿបាន? និងមិនអាចទទួលយកដោយអង្គជំនុំជម្រះនេះ? ជាបឋម ដូចដែលខ្ញុំទើបបានបង្ហាញជូនថា សក្ខីកម្មនេះមិនស៊ីសង្វាក់គ្នាទៅនឹងគ្រប់ភស្តុតាងជាឯកសារ។ វាមិនស៊ីសង្វាក់ជាមួយនឹងភស្តុតាងដែលថាលោក នួន ជា ទទួលបានត្រឹមតែចម្លើយសារភាពនៅមន្ទីរស-២១តិចតួច។ វាមិនស៊ីសង្វាក់ជាមួយភស្តុតាងដែលថានីរសាររបស់លោក នួន ជា, ដែល ឌុច និយាយថាជាអ្នកទទួលខុសត្រូវបញ្ជូនចម្លើយសារភាពនៅមន្ទីរស-២១ មកលោក នួន ជា, បានអះអាងថាខ្លួនបានបញ្ជូនចម្លើយសារភាពនៅមន្ទីរស-២១ មកលោក នួន ជា តិចតួចណាស់។ វាមិនស៊ីសង្វាក់ជាមួយភស្តុតាងដែលថាលោក នួន ជា មិនបានធ្វើចំណារនៅលើចម្លើយសារភាពនៅមន្ទីរស-២១។ អង្គហេតុទាំងនេះត្រូវបានយល់ស្របដោយសហព្រះរាជអាជ្ញា លើកលែងតែឯកសារប្រាំមួយប៉ុណ្ណោះ វាមិនស៊ីសង្វាក់ជាមួយសក្ខីកម្មរបស់អ្នកយាមនៅមន្ទីរស-២១ ដែលចង្អុលបង្ហាញថា សុន សេន ជាមេរបស់ ឌុច ស្ថិតនៅមន្ទីរស-២១ យ៉ាងទៀងទាត់នៅពេញរបបកម្ពុជាប្រជាធិបតេយ្យតាំងពីដើមរហូតដល់ចប់។

[១៥:២៦:៤០]

ទី២ ឌុច ជានិច្ចកាលធ្វើការអះអាងដ៏ចម្លែកអំពីមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូចដែលយើងបានពិពណ៌នានៅកថាខណ្ឌ១២០ នៃសារណារបស់យើង។ ឌុច ជាញឹកញាប់និយាយហាក់ដូចជាគាត់ដឹងដោយផ្ទាល់នៃការទទួលខុសត្រូវរបស់មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលតាមពិត ឌុច មិនមានព័ត៌មានបែបនេះទេ។

ការលើកឡើងបែបនេះ គឺពិតជាទាក់ទងនឹងការអះអាងរបស់ ឌុច អំពីតួនាទីរបស់លោក នួន ជា នៅមន្ទីរស-២១។ ដូចដែលសហព្រះរាជអាជ្ញាបានកត់សម្គាល់ ឌុច ផ្តល់សក្ខីកម្មដដែលៗថា គាត់អាចកំណត់អត្តសញ្ញាណសរសេរដៃរបស់លោក នួន ជា នៅលើចម្លើយសារភាព និងឯកសារដដែលដទៃទៀត។ តែដូចដែលយើងខ្ញុំបានបង្ហាញរួចហើយ នៅពេលចោទសួរពីបដិភាគ -- បដិភាគី ឌុច យល់ស្រប ដោយអឹមអៀនថា គាត់បានឃើញចំណារនៅលើចម្លើយសារភាពក្នុងមន្ទីរស-២១ របស់មេដឹកនាំជាន់ខ្ពស់ជាលើកដំបូងនៅខែមេសា ឆ្នាំ១៩៨៩។

ទី៣ ឌុច តែងតែមានបំណង និងបន្ត មានបំណងដាកចេញពីការទទួលខុសត្រូវរបស់ខ្លួននៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ សញ្ញាណដែលថា ឌុច បានរាយការណ៍មកលោក នួន ជា និងតម្រូវឲ្យបង្ហាញខ្លួនទៀងទាត់នៅការិយាល័យរបស់លោក នួន ជា គឺពិតជាបំពេញនូវបំណងរបស់ ឌុច ក្នុងការអះអាងថាគាត់គ្រាន់តែធ្វើតាមបញ្ជា។

[១៥:២៨:៤៥]

វាសំខាន់ណាស់ ដើម្បីទទួលស្គាល់ថា ប្រសិនបើ ឌុច មិនរាយការណ៍មកលោក នួន ជា បន្ទាប់ពី សុន សេន ចេញទៅដឹកនាំប្រតិបត្តិការយោធានៅភូមិភាគបូព៌ាទេនោះ មានន័យថា ឌុច អាចធ្វើសេចក្តីសម្រេចពាក់កណ្តាលឯករាជ្យ–*"ស៊ីមី អាំងដេប៉ង់ដង់"* ជាមួយការគ្រប់គ្រងពីថ្នាក់លើតិចតួច។

តាមទស្សនៈរបស់ ឌុច ការទទួលខុសត្រូវអាចធ្លាក់មកលើលោក នួន ជា ឬខ្លួនគាត់។ យើងមិនភ្ញាក់ផ្អើលដើម្បីរកឃើញថា ឌុច ចាប់យក នួន ជា សម្រាប់ឆ្លើយដាក់នោះទេ។ នៅក្នុងករណី០០១ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា សក្ខីកម្មរបស់ ឌុច មិនអាចជឿជាក់បាន ដោយសារ ឌុច មាននិន្នាការទម្លាក់កំហុសមកលើអ្នកដទៃ ជាជាងទទួលយកការទទួលខុសត្រូវរបស់ខ្លួន។

[១៥:២៩:៤៩]

នៅក្នុងសាលដីកាករណី០០១ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញដូចខាងក្រោម ខ្ញុំសូមដកស្រង់៖ "កាំង ហ្កេកអ៊ាវ ហៅ ឌុច ខកខានមិនផ្តល់រូបភាពពេញលេញនៃការដឹងរបស់គាត់នៃករណីនេះ ដើម្បីសម្រាលតួនាទីរបស់គាត់នៅក្នុងឧក្រិដ្ឋកម្ម។ គាត់គេចវេះយ៉ាងប្រុងប្រយ័ត្នពីការឆ្លើយតបពេញលេញនៅពេលប្រឈមជាមួយការចោទប្រកាន់ទាក់ទងនឹងការជាប់ពាក់ព័ន្ធរបស់គាត់ដោយព្យាយាមទម្លាក់ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទៅលើអ្នកដទៃ និងបានកែប្រែសេចក្តីថ្លែងការណ៍ដែលមិនស៊ីសង្វាក់នឹងភស្តុតាងដែលមាន" បិទការដកស្រង់។

ទី៤ ថ្វីបើមានបញ្ហាជាក់ស្តែងនៃភាពជឿជាក់បានរបស់ ឌុច ក៏ក្នុងអំឡុងពេលសួរដេញដោល អង្គជំនុំជម្រះនេះបានហាមឃាត់មិនឲ្យមេធាវីការពារក្តីលោក នួន ជា ចោទសំណួរទៅលើសាក្សីពីការពាក់ព័ន្ធផ្ទាល់ចំពោះភាពជឿជាក់បានរបស់ ឌុច ដែរ។

[១៥:៣១:១០]

ដូចដែលបានពន្យល់លម្អិតនៅក្នុងសារណារបស់យើងហើយ យើងខ្ញុំនឹងនិយាយបន្ថែមនៅថ្ងៃនេះ អង្គជំនុំជម្រះនេះបានធ្វើសេចក្តីសម្រេចដែលមិនសមហេតុផល និងគ្មានមូលហេតុជាបន្តបន្ទាប់ក្នុងអំឡុងពេលការចោទប្រកាន់សួរលើបដិសាក្សី។ ការសម្រេចទាំងនេះបានរារាំងមេធាវីការពារក្តីមិនឲ្យបង្ហាញនូវ ឌុច នូវឯកសារដែលអាចទទួលយកបាន ហើយដែលផ្ទុយពីសក្ខីកម្មរបស់ ឌុច។ អង្គជំនុំជម្រះមិនបានផ្តល់ការសំអាងហេតុចំពោះការសម្រេចទាំងនេះទេ និងមិនបានរារាំងជាប់ជានិច្ចដល់មេធាវីការពារក្តីរួមទាំងបិទមីក្រូហ្វូនរបស់ពួកយើងថែមទៀត នៅពេលពួកយើងព្យាយាមដាក់សំណួរដែលពាក់ព័ន្ធនិងអាចទទួលយកបាន។

ដូចដែលបង្ហាញនៅក្នុងសារណារបស់យើង ក្រោយមកអង្គជំនុំជម្រះបានធ្វើមោឃភាពសេចក្តីសម្រេចទាំងនោះដោយគ្មានសំអាងហេតុ ហើយបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់សំណួរមក ឌុច តែមិនអាចអនុញ្ញាតឲ្យមេធាវីការពារក្តី នួន ជា ទៅវិញ។

[១៥:៣២:៤០]

<u>អំពីការគ្រប់គ្រងលើភូមិភាគ និងតំបន់ស្វយ័ត</u>

លោកប្រធាន! ឥឡូវនេះខ្ញុំនឹងឆ្លើយតបទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញាដែលថាលោក នួន ជា-- ខ្ញុំសូមដកស្រង់៖ “ទទួលខុសត្រូវតាមដាន និងដឹកនាំការអនុវត្តមាគ៌ា គោលនយោបាយរបស់បក្សដល់ភូមិភាគ ភាគតំបន់ និងអង្គការរបស់បក្សទាំងអស់” បិទការដកស្រង់។ លោក នួន ជា មិនជំទាស់ការអះអាងនេះទេ ហើយតាមពិតលោក នួន ជា យល់ស្របថាគោលនយោបាយរបស់គណៈអចិន្ត្រៃយ៍ត្រូវបានអនុវត្តដោយមន្ត្រីថ្នាក់ភូមិភាគ។ លោក នួន ជា ក៏បានយល់ស្របដែរថា គណៈអចិន្ត្រៃយ៍តាមដានការសម្រេចបានគោលដៅខ្ពស់បំផុត។ តែវាមិនត្រឹមត្រូវទេ ដែលថាលោក នួន ជា -- ខ្ញុំសូមដកស្រង់៖ “ដឹកនាំការអនុវត្តគោលនយោបាយទាំងនេះ សមត្ថភាពរបស់លោក នួន ជា ដើម្បីតាមដានការអនុវត្តនៅថ្នាក់ភូមិភាគ មានកម្រិត និងអាស្រ័យលើកិច្ចសហការពីមន្ត្រីភូមិភាគ”។

សហព្រះរាជអាជ្ញាចោទប្រកាន់លោកនួន ជា ថា បានគ្រប់គ្រងលើភូមិភាគតាមវិធីបីយ៉ាងគឺ៖

ទី១) តាមរយៈកិច្ចប្រជុំនៅភ្នំពេញជាមួយមេដឹកនាំភូមិភាគ និងតំបន់, ទី២) តាមរយៈការទទួលសារទូរលេខ និងរបាយការណ៍, ទី៣) ធ្វើទស្សនកិច្ចតាមបណ្ដាខេត្ត។ ការកំណត់តួនាទីរបស់លោក នួន ជា របស់សហព្រះរាជអាជ្ញានាពេលនេះ គឺមានលក្ខណៈមិនពេញលេញនិងភន្តច្រឡំ។ សហព្រះរាជអាជ្ញាមិនបានបង្ហាញភស្តុតាងគ្រប់គ្រាន់ ដើម្បីរកឲ្យឃើញលើសពីវិមតិសង្ស័យនូវតួនាទីរបស់លោក នួន ជា ជាអ្នកគ្រប់គ្រងលើភូមិភាគ និងតំបន់ស្វយ័តនេះទេ គឺកិច្ចប្រជុំ។

[១៥:៣៥:០៨]

ជាបឋម ខ្ញុំនឹងឆ្លើយតបទៅនឹងការអះអាងដែលថាលោក នួន ជា បានជួបយ៉ាងទៀតទាត់ជាមួយមន្ត្រីថ្នាក់ភូមិភាគ និងតំបន់។ ដូចដែលសហព្រះរាជអាជ្ញាកត់សម្គាល់ លោក នួន ជា បានជួបប្រជុំជាមួយមេដឹកនាំភូមិភាគ ជាពិសេស តាម៉ុក, សោ ភឹម, រស់ ញឹម និង កែ ពក។ លោក នួន ជា មិនចាំបាច់ទេថា កិច្ចប្រជុំបែបនេះកើតឡើងញឹកញាប់ប៉ុន្មាន។ តែលោក នួន ជា និយាយស្មានថា កិច្ចប្រជុំបែបនេះមានច្រើនដងក្នុងឆ្នាំនីមួយៗ។ លោក នួន ជា រំឭកអង្គជំនុំជម្រះនេះថាបុរសទាំងបួននាក់នេះជាសមាជិកគណៈអចិន្ត្រៃយ៍។ ដោយសារពួកគេជាសមាជិកគណៈអចិន្ត្រៃយ៍ ទើបពួកគេធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីចូលរួមកិច្ចប្រជុំជាមួយសមាជិកដទៃទៀតនៃគណៈអចិន្ត្រៃយ៍ រួមទាំងលោក នួន ជា ផងដែរ។ តែពួកគេមិនធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីរាយការណ៍ ឬទទួលសេចក្ដីណែនាំពីលោក នួន ជា ទេ ពួកគេមកភ្នំពេញដើម្បីពិភាក្សាបញ្ហាសំខាន់ៗទាក់ទងនឹងភូមិភាគរបស់ពួកគេ និងបញ្ហាប្រទេសជាតិក្នុងខណៈពួកគេជាសមាជិកនៃអង្គការដឹកនាំដ៏ខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៥:៣៦:៤៣]

លោក នួន ជា បានរំឭកអង្គជំនុំជម្រះថា សហព្រះរាជអាជ្ញាបន្តអះអាងថាបក្សកុម្មុយនីស្តកម្ពុជាដឹកនាំតាមរយៈ-- ខ្ញុំសូមដកស្រង់៖ “ការសម្រេចជាសមូហភាព” បិទការដកស្រង់។ អនុលោមសហព្រះរាជអាជ្ញាការសម្រេចជាសមូហភាព មានន័យថា ប៉ុល ពត មិនចេញបទបញ្ជាមកលោក នួន ជា។ ប៉ុន្តែពិភាក្សាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា រហូតទាល់តែមានកិច្ចព្រមព្រៀង។ វាពិតជាអ៊ីចឹងមែនបើនិយាយពីទំនាក់ទំនងរបស់ ប៉ុល ពត ជាមួយមេដឹកនាំភូមិភាគដ៏មានអំណាច។ មេដឹកនាំភូមិភាគមានមូលដ្ឋានអំណាចនៅក្នុងតំបន់នីមួយៗរបស់ពួកគេ និងគ្រប់គ្រងលើកងទ័ពទៀតផង។ គណៈអចិន្ត្រៃយ៍មិនអាច និងមិនចេញបញ្ជាទៅមេដឹកនាំភូមិភាគនោះទេ។ ពួកគេយល់ព្រមលើមាគ៌ានយោបាយទូលំទូលាយដែលត្រូវអនុវត្តតាមនឹកឃើញរបស់មេភូមិភាគ។ នេះគឺជាលក្ខណៈធម្មជាតិនៃកិច្ចប្រជុំ

រវាងមេដឹកនាំភូមិភាគ ជាពិសេស តាម៉ុក, សោ ភឹម និង រស់ ញឹម និងសមាជិកដទៃទៀតរបស់គណៈអចិន្ត្រៃយ៍ ដែលមានមូលដ្ឋាននៅភ្នំពេញ។

លោក នួន ជា ម្តងម្កាលជួបលេខានៃតំបន់ស្វយ័ត។ លេខានៃតំបន់ស្វយ័តមិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ និងមានអំណាចតិចតួចជាងលេខភូមិភាគ។ ពួកគេមិនសូវធ្វើដំណើរមកទីក្រុងភ្នំពេញទេ។ ពួកគេមកទីក្រុងភ្នំពេញតែនៅពេលចូលរួមពិភាក្សាបញ្ហាជាក់លាក់តែប៉ុណ្ណោះ។ លោក នួន ជា មិនជួបមន្ត្រីដទៃទៀតទេ រួមទាំងកម្មាភិបាលនៅក្រៅតំបន់ស្វយ័ត និងកម្មាភិបាលថ្នាក់ស្រុក។ តែកម្មា-ភិបាលទាំងនោះមកភ្នំពេញតែនៅពេលត្រូវចូលរួមកិច្ចប្រជុំនយោបាយធំៗប៉ុណ្ណោះ។ លោក នួន ជា មិនអាចចាំបាននូវកិច្ចប្រជុំនយោបាយធំៗ សូម្បីតែមួយក៏មិនចាំដែរ។ ប្រសិនបើមានកិច្ចប្រជុំមែននោះក៏វាកើតឡើងដោយកម្រ និងក្នុងករណីលើកលែងប៉ុណ្ណោះ។ ក្នុងភស្តុតាងគាំទ្រយ៉ាងរឹងមាំដល់ការលើកឡើងរបស់លោក នួន ជា។ ភស្តុតាងដែលសំអាងដោយសហព្រះរាជអាជ្ញាដែលខ្ញុំនឹងពិភាក្សាលម្អិតឆាប់ៗនេះបង្ហាញថា លោក នួន ជា បានជួបតែលេខាភូមិភាគ និងតំបន់ស្វយ័តប៉ុណ្ណោះ។

[១៥:៣៩:៤១]

កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ជាភស្តុតាងបង្ហាញថា កម្មាភិបាលបីរូបមកពីរចនាសម្ព័ន្ធរដ្ឋបាលជាតិបានចូលរួមកិច្ចប្រជុំណាមួយនៃកិច្ចប្រជុំ១៩លើករបស់គណៈអចិន្ត្រៃយ៍។ មានតែសាក្សីតែម្នាក់គត់ពីរចនាសម្ព័ន្ធរដ្ឋបាលជាតិ បានផ្តល់សក្ខីកម្មថា គាត់បានចូលរួមរាល់កិច្ចប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់នៅភ្នំពេញ។ ដូចដែលសហព្រះរាជអាជ្ញាកត់សម្គាល់ សាក្សីនោះឈ្មោះ សៅ សារុន ជាលេខាតំបន់ស្វយ័ត១០៥រយៈពេលជាងមួយឆ្នាំ។ ក្នុងអំឡុងពេលនោះ សៅ សារុន បានចូលរួមកិច្ចប្រជុំបីលើកតែប៉ុណ្ណោះ។ កិច្ចប្រជុំនីមួយៗមានគោលបំណងជាក់លាក់។ កិច្ចប្រជុំលើកដំបូងដែលគាត់ចូលរួមគឺបន្ទាប់ពីការស្លាប់របស់ ឡាំង។ កិច្ចប្រជុំលើកទី២ គឺការតែងតាំងគាត់ជាផ្លូវការជាលេខាតំបន់១០៥។ ក្នុងអំឡុងពេលជាងមួយឆ្នាំ លោក សៅ សារុន ធ្វើដំណើរមកទីក្រុងភ្នំពេញតែមួយលើកគត់សម្រាប់គោលបំណងពិភាក្សាផែនការអភិវឌ្ឍន៍នៅតំបន់របស់គាត់។ ហេតុដូច្នេះ ភស្តុតាងរបស់លោក សៅ សារុន បង្ហាញឲ្យឃើញថា លេខាតំបន់មិនចូលរួមកិច្ចប្រជុំទៀងទាត់នោះទេ ឬមិនធ្វើដំណើរមកទីក្រុងភ្នំពេញញឹកញាប់ដែរ។

សាក្សីបីនាក់ដែលសំអាងដោយសហព្រះរាជអាជ្ញា រៀបរាប់ពីការឃាមនៅមន្ទីរ ក-១ និងក-៣ ក្នុងពេលប្រជុំរវាងមន្ត្រីថ្នាក់ភូមិភាគ និងមេដឹកនាំជាន់ខ្ពស់នៅភ្នំពេញ សាក្សីទាំងបីនាក់នេះផ្តល់សក្ខីកម្ម

ថាពួកគេមិនស្គាល់មន្ត្រីថ្នាក់ភូមិភាគដែលពួកគេបានឃើញនៅកិច្ចប្រជុំនៅមន្ទីរក-១ និង ក-៣ នោះទេ ហេតុដូច្នេះពួកគេមិនអាចផ្តល់ភស្តុតាងអំពីអត្តសញ្ញាណរបស់មន្ត្រីភូមិភាគដែរ។

[១៥:៤១:៥៩]

អង្គជំនុំជម្រះអាចរកឃើញសក្ខីកម្មរបស់សាក្សីឈ្មោះ ស វិ នៅក្នុងប្រតិចារឹកសវនាការ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៣ នៅទំព័រ២៣ ដល់ ២៥។ ហើយអង្គជំនុំជម្រះក៏អាចរកឃើញសក្ខីកម្ម របស់សាក្សីទី២ ឈ្មោះ សូត្រ ទឿង នៅក្នុងប្រតិចារឹកសវនាការថ្ងៃ១៨ ខែមេសា ឆ្នាំ២០១២ នៅទំព័រ៥៣ ដល់ ៥៤។ សាក្សីទី៣ ឈ្មោះ អឿន តាន បានផ្តល់សក្ខីកម្មថា “មនុស្សមួយក្រុមតូចដដែលបានចូលរួមកិច្ចប្រជុំទាំងនេះ”។ អង្គជំនុំជម្រះអាចរកឃើញសក្ខីកម្មនោះនៅក្នុងប្រតិចារឹកថ្ងៃសវនាការទី១៣ ខែមិថុនា ឆ្នាំ២០១២ នៅទំព័រ៥៣។ សក្ខីកម្មនោះបង្ហាញថាលោក នួន ជា មិនបានជួបប្រជុំជាមួយកម្មាភិបាលថ្នាក់ខុសគ្នានៃឋានានុក្រមរបស់បក្សកុម្មុយនីស្តឡើយ។ ផ្ទុយទៅវិញ គាត់ជួបប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់នៃភូមិភាគ និងតំបន់ស្វយ័តនីមួយៗដែលពួកគេភាគច្រើនបំផុត គឺជាសមាជិកគណៈអចិន្ត្រៃយ៍ដែរនោះតែប៉ុណ្ណោះ។ ភស្តុតាងដដែល ភស្តុតាងដទៃទៀតដែលសំអាងដោយសហព្រះរាជអាជ្ញាគឺស្របគ្នាជាមួយនឹងសេចក្តីសន្និដ្ឋានទាំងនេះ។ សហព្រះរាជអាជ្ញាប្រមូលភស្តុតាងនេះនៅក្នុងនៅជើងអក្សរលេខ១៨៤៦ នៃសារណារបស់សហព្រះរាជអាជ្ញា។ សាក្សី ពាន ឃាន បានចង្អុលបង្ហាញថា កិច្ចប្រជុំរបស់គណៈកម្មាធិការភូមិភាគធ្វើឡើងជាប្រចាំឆ្នាំនៅមន្ទីរក-៣។ លោក នួន ជា ជឿថា លោក ពាន ឃាន ភ័ន្តច្រឡំតែគាត់មិនបានបដិសេធថា មិនបានជួបប្រជុំជាមួយមេដឹកនាំភូមិភាគទេ អាស្រ័យហេតុនេះការមិនយល់ស្របនេះគឺមិនសំខាន់ឡើយ។

[១៥:៤៤:១៥]

សាក្សី ខាំ ផាន់, សាក្សីដែលមានលេខTCW-596 និងឯកសារលេខE3/366 ដែលអ្នកទាំងអស់នោះបានផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា លេខាតំបន់ស្វយ័ត១០៥បានធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីចូលរួមប្រជុំ។ សក្ខីកម្មនោះគឺស្របគ្នាជាមួយនឹងការអះអាងរបស់លោក នួន ជា ដែលថា គាត់ជួបប្រជុំតែជាមួយមេដឹកនាំភូមិភាគ និងលេខាតំបន់ស្វយ័តតែប៉ុណ្ណោះ។ ការថ្លែងរបស់លោក ភី ភួន ទាក់ទងនឹងកិច្ចប្រជុំជាមួយលេខាភូមិភាគ និងតំបន់ស្វយ័តនៅខែឧសភា ឆ្នាំ១៩៧៥ នង សុផង់ បានផ្តល់សក្ខីកម្មថា មេដឹកនាំភូមិភាគបានចូលរួមប្រជុំនៅទីក្រុងភ្នំពេញ។ លោក នង សុផង់ ដែលជាអ្នកបកសារទូរលេខមិនបានពន្យល់របៀបដែលគាត់ដឹងពីទម្លាប់របស់មេដឹកនាំភូមិភាគឡើយ។

អាស្រ័យហេតុនេះ សក្ខីកម្មរបស់គាត់ គឺស្របគ្នាជាមួយនឹងការអះអាងរបស់លោក នួន ជា ដែលថា លោក នួន ជា បានជួបប្រជុំជាមួយតែលេខាភូមិភាគ និងតំបន់ស្វយ័តប៉ុណ្ណោះ។

សាក្សីបង្ហាញក្នុងឯកសារលេខ E3/464 បានរៀបរាប់វគ្គអប់រំនយោបាយជាមួយកម្មាភិបាលរាប់រយនាក់នៅស្តាតអូរឡាំពិក និងបុរីកីឡា។ លោក នួន ជា ត្រៀមខ្លួនជាស្រេចក្នុងការយល់ស្របថា គាត់ធ្វើបទឧទ្ទេសនាមនៅវគ្គអប់រំនយោបាយធំៗទាំងនេះ។ សាក្សី ប្រាក់ យុត បានបង្ហាញ បានបញ្ជាក់ថា កម្មាភិបាលថ្នាក់ស្រុកនៅភូមិភាគនិរតីមិនបានចូលកិច្ចប្រជុំអ្វីទាំងអស់នៅទីក្រុងភ្នំពេញ។

[១៥:៤៦:២៤]

<u>អំពីសារទូរលេខ និងរបាយការណ៍</u>

ចំណុចទី២ សហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា បានគ្រប់គ្រងសកម្មភាពនៅតំបន់ និងរចនាសម្ព័ន្ធរដ្ឋបាល តាមរយៈសារទូរលេខ និងរបាយការណ៍ដែលគាត់បានទទួល។ ប៉ុន្តែសារទូរលេខ និងរបាយការណ៍ដែលគាត់បានទទួលនោះ មិនមែនសុទ្ធតែមានតម្លៃជាភស្តុតាងហេតុដែលអាចបង្ហាញពីការគ្រប់គ្រងរបស់គាត់ឡើយ។ វាជាការត្រឹមត្រូវដែលសហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា បានទទួលសារទូរលេខ និងរបាយការណ៍ពីភូមិភាគ និងតំបន់ស្វយ័ត។ នេះមានន័យថា លោក នួន ជា មិនបានប្រាស្រ័យទាក់ទងដោយផ្ទាល់ពីភ្នំពេញជាមួយកម្មាភិបាលនៅក្រោមថ្នាក់ដឹកនាំភូមិភាគ និងតំបន់ស្វយ័តនីមួយៗឡើយ។ មានន័យថា នួន ជា ត្រូវបានគេប្រាប់នូវអ្វីដែលថ្នាក់ដឹងនាំភូមិភាគបានដឹង ហើយដែលពួកគេចង់ប្រាប់លោក នួន ជា តែប៉ុណ្ណោះ។ តាមពិតព័ត៌មានដែលបញ្ជូនមកលោក នួន ជា ដោយថ្នាក់ដឹកនាំនៅភូមិភាគនិងតំបន់ស្វយ័ត គឺមានលក្ខណៈត្រឹមត្រូវជាប្រព័ន្ធទេ គឺមិនមានលក្ខណៈត្រឹមត្រូវជាប្រព័ន្ធទេ(សូមទោស)។ ដូចដែលយើងខ្ញុំបង្ហាញនៅកថាខណ្ឌ២០៣ នៃសារណារបស់យើង កម្មាភិបាលបាននិយាយបំផ្លើសពីទិន្នផល និងម៉ោងធ្វើការ ព្រមទាំងការសម្លាប់ប្រជាជន។ សហព្រះរាជអាជ្ញាគ្រាន់តែបង្ហាញថា របាយការណ៍ត្រូវបានបញ្ជូនជាទៀងទាត់មកមេដឹកនាំថ្នាក់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា តែសហព្រះរាជអាជ្ញាមិនអាចបង្ហាញថារបាយការណ៍ទាំងនេះជារបាយការណ៍ត្រឹមត្រូវនោះទេ ហើយពិត ហើយតាមពិតរបាយការណ៍ទាំងនេះ គឺមិនត្រឹមត្រូវទាល់តែសោះ។

[១៥:៤៨:៤១]

ម្យ៉ាងទៀត លោក នួន ជា ស្ទើរតែមិនដឹងឆ្លើយតបទៅនឹងសារទូរលេខទាំងនោះឡើយ។ លោក នួន ជា មិនដែលគ្រប់គ្រងលើមូលដ្ឋានណាមួយទេ ពីព្រោះលោក នួន ជា មិនដែលផ្តល់ការណែនាំអំពី

របៀបដែលគេត្រូវអនុវត្តមាគ៌ានយោបាយរបស់បក្ស។ សហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា បានឆ្លើយតបទៅនឹងសារទូរលេខនេះ និងចេញការណែនាំដល់ថ្នាក់ដឹកនាំភូមិភាគ គឺពិតជាត្រឹមត្រូវ។ ភស្តុតាងតែមួយគត់ដែលគាំទ្រដល់ការនេះ គឺសក្ខីកម្មរបស់សាក្សី នង សុផង់ អ្នកបកប្រែសារទូរលេខ។ តាមពិត នង សុផង់ បានផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះនេះថា គាត់កម្រនឹងបញ្ជូនចេញសារទូរលេខចេញពី នួន ជា ណាស់។ គាត់បានផ្តល់សក្ខីកម្មបន្ថែមថា ការបញ្ជូនចេញសារទូរលេខពីមជ្ឈិមមិនសូវញឹកញាប់ទេ ហើយបើមានការបញ្ជូន គឺបញ្ជូនចេញតែពីសារទូរលេខពាក់ព័ន្ធនឹងសំណើបញ្ជូនស្បៀងពីកម្មាភិបាលថ្នាក់ភូមិភាគប៉ុណ្ណោះ។ ខ្ញុំសូមស្នើ សូមអង្គជំនុំជម្រះពិនិត្យមើលសារណារបស់យើង នៅក្នុងកថាខណ្ឌលេខ២០៤ ទាក់ទងនឹងករណីនេះ អង្គជំនុំជម្រះអាចរកឃើញសក្ខីកម្មស្រដៀងនេះ ប្រសិនបើអង្គជំនុំជម្រះផ្ទៀងផ្ទាត់សក្ខីកម្មរបស់ នង សុផង់ ដែលផ្តល់ដោយជើងអក្សរលេខ១៨៦៣ នៃសារណារបស់សហព្រះរាជអាជ្ញា។

អំពីដំណើរធ្វើទស្សនកិច្ចតាមខេត្ត

សហព្រះរាជអាជ្ញាអះអាងថា លោក នួន ជា បានគ្រប់គ្រងលើភូមិភាគតាមរយៈដំណើរធ្វើទស្សនកិច្ចទៅតាមបណ្តាខេត្តនានា។ យើងកត់សម្គាល់ថា ភស្តុតាងស្ទើរតែទាំងអស់ដោយសហព្រះរាជអាជ្ញាមិនបានបង្ហាញអ្វីទាំងអស់អំពីអ្វីដែល មួយដែលហៅថាលោក នួន ជា បានគ្រប់គ្រងលើភូមិភាគ។ វាគ្រាន់តែបង្ហាញថា លោក នួន ជា បានជួបប្រជុំជាមួយលេខាភូមិភាគ និងតំបន់ស្វយ័ត ដែលស្របជាមួយការអះអាងរបស់លោក នង សុផង់ ផ្ទាល់តែប៉ុណ្ណោះ។

[១៥:៥១:១៧]

ភស្តុតាងទាំងនេះហាក់ដូចជាបានបង្ហាញថា លោក នួន ជា នឹងដឹងថាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាធ្វើឲ្យប្រជាជននៅមូលដ្ឋានជួបការលំបាក។ លោក នួន ជា បានជំទាស់យ៉ាងខ្លាំងចំពោះការចោទប្រកាន់នេះ។ ឥឡូវនេះខ្ញុំនឹងសង្កត់ធ្ងន់ថា អង្គហេតុនេះគឺមិនពាក់ព័ន្ធ បើទោះជាវាអាចជាការពិតថា លោក នួន ជា បានមើលឃើញពីការលំបាកវេទនានៅតាមមូលដ្ឋាន តែវាមិនអាចនិយាយបានថាលោក នួន ជា មានសមត្ថភាពគ្រប់គ្រងទៅលើកម្មាភិបាលនៅភូមិភាគនោះទេ។

សហព្រះរាជអាជ្ញាបានរៀបរាប់នៅកថាខណ្ឌ៤៧៩ ដល់កថាខណ្ឌ៤៨២ អំពីវគ្គអប់រំនយោបាយនៅមូលដ្ឋានផ្សេងៗ ដែលធ្វើឡើងដោយលោក នួន ជា។ តែជាថ្មីម្តងទៀត ការអះអាងនេះស្របជាមួយភស្តុតាងដែលថាលោក នួន ជា ជួបតែមួយលេខាភូមិភាគ និងតំបន់ស្វយ័ត។ គាត់ប្រាស្រ័យ

ទាក់ទងជាមួយកម្មាភិបាលដទៃទៀតនៅវគ្គអប់រំនយោបាយធំៗ ដែលធ្វើបទឧទ្ទេសនាមជាទូទៅអំពីមាគ៌ានយោបាយរបស់បក្ស។

[១៥:៥២:៤១]

សហព្រះរាជអាជ្ញាព្យាយាមធ្វើឲ្យការអប់រំក្នុងវគ្គនយោបាយ ដែលធ្វើឡើងដោយលោក នួន ជា ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរបស់លោក នួន ជា នៅមូលដ្ឋាន តាមរយៈការលើកឧទាហរណ៍ជាក់លាក់ពីករណីទាក់ទងនឹងការចាប់ខ្លួនជាបន្តបន្ទាប់ នៅក្រោយការធ្វើសុន្ទរកថាដោយសមាជិកម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា។ ព្រឹត្តិការណ៍ទាំងពីរនេះមាននៅក្នុងសុន្ទរកថាមួយនៅតំបន់១០៣ ក្នុងខេត្តព្រះវិហារ និងមួយនៅភូមិភាគពាយ័ព្យ។ យើងដឹងមិនប្រាកដថា តើការអះអាងនេះវាពាក់ព័ន្ធគ្នាយ៉ាងដូចម្តេចទេ? យើងសន្មតថា សហព្រះរាជអាជ្ញាកំពុងជំរុញឲ្យអង្គជំនុំជម្រះសន្និដ្ឋានថា មានទំនាក់ទំនងនឹងគ្នារវាងសុន្ទរកថានេះ និងការចាប់ខ្លួនមនុស្សនៅក្រោយសុន្ទរកថានេះ។ ជាការចាប់ផ្តើមសុន្ទរកថាមួយដែលបង្ហាញដោយសហព្រះរាជអាជ្ញា គឺសុន្ទរកថាមិនមែនជារបស់លោក នួន ជា ឡើយ។ សុន្ទរកថានេះគឺជាភស្តុតាងមួយក្នុងចំណោមភស្តុតាងដទៃទៀត ដែលបង្ហាញដោយសហព្រះរាជអាជ្ញា ដើម្បីបង្ហាញថា លោក នួន ជា បានគ្រប់គ្រងលើកម្មាភិបាលនៅតាមមូលដ្ឋាន។ ហើយភស្តុតាងនោះជារបស់អ្នកផ្សេងដែលមិនមែនជារបស់លោក នួន ជា។ ហើយក៏គ្មានភស្តុតាងដែលភ្ជាប់រវាងសុន្ទរកថានេះ និងការចាប់ខ្លួននៅក្រោយសុន្ទរកថានេះដែរ។

[១៥:៥៤:២២]

សហព្រះរាជអាជ្ញាក៏បានអះអាងថា លោក នួន ជា ធ្វើបទឧទ្ទេសនាម ឧទ្ទិស -- លោក នួន ជា ធ្វើបទឧទ្ទេសបានអប់រំនយោបាយនៅតាមមូលដ្ឋាន។ តែសហព្រះរាជអាជ្ញាមិនផ្តល់ឧទាហរណ៍សូម្បីតែមួយនៃការចាប់ខ្លួន នៅក្រោយការធ្វើបទឧទ្ទេសនាមរបស់លោក នួន ជា។ សហព្រះរាជអាជ្ញាព្យាយាមភ្ជាប់លោក នួន ជា ទៅនឹងការចាប់ខ្លួនៅព្រះវិហារ និងភូមិភាគពាយ័ព្យ ដោយបានអះអាងថា "លោកនួន ជា បានធ្វើចំណារលើចម្លើយសារភាពរបស់កម្មាភិបាលដែលត្រូវបានចាប់ខ្លួននៅពេលបោសសម្អាតនោះ"។

យើងបានពិភាក្សារួចមកហើយអំពីចម្លើយសារភាព។ យើងបង្ហាញអង្គជំនុំជម្រះថាពុំមានមូលដ្ឋានអ្វីទាំងអស់ដែលអាចសន្និដ្ឋានថាលោក នួន ជា បានធ្វើចំណារលើចម្លើយសារភាព។ ដូច្នេះភស្តុតាងនេះត្រូវក្រុមសហមេធាវីការពារលោក នួន ជា សុំធ្វើការបដិសេធទាំងស្រុង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ឥឡូវនេះដល់ពេលវេលាសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃព្រហស្បតិ៍ ទី២៤ ខែតុលា ឆ្នាំ ២០១៣ ដែលចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគី ហើយនិងសាធារណជនបានជ្រាបផងដែរថា នៅសវនាការនៅថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីបន្តធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នូវកិច្ចពិភាក្សាដេញដោលរបស់ខ្លួននៅផ្នែក០០២/០១ នេះបញ្ចប់។ សូមភាគី មន្ត្រីបុគ្គលិក និងសាធារណជនជ្រាប ហើយអង្គជំនុំជម្រះក៏សូមបញ្ជាក់ជូនផងដែរថា នៅថ្ងៃស្អែកនេះជាថ្ងៃសម្រាកជាតិ ទិវាបុណ្យជាតិ ២៣ តុលា។

[១៥:៥៦:៥២]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃព្រហស្បតិ៍ ទី២៤ ខែតុលា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ចូលរួមដោយនៅក្នុងបន្ទប់សវនាការនេះ។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ដែលឃុំខ្លួនមួយដែលនៅខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង១៥:៥៧នាទី)*